ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**
**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី៦)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូបឺត ពើទីត *(Mr. Robert Petit)*

លោក យ៉េត ចរិយា

លោក វាលៀម ស្មីត *(Mr. William Smith)*

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេិត *(Mr. Alexander Bates)*

លោក ជឺហ្គិន អាស្មាន *(M.r Jurgen Assmann)*

លោក ប៉ាក ចាន់លីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទូត ហ្ស៊ីនស្គី *(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ *(Mr. Alain Werner)*

លោក ហ្វីលីព កាណុន *(Mr. Phillippe CANONNE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ខ្លឹមសារ

## សាក្សី

**សាក្សី ៖ ជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច**

សួរដោយ លោកស្រី ស៊ីលយី ស្ទុតហ្ស៊ីនស្គី ផ្តើមពី........................................ទំព័រ ១

សួរដោយ លោក ហុង គីមសួន ផ្តើមពី........................................ទំព័រ១៧

សួរដោយ លោក ការ សាវុត្ថ ផ្តើមពី........................................ទំព័រ២៤

សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី........................................ទំព័រ២៧

**សាក្សី TC-1 ៖ លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ**

សួរដោយប្រធានអង្គជំនុំ ផ្តើមពី........................................ទំព័រ៤២

សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី........................................ទំព័រ៥៦

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ដាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក រ៉ូបឺត ពើទីត | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[សវនាការចាប់ផ្តើមដំណើរការនៅម៉ោង០៩:០៦:២៥ នាទី]*

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជនុំជម្រះសាលាដំបូងប្រកាសបន្តដំណើរការសវនាការតទៅទៀត ។ ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី ព្រមទាំងសាក្សីដែលត្រូវបានកោះហៅឲ្យចូលមកផ្តល់ចម្លើយនៅក្នុងអំឡុងពេលថ្ងៃនេះ ។

**លោក ឌុច ផារី៖**

សូមគោរពលោកប្រធានភាគីទាំងអស់មានវត្តមានគ្រប់ចំនួននៅក្នុងព្រឹកនេះ សាក្សីក៏មានវត្តមានផងដែរ ។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ កាំង ហ្គេកអ៊ាវ មកកាន់ឈើរាងក្រចកសេះ ជាកន្លែងបម្រុងទុកសម្រាប់ជនជាប់ចោទ ។

ជាកិច្ចបន្តអង្គជម្រះផ្តល់វេទិកានេះទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងក្រុមបួន ដែលមិនទាន់បានសួរដល់ជនជាប់ចោទ ដោយអង្គជម្រះសូមជម្រាបថា អង្គជម្រះនឹងផ្តល់ពេលវេលាសម្រាប់ក្រុមនីមួយៗរយៈពេល៣០នាទី យ៉ាងយូរ ។ ទីពីរ សូមរំឭកនៅក្នុងការតាំងសំណួរដល់ជនជាប់ចោទ សូមជៀសវាងនូវសំណួរច្រំដែល ។ ទីពីរ គឺសូមតាំងសំណួរឲ្យបានច្បាស់ ក្នុងករណីសំណួរវែងអាចបង្កើតជាសំណួរខ្លីៗជាច្រើន ដើម្បីឲ្យច្បាស់លាស់ ដើម្បីឲ្យទុកឱកាសជូនដល់ជនជាប់ចោទ គាត់បានយល់អំពីសំណួរនេះច្បាស់លាស់ ដើម្បីឆ្លើយតបឲ្យបានត្រឹមត្រូវ ។

ជាដំបូងនេះសូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។

**សួរដោយលោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

លោកប្រធាន លោក លោកស្រីចៅក្រម អរគុណ ។ ខ្ញុំសូមចាប់ផ្តើមឥឡូវនេះ ។

**ស៖** ជាបឋមខ្ញុំចង់ដឹង ថាតើលោកយល់ស្របដែរ ឬទេ ថា ម-១៣ គឺជាមន្ទីរសម្លាប់មនុស្ស?

[០៩:១០:៣០]

**ជនជាប់ចោទ៖**

សូមគោរពកញ្ញាមេធាវីថា ពិតហើយ ។ មន្ទីរ ១៣ ជាយន្តការឧក្រិដ្ឋ ពីថ្ងៃ២០ កក្កដា ១៩៧១ រហូតដល់ថ្ងៃ១៧ មេសា ១៩៧៥ ។

**ស៖** តើលោកយល់ស្របដែរ ឬទេ ថាយើងអាចហៅមន្ទីរនេះ ថាជាមន្ទីរសម្រាប់សម្លាប់មនុស្ស? សូមឲ្យឆ្លើយឲ្យខ្លី ហើយឲ្យច្បាស់ ។

**ឆ៖** ខ្ញុំអត់ប្រកែកទេ ខ្ញុំបានជម្រាបហើយ ថាវាជាយន្តការសម្លាប់មនុស្ស ដែលមានរយៈកាលតាំងពីថ្ងៃ២០ កក្កដា រហូតដល់ថ្ងៃ១៧ មេសា ។ ខ្ញុំគិតត្រឹម១៧ទៅចុះ ។ ក្រៅអំពីមនុស្សដែលយើងខ្ញុំបានដោះលែង១០នាក់ ទាំងអស់សុទ្ធតែត្រូវបានសម្លាប់ និងបញ្ជូនទៅកន្លែងផ្សេង ។

**ស៖** ជាថ្មីម្តងទៀត និយាយឆ្លើយឲ្យខ្លី ហើយឆ្លើយសំណួរថា មែន ឬក៏មិនមែន? ចំពោះសំណួរហ្នឹង សំណួរហ្នឹង គឺអាចឆ្លើយថា មែន ឬក៏មិនមែន ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំមិនអាចទទួលយកបានទេ ចំពោះការលើកឡើងដូច្នេះ មេធាវីបានសួរសំណួរ ហើយគាត់ឲ្យឆ្លើយ យើងមិនបង្គាប់ឲ្យការឆ្លើយដូច្នេះទេ ។ គឺលោកស្រីអាចសួរសំណួរ ប៉ុន្តែមិនអាចបង្គាប់ឲ្យធ្វើការឆ្លើយបែបណានោះទេ ។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីការពារក្តី មានប្រសិទ្ធភាព ។ អ៊ីចឹងសូមមេធាវីតំណាងក្រុមពីរ តសំណួរផ្សេង សំណួរនេះមិនអនុញ្ញាតឲ្យសួរទៀតទេ ។

**សួរដោយលោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

ការរើសបុគ្គលិកនៅម-១៣ លោកបានប្រាប់ថា លោកមានប្រហែលជា២០នាក់ចំពោះបុគ្គលិក។

**ស៖** ថាលោកអាចជម្រាបយើងខ្ញុំដែរឬទេ? ថាតើពួកគាត់មានអាយុប៉ុន្មាននៅពេលដែលគាត់ចូលទៅមន្ទីរហ្នឹង? តើពួកគេមានអាយុប៉ុន្មាន នៅពេលដែលពួកគេចូលទៅ?

[០៩:១៣:២៨]

**ជនជាប់ចោទ៖**

**ឆ៖** ចំពោះក្មេងៗដែលស្ថិតស្ថេរជាមួយខ្ញុំរហូតទៅដល់មន្ទីរស-២១ នៅពេលដែលចូលភាគច្រើនមានអាយុ១៥-១៦ឆ្នាំឡើងលើ ក៏ប៉ុន្តែទាបជាង១៨ ។

**ស៖** ថា មួយណាដែលជាអាយុទាបបំផុត?

**ឆ៖** ទាបបំផុត នីរសារខ្ញុំម្នាក់ ឈ្មោះមិត្ត ឆេន នៅពេលដែលគាត់ទៅដល់ ទៅនៅជាមួយនឹងខ្ញុំអាយុ១២ ឬ១៣ឆ្នាំប៉ុណ្ណឹងទេ ។

**ស៖** តើមានស្រីដែរ ឬទេ?

**ឆ៖** បុគ្គលិកខ្ញុំមានស្រីម្នាក់ ស្ត្រីវ័យចាស់ ប្រពន្ធរបស់ KW០៨ ។

**ស៖** ថាតើមានបុគ្គលិកប៉ុន្មាននាក់ ដែលលោកជ្រើសរើសដោយខ្លួនឯង?

**ឆ៖** ខ្ញុំបញ្ជាក់ជូនលោកចៅក្រមម្សិលមិញដូចច្បាស់អស់ហើយ ។ បុគ្គលិកទាំងអស់របស់មន្ទីរ១៣ គឺខ្ញុំជ្រើសរើស មិនពេញចិត្តគឺខ្ញុំបញ្ជូនទៅភូមិឃុំវិញ ។

[០៩:១៥:១៩]

**ស៖** សំណួររបស់ខ្ញុំគឺថាមានចំនួនប៉ុន្មាន? ថាមានចំនួនបុគ្គលិកប៉ុន្មានដែលលោកបានជ្រើសរើសដោយផ្ទាល់ដៃដោយខ្លួនឯង? គឺលោកជ្រើសរើសដោយផ្ទាល់ខ្លួនឯង?

**ឆ៖** បុគ្គលិកទាំងអស់របស់មន្ទីរ-១៣ គឺខ្ញុំជ្រើសរើសដោយខ្លួនឯង ។

**ស៖** គឺដោយខ្លួនឯង ហើយដោយផ្ទាល់តែម្តង?

**ឆ៖** វាមិនដែលយើងធ្វើការងារអីកើតតែម្នាក់ឯងទេ ។ វាទាល់តែសហការជាមួយនឹងគណៈកម្មាធិការភូមិឃុំ ហើយនិងក្រោមការសម្រេចរបស់គណៈកម្មាធិការភូមិភាគ ។ ក៏ប៉ុន្តែ គំនិតផ្តើមទៅជ្រើសរើសអ្នកណាៗ គឺខ្ញុំគំនិតដើម ។

**ស៖** ថាលោកបានប្រាប់ដែរឬទេថាអ្នកក្មេងៗ ហើយនិងកូនក្មេងទាំងអស់នោះ ថាតើពួកគេត្រូវធ្វើអីនៅម-១៣?

**ឆ៖** រឿងនេះដូចជាខ្ញុំឆ្លើយអស់ហើយជាមួយនឹងលោកមេធាវី ជាពិសេសជាមួយនឹងលោកចៅក្រម យើងយក-- ខ្ញុំយកមកដល់ហ្នឹងមកឲ្យគេយាមអ្នកទោស មានតែពីរនាក់ទេ យាមដាំដំណាំ បង្កបង្កើនផល យាមបង្កបង្កើនផល ហើយអ្នកណាដែលអាយុច្រើនគួរសម យើងខ្ញុំឲ្យរៀនសួរ ។ ឯចំណែកមានតែមនុស្សម្នាក់ទេ គឺនីរសារខ្ញុំ--

**ស៖** សូមអភ័យទោស! វាមិនមែនជាសំណួររបស់ខ្ញុំទេ ខ្ញុំផ្អាកសួរហើយខ្ញុំ-- ថាតើលោកប្រាប់

គេយ៉ាងម៉េចនៅពេលដែលលោកទៅតាមភូមិ ហើយព្យាយាមជ្រើសរើសបុគ្គលិកហ្នឹង? អ៊ីចឹងនៅពេលដែលលោកនិយាយលើកដំបូងជាមួយអ្នកទាំងអស់ហ្នឹង តើលោកនិយាយយ៉ាងម៉េចនៅពេលដែលលោកទៅ ជ្រើសរើសហ្នឹង? ថាតើលោកប្រាប់ក្មេងៗនោះយ៉ាងម៉េច ថាពួកគេនឹងទៅធ្វើអីនៅ ម-១៣?

[០៩:១៧:៤០]

**ឆ៖** ម្សិលមិញខ្ញុំបានរាយការណ៍ជម្រាបលោកចៅក្រមហើយ កាលណាខ្ញុំចង់បានបុគ្គលិកថែមទៀត ខ្ញុំសួរបុគ្គលិកខ្ញុំដែលមាននៅក្នុងដៃ ។ តើអ្នកណាល្អ គេរាយការណ៍ប្រាប់មក ខ្ញុំស្ទាបស្ទង់មើលចុះមើលឡើងខ្ញុំពេញចិត្ត ខ្ញុំទៅស្នើសុំខាងលើ ។ ស្នើសុំខាងលើដើម្បីមកធ្វើជាបុគ្គលិករបស់ខ្ញុំ ខ្ញុំអត់ទាន់ទៅទាក់ទងផ្ទាល់របស់គេទេ ខុសច្បាប់ ។ ដូច្នេះ ខ្ញុំស្នើសុំទៅខាងលើដល់ខាងលើគេប្រគល់មកឲ្យខ្ញុំខ្ញុំបង្រៀន ។

**ស៖** ខ្ញុំថាលោកយល់សំណួរខ្ញុំដែរឬទេ? ប៉ុន្តែ ខ្ញុំដូចជាអត់ទទួលចម្លើយណាមួយទាក់ទងនឹងសំណួររបស់ខ្ញុំទេ ដូច្នេះហើយគឺខ្ញុំអត់ដឹងថាតើវាជាបញ្ហាបកប្រែ ឬក៏លោកមិនចង់ឆ្លើយតបទៅនឹងសំណួរខ្ញុំដោយផ្ទាល់?

**ឆ៖** ចង់ឆ្លើយណាស់ កញ្ញាមេធាវី ខ្ញុំពិតជាចង់ឆ្លើយ ខ្ញុំពិតជាចង់រាយការណ៍ជូនទាំងអស់ អត់ប្រកែកទេ ។ ក៏ប៉ុន្តែ ខ្ញុំជឿថាកញ្ញា ប្រហែលជាមិនយល់ចម្លើយខ្ញុំ ។ ខ្ញុំបានជម្រាបហើយថាខ្ញុំអត់បានទៅទាក់ទងទៅនឹងមនុស្សនោះផ្ទាល់មុននឹងគេចូលមកដល់មន្ទីរទេ ។ នេះជាបញ្ហាសំខាន់ ។

**ស៖** ថាតើលោកប្រាប់ក្មេងៗហ្នឹង ថាពួកគេនឹងទៅធ្វើការនៅមន្ទីរសម្លាប់មនុស្សដែរឬទេ?

**ឆ៖** យើងខ្ញុំរើសមកដល់ ដល់ដៃយើងខ្ញុំហើយ ដែលគណៈកម្មាធិការភូមិឃុំមកដល់ហើយយើងខ្ញុំប្រគល់ឲ្យគេធ្វើការងារ ។ យើងខ្ញុំមិនប្រើពាក្យថាមន្ទីរសម្លាប់មនុស្សទេ វាជាភារកិច្ចរបស់បក្សកុម្មុយនីស្តកម្ពុជាណាកញ្ញា ។ យើងខ្ញុំមិនអាចនិយាយពាក្យហ្នឹងបានទេ ទោះបីអាចថាជាពាក្យមន្ទីរសម្លាប់មនុស្សគឺ *កុងសិត* របស់បច្ចុប្បន្ននេះ ដោយយើងត្រូវតែចោទប្រកាន់មន្ទីរនោះព្រោះវាអមនុស្សធម៌ គ្មានច្បាប់ណាទៅការពារមន្ទីរហ្នឹងទេ។ ក៏ប៉ុន្តែ ជំនាន់ហ្នឹងយើងខ្ញុំអត់ប្រើពាក្យថាមន្ទីរសម្លាប់មនុស្សទេ គឺអញ្ជើញគេមកធ្វើការបដិវត្តន៍ ។ ការងារបដិវត្តន៍គឺស្អី ពេលហ្នឹងគឺសម្លាប់មនុស្សហ្នឹងហើយ ។

[០៩:២០:១៥]

**ស៖** ថាតើលោកបានសន្យានឹងក្មេងៗ និងឪពុកម្តាយរបស់គេដែរឬទេ? ថាពួកគេនឹងទទួលបាន

ការអប់រំល្អ ហើយទទួលបានការគាំទ្រផ្នែកសម្ភារៈអីផ្សេងៗ?

**ឆ៖** ផ្នែកសម្ភារៈសូមជម្រាបកញ្ញាដោយត្រង់ទៅ ជំនាន់ហ្នឹងអ្នកបដិវត្តន៍ជើងចាស់ប្រហែលជានៅទេ មួយខែបានដប់ប្រាំរៀលម្នាក់ៗ ឧបត្ថម្ភសម្រាប់ថ្នាំជក់ អ្នកណាមិនចេះជក់ថ្នាំ សន្សំលុយនឹងទុកកាត់សក់ ទុកអីទៀតទៅ ធ្វើអីទៀតទៅ ហ្នឹងមែន ។ ក្រៅពីនេះបានខោអាវអីកញ្ចែសកញ្ចាស់បន្តិចបន្តួចគ្មានអីពិសេសទេ ។ យើងស៊ីអត់ ស៊ីឃ្លានជាមួយគ្នា ដូចគ្នាមិនមានអ្នកណាលើសអ្នកណាទេ ។ នេះជារឿងពិត យើងខ្ញុំអត់បានប៊ានសន្យាទេ គឺរបបបក្សកំណត់ ។ ឯចំណែកសន្យាឲ្យការរៀនសូត្រវាជាកាតព្វកិច្ចរបស់យើងខ្ញុំ ត្រូវតែយកមាគ៌ាបក្សទៅបង្រៀនគេ ។ នេះជារឿងពិត ។

**ស៖** ថាតើមានក្មេងៗប៉ុន្មាននាក់ដែលជាបុគ្គលិករបស់លោកហ្នឹង ដែលបានរត់ពីកន្លែងលោកក្នុងកំឡុងពេលឆ្នាំ៧១ ដល់៧៥?

**ឆ៖** សូមជម្រាបកញ្ញាដោយត្រង់ អ្នករត់ចោលមិនបានទេ វាទាល់តែយើងខ្ញុំមានបំណងចង់ឲ្យគេត្រឡប់ទៅវិញ អាហ្នឹងបានយើងខ្ញុំចេះតែរកវិធីឲ្យគេចេញទៅវិញទៅ ។ ថ្ងៃនេះ ខ្ញុំជឿថាកញ្ញាគង់ឃើញមនុស្សពីរនាក់គឺ KW-30 និង KW-32 ដែលយើងខ្ញុំបានឲ្យត្រឡប់ទៅវិញមុនថ្ងៃ១៧ មេសា ១៩៧៥ ។

**ស៖** លោក តើខ្ញុំត្រឹមត្រូវ គិតថាត្រឹមត្រូវដែរឬទេ? លោកនិយាយថាគ្មានអ្នកណាម្នាក់រត់ចេញទេនៅក្នុងកំឡុងពេលហ្នឹង?

**ឆ៖** សូមបញ្ជាក់ជូនកញ្ញាដោយច្បាស់ ឲ្យច្បាស់ របបចាត់តាំងរបស់ខ្មែរក្រហមច្បាស់ណាស់មានរចនាសម្ព័ន្ធគេទាំងនៅភូមិឃុំ មានរចនាសម្ព័ន្ធរបស់គេទាំងនៅមន្ទីរ គ្មានអ្នករត់រួចទេ សូមជម្រាបកញ្ញា ។ ប៊ានរត់ចេញពីមន្ទីរ-១៣ហ្នឹង ដោយគ្មានការអនុញ្ញាតពីខ្ញុំ ខ្ញុំប្ដឹងទៅលើឲ្យគេរករឿងជាមួយប្រធានភូមិ ប្រធានឃុំ ។

ដូច្នេះ និយាយពីពាក្យថារត់គ្មាន និយាយពីយើងខ្ញុំឲ្យចេញដោយមានការស្រុះស្រួលចង់ឲ្យគេចេញ អាហ្នឹងវាមាន ។

[០៩:២៣:២៤]

**ស៖** ក្រៅពីផលដែលត្រូវបានរងការរងទារុណកម្ម រងការដាក់ទណ្ឌកម្ម ថាតើបុគ្គលិកផ្សេងៗទៀតតើលោកមានការដាក់ទណ្ឌកម្មពួកគេផ្សេងៗទៀតទេ ក្រៅពី ផល?

**ឆ៖** ផល មិនមែនត្រឹមតែដាក់ទណ្ឌកម្មទេ គឺខាងលើឲ្យខ្ញុំចាប់សួរចម្លើយ ហើយកម្ទេច អាហ្នឹង

មិនមែនជាទណ្ឌកម្មទេ ។ និយាយទណ្ឌកម្មនៅស្រាលណាស់ ក្រៅពី ផល ម្នាក់នៅមន្ទីរ-១៣“ក” គ្មានអ្នកណាទទួលរងការចាប់ចងនិងសម្លាប់ពីខាងលើនៅមន្ទីរ-១៣“ក” ទេ ។ បើមន្ទីរ-១៣“ខ” មានម្នាក់ដាក់ទណ្ឌកម្មដោយមិនឲ្យចូលយុវកក ឈ្មោះមិត្ត ភី ។

**ស៖** តើត្រូវដែរឬទេ ដែលមានតែផល ទេមកពីមន្ទីរម-១៣ “ក” ហ្នឹងដែលរងទារុណកម្ម មានតែ ផល ទេ?

**ឆ៖** *(ឮសំឡេងខ្យល់)*

**ស៖** លោកជម្រាបថាអម្បាញ់មិញ គឺអ្នកបកប្រែអត់បានស្តាប់ជនជាប់ចោទនិយាយ ដូច្នេះសូមឲ្យជនជាប់ចោទនិយាយម្តងទៀត ។

**ឆ៖** អ្នកដែលត្រូវសម្រេចឲ្យចាប់ចងនិងកម្ទេច អ្នកដែលត្រូវសម្រេចឲ្យចាប់ចង សួរចម្លើយហើយនិងកម្ទេច មានតែ ផល មួយទេ ។ ដូច្នេះ បើកញ្ញាប្រើថាពាក្យទណ្ឌកម្ម គឺមានតែមួយហ្នឹងឯងដែលទទួលទណ្ឌកម្ម ។

[០៩:២៥:៣០]

**ស៖** នៅពេលដែលលោកហ្វឹកហាត់បុគ្គលិកនៅម-១៣ ថាតើលោកបានប្រាប់ពួកគេ ប្រាប់បុគ្គលិកថា គឺមនុស្សអាចធ្វើការដាំដំឡូងនិងដំឡូងឈើផ្សេងៗទេ? ហើយសម្លាប់មនុស្សពីរនាក់នោះគឺវាមិនជាបញ្ហាធំធេងទេ? ថាតើលោកបានប្រាប់គេ ប្រាប់បុគ្គលិកអំពីបញ្ហា និងពាក្យដែលលើកឡើងអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ នៅជំនាន់នោះគ្មានការដាំដំណាំជាឯកជនបានទេ ទទួលផលជាឯកជនបានទេ ។ ខ្ញុំជាអ្នកចាត់ចែងកម្មវិធីឲ្យដាំដុះជាសមូហភាព បានផលមកចាត់ចែងជាសមូហភាព តាមការចាត់តាំង ។ នេះអំពីរឿងដាំដំណាំ ។ ឯចំណែករឿងពីរនាក់ដែលកញ្ញាសួរខ្ញុំ ថាសម្លាប់ពីរនាក់មិនជាការអីហ្នឹង សម្លាប់អ្នកណា ខ្ញុំអត់ទាន់យល់សំណួរហ្នឹងទេ ។

**ស៖** សំណួររបស់ខ្ញុំគឺ ថាតើលោកជំរុញឲ្យក្មេងសម្លាប់យ៉ាងហោចណាស់មនុស្សពីរនាក់ក្នុងមួយថ្ងៃដែរឬទេ? នៅពេលដែលលោកបាននិយាយថា លោកលើកឧទាហរណ៍ថា “មនុស្សអាចដាំដំឡូងវាប់រយគុម្ព ហើយសម្លាប់មនុស្សពីរនាក់នោះគឺមិនមានបញ្ហាអីធំធេងទេ គ្រាន់តែសម្លាប់ពីរនាក់នោះ?”

**ឆ៖** សូមជម្រាបកញ្ញាដោយត្រង់ណាស់ ខ្ញុំអត់ដែលធ្វើការប្រៀបធៀបអ៊ីចឹងទេ ក្នុងការអប់រំដាំដំណាំ គឺជាភារកិច្ចបដិវត្តន៍ ។ ការយកខ្មាំងទៅកម្ទេចនេះ យើងខ្ញុំសូមអនុញ្ញាតប្រើពាក្យរបស់បក្ស

កុម្មុយនីស្តកម្ពុជាជំនាន់ហ្នឹងចុះ ។ “តែកាលណាបក្សប្រគល់ភារកិច្ចឱ្យមិត្តហើយ មិត្តត្រូវតែបំពេញ” នេះពាក្យរបស់គេដែលខ្ញុំយកទៅបញ្ជាក្មេងៗ ។ តាមទស្សនៈឥឡូវរបស់ច្បាប់មនុស្សធម៌ តាមសេចក្តីថ្លែងការណ៍ជាសកលរបស់សិទ្ធិមនុស្សនេះ វាជាឧក្រិដ្ឋកម្ម វាជារឿងពិត ។ ទស្សនៈសម័យពីរវាខុសគ្នា ។ សម័យនោះខ្ញុំធ្វើមេបញ្ជាការគេ ឥឡូវសម័យនេះខ្ញុំមកឱនក្បាលទទួលមុខជំនុំជម្រះតុលាការនេះ ក្នុងឋានៈខ្ញុំជាអ្នកដឹកនាំគេ ។ សម័យនោះខ្ញុំផ្សាយមាគ៌ា--

[០៩:២៨:២០]

**ស៖** សូមអភ័យទោស! មិនមែនជាការឆ្លើយនឹងសំណួររបស់ខ្ញុំទេ សូមឱ្យលោកឆ្លើយតបនឹងសំណួររបស់ខ្ញុំដែលបានដាក់ជូនលោក ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោកប្រធានឱ្យមេធាវីធ្វើការសម្តែង និងសួរទៅកាន់ជនជាប់ចោទដោយគោរពបន្តិច ។

**ប្រធានអង្គជំនុំ៖**

បាទ, មេធាវីសូមរៀបចំនូវអាប្បកិរិយា និងពាក្យពេចន៍ ឱ្យបានសមរម្យដើម្បីរៀបចំសំណួរឱ្យបានត្រឹមត្រូវទៅជនជាប់ចោទ ហើយការនេះនឹងប្រព្រឹត្តិទៅបានល្អ ។

[០៩:៣០:០០]

**សួរដោយលោកស្រី ស៊ីលយីស្វួត ហ្សឺនស្គី៖**

**ស៖** ខ្ញុំសូមរំឭកលោកថា សូមឱ្យលោកឆ្លើយតបនឹងសំណួររបស់ខ្ញុំឱ្យខ្លីៗ ហើយឱ្យបានត្រឹមត្រូវ។ ខ្ញុំយល់ត្រឹមត្រូវដែរឬទេ? កាលពីម្សិលមិញលោកបានជម្រាបតុលាការថា លោកបានចាត់តាំងឱ្យមានការកម្ទេចទៅក្មេងៗពីរនាក់?

**ឆ៖** ក្មេងៗពីរនាក់ណា សូមកញ្ញាមេធាវីបញ្ជាក់បន្តិចមក? ខ្ញុំរកនឹកមិនឃើញទេ ក្មេងពីនាក់ណា? ព្រោះកងការពារខ្ញុំទាំងអស់ មិនមែនមានត្រឹមតែពីរនាក់ទេ ប្រហែលជាង១០នាក់ ខ្ញុំចាត់តាំងឱ្យបំពេញភារកិច្ចនេះ ។ បើតាមខ្ញុំចាំ ខ្ញុំនិយាយថា លើកលែងក្មេងពីរនាក់ អ៊ីចេះទៅវិញទេ ។ ដូច្នេះ កញ្ញាពិនិត្យ មើលការបកប្រែឬយ៉ាងម៉េច? ក៏ប៉ុន្តែនិយាយជាទូទៅ កងការពាររបស់ខ្ញុំជាង១០នាក់ ខ្ញុំចាត់តាំងឱ្យកម្ទេចមនុស្ស ។

**ស៖** ដូច្នេះ ខ្ញុំព្យាយាមរៀបសំណួរឡើងវិញ ។ លោកអាចបញ្ជាក់ដែរឬទេថាលោកបានចាត់តាំងភារកិច្ចកម្ទេចនេះទៅឱ្យក្មេងៗ គឺបុគ្គលិកក្រោមបង្គាប់របស់លោក គឺក្មេងៗ?

**ឆ៖** រឿងនេះវាជាសច្ចៈធម៌ដែលមានពិត ដូចភ្នំហិមាល័យអ៊ីចឹង មានតាំងពីណាពីណឹមក ។ ខ្ញុំបានបញ្ជាក់ជូនតុលាការតាំងពីដើមអើយមក ។ ខ្ញុំចាត់តាំងក្មេងៗឲ្យកម្ទេចមនុស្ស។ នេះជារឿងពិត ។

**ស៖** អរគុណ ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើត្រឹមត្រូវដែរឬទេ ? លោកសង្កេត ឬពិនិត្យមើលលើកដំបូងនៅ ពេលដែលគេកម្ទេចអ្នកទោស ថាតើលោកបានសង្កេតដោយមើលលើកទីមួយដែរឬទេ នៅពេលដែល ពួកគេកម្ទេចអ្នកទោស?

**ឆ៖** រឿងនេះ ខ្ញុំបានជម្រាបតុលាការតាំងពីហូរហែមក ហើយជាហូរហែមកទៀត ក្រៅតុលាការ ក៏ខ្ញុំនិយាយដែរ ។ ខ្ញុំមិនដែលបានទៅមើលទេ ។ រយៈដំបូងនុ៎ង គឺចាត់ចែងឲ្យគេធ្វើ ខ្ញុំជាអ្នកណែនាំ តាមការណែនាំរបស់មេខ្ញុំ គឺ ឆាយ គឹមហ៊ ។ ដូច្នេះ ឲ្យទៅមើល គឺខ្ញុំអត់មើលទេ ។

[០៩:៣២:៣០]

**ស៖** ថាលោកត្រូវបានជម្រាបថា ពួកគេគឺបានសម្លាប់មនុស្ស ហើយកម្ទេចមនុស្ស ហើយថាពួកគេបុគ្គលិកហ្នឹង គឺមានការស្ទាក់ស្ទើរក្នុងការកម្ទេចដែរឬទេ?

**ឆ៖** រឿងស្ទាក់ស្ទើរ ឬមិនស្ទាក់ស្ទើរខ្ញុំអត់ច្បាស់ទេ ។ ក៏ប៉ុន្តែក្រោយមក ខ្ញុំឮបុគ្គលិកខ្ញុំម្នាក់ គឺឈ្មោះ មិត្ត ប៉ុន មករាយការណ៍ប្រាប់ខ្ញុំ ថាមិត្ត មាស ហ្នឹងកម្ទេចមនុស្សសុទ្ធតែយោលជើង ។ ដូច្នេះនេះជាព័ត៌មានដែលខ្ញុំទទួលបានពីថ្នាក់ក្រោមមក គេរាយការណ៍ឲ្យខ្ញុំអំពីការងារកម្ទេច ។ សូមបញ្ចប់។

**ស៖** ការឆ្លើយរបស់លោកលើកមុន លោកប្រាប់យើងថា លោកមិនដែលឃើញផ្ទាល់ភ្នែកចំពោះការកម្ទេច ការសម្លាប់នៅម-១៣ ដែលវាប្រហែលជា១០០ម៉ែត្រ ពីការិយាល័យរបស់លោក តើនេះជាអ្វីដែលលោកចង់និយាយ និងបានលើកឡើងដែរឬទេ?

**ឆ៖** កញ្ញាមេធាវី សូមបញ្ជាក់ថា អមលាំង មិនមែនស្រឡះផ្លុងថ្លឹងដូចក្រុងភ្នំពេញទេ ។ វាមានព្រៃ ចេញផុតតែពីអាកន្លែងឃុំឃាំងតែ៥ម៉ែត្រចប់ហើយ អត់មើលគ្នាឃើញទេ ១០ម៉ែត្រ យើងខ្ញុំនិយាយថា១០ម៉ែត្រទៅចុះ មើលគ្នាអត់ឃើញទេ ។ ហើយសូមដូចបញ្ជាក់ថា នៅម-១៣ អាផ្ទះមួយធំជាងគេនោះម្ចាងស្ទឹងម្នាក់ទេ ។ ដូច្នេះ វាមិនដល់១០០ម៉ែត្រទេ ។

**ស៖** អ៊ីចឹងចម្លើយគឺថា បាទ គឺមែន ។

**ឆ៖** ពិតជាមែន ព្រោះខ្ញុំអត់ទៅមើល ទោះបីជិតត្រឹម១០០ម៉ែត្រ ក៏ខ្ញុំអត់ទៅមើលដែរ តែមិនមើល គឺវាមិនឃើញហើយ ។

**ស៖** គឺខ្ញុំសូមលើកឡើងអំពីអ្នកទោស ហើយខ្ញុំចង់ដឹងប្រហែលលោកនិយាយម្សិលមិញ ឬក៏ថ្ងៃម្សិលម្ង៉ៃ ឬក៏មានការបកប្រែច្រឡំ ឬយ៉ាងម៉េច? ដូច្នេះ ខ្ញុំចង់សួរលោកសំណួរដូចខាងក្រោម៖

ថាតើមានអ្នកទោសចំនួនប៉ុន្មានជាមធ្យមនៅម-១៣?

គឺម-១៣“ក” សូមអភ័យទោសម-១៣“ក”?

[០៩:៣៥:៣២]

**ឆ៖** ម-១៣“ក” ក្រោយពីរឿងអ្នកទោសរត់ម្តង ប្រហែល៣០នាក់ យើងខ្ញុំមិនដែលទុកឲ្យលើស១០នាក់ទេដែរ ។ ហើយ គេក៏មិនឲ្យខ្ញុំទុកលើស១០នាក់ដែរ ។

**ស៖** គឺចំនួនមធ្យម ខ្ញុំដឹងថាមាន៣០នាក់រត់។ អ្នកទោស៣០នាក់ រត់ក្នុងថ្ងៃមួយ ។ អ៊ីចឹង គឺថាចំនួនមធ្យម គឺលោកមានចំនួន១០នាក់ ជាមធ្យមនៅក្នុងគុករបស់លោក ឬយ៉ាងម៉េច ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំនិយាយមិញ សូមកញ្ញាពិនិត្យមើល ។ រយៈកាលពីរ មុនអ្នកទោសរត់ យើងខ្ញុំសន្សំឲ្យអ្នកទោសឲ្យទៅធ្វើស្រែរហូត៣០នាក់ នៅសល់ ។ ក្រោយពីនោះមក យើងខ្ញុំមិនដែលបានទុកឲ្យលើស១០នាក់ទេ ។ តែសួរហើយ សុំយោបល់គេហើយ គេឲ្យកម្ទេច យើងខ្ញុំកម្ទេចហើយ ។ ដូច្នេះ មិនដែលមានលើស១០នាក់ទេ ។

**ស៖** លោកអាចបំភ្លឺដែរឬទេ ថាតើមនុស្ស៣០នាក់រត់ចេញហ្នឹងកើតឡើងនៅពេលណា?

**ឆ៖** នៅឆ្នាំ១៩៧២ សូមទោសណ៎ារឿងខែឆ្នាំខ្ញុំច្រឡំបន្តិច អាចច្រឡំបន្តិច ដូច្នេះអាចចុងឆ្នាំ១៩៧២ ឬដើមឆ្នាំ ។ ក៏ប៉ុន្តែ ទីតាំងច្បាស់ហើយ កញ្ញាទៅតាមដានសួរគេទៀតទៅ នៅកន្លែងមួយនៅជើងភ្នំពីស ឈ្មោះ ទួលស្វាយមាស ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ធំ អូ៎! សុំទោសស្រុកថ្ពង ខេត្តកំពង់ស្ពឺ។

**ស៖** ហើយម្សិលមិញលោកបាននិយាយថា ជាមធ្យមរាល់ថ្ងៃលោកទទួល ឬក៏រាល់១០ថ្ងៃ រៀងរាល់ ១០ថ្ងៃ លោកបានទទួលអ្នកទោសប្រហែលជាម្នាក់ ។

**ឆ៖**សូមបញ្ជាក់ជូនកញ្ញាថា ការមករបស់អ្នកទោស មកដល់ម-១៣ វាមិនមែនជាផែនការដែលយើងកំណត់កើតទេ ។ ដូច្នេះ វាមកតាមយថាហេតុ ដែលគេផ្តល់មកឲ្យយើងខ្ញុំ ។ ខ្ញុំនិយាយថាយូរៗមកមួយ ឬពីរ ឬបី ។ ខ្ញុំនិយាយអ៊ីចឹង ។

[០៩:៣៨:១៧]

**ស៖** ថាតើលោកបានរៀបជាក្រុម ដាក់អ្នកទោសនៅក្នុងជាក្រុម តាមប្រភេទរបស់អ្នកទោសដែរឬទេ?

**ឆ៖** កញ្ញាចង់ឲ្យខ្ញុំនិយាយពីប្រភេទយ៉ាងម៉េច? សូមមេត្តាបញ្ជាក់ឲ្យខ្ញុំបានច្បាស់?

**ស៖** ឧទាហរណ៍ អ្នកដែលមានទោសស្រាល ហើយនិងអ្នកដែលទោសធ្ងន់ ។ ឧទាហរណ៍ កម្មាភិបាល ហើយនិងទាហាន លន់ នល់ គឺ។ល។ ហើយនេះ គឺជាឧទាហរណ៍នូវអ្វីដែលខ្ញុំ មានន័យថា អំពីប្រភេទក្រុមហ្នឹង ។

**ឆ៖** សូមបញ្ជាក់ថា មនុស្សដែលទៅជាប់ហ្នឹង ម-១៣ យើងខ្ញុំឲ្យពិសេសតែប៉ុន្មានពីរនាក់ទេ ។ អានេះខ្ញុំមិននិយាយអំពី TC១ ទេ ។ TC១ គេមានកន្លែងដេកអីរបស់គេស្រួលបួល ។ ឯចំណែកក្រោយមកមានអ្នកទោសពីរនាក់ ដែលយើងខ្ញុំទុកពិសេស គឺកម្មាភិបាលហាណូយម្នាក់ ឈ្មោះ ប្រាជ្ញ សុន ហៅ ពត អនុលេខាវរសេនាតូច ដែលគេចោទថា បាញ់មេខ្លួនឯង ។ ហើយទីពីរ មនុស្សទីពីរដែលយើងខ្ញុំរៀបចំឲ្យដេកស្រួលបួលមានកន្លែងស្រួលបួលដែរ គឺ សង្ហា ហឿន សមាជិក តំបន់៣៣ ភូមិភាគនិរតី នេះគឺដោយឡែកមែន គេមានសិទ្ធិ មានអី គ្រែដេក មានមុងអីរបស់គេស្រួលបួលមែន ។ នេះជំនាន់ហ្នឹង។ ឯរបបហូបចុកក៏មិនប្លែកពីកងការពារយើងខ្ញុំប៉ុន្មានដែរ តែវាមិនដល់ខ្ញុំទេ។ សូមបញ្ចប់ ។

**ស៖** ខ្ញុំយល់ត្រូវដែរឬទេ? ក្នុងចំណោមអ្នកទោសដទៃទៀត គឺត្រូវបានប្រព្រឹត្តលើស្មើៗគ្នាដូច្នេះហើយ គឺពួកគេបានគិតថាពួកគេជាដាក់នៅក្នុងក្រុមមួយ?

**ឆ៖** អ្នកទោសទាំងអស់ ខ្ញុំសូមជម្រាបកញ្ញាឲ្យច្បាស់ថា មនុស្សស្រាលគេអត់យកមកមន្ទីរ១៣ “ក”ទេ គេទុកនៅមន្ទីរ១៣“ខ”ឯណោះ ។ មនុស្សធ្ងន់ដែលគេចង់បានចម្លើយ ហើយចង់ឲ្យម-១៣ “ក” សម្លាប់ ជាពិសេសគឺគេចង់បានចម្លើយ គឺគេឲ្យមកម-១៣“ក” ដូច្នេះ គ្មានស្រាលទេៗ ។

[០៩:៤១:០៨]

**ស៖** ថាតើមានរយៈពេលប៉ុន្មាន? ដែលអ្នកទោសស្រាលទាំងអស់នោះនៅម-១៣“ក” មុនពេលដែលពួកគេបានបញ្ជូនទៅ ម-១៣“ខ” ។

**ឆ៖** ឥឡូវកញ្ញាសួរសំណួរដូចនេះដល់ខ្ញុំ កញ្ញាស្ដាប់សភាពការណ៍អត់បានទេ ។ ខ្ញុំសូមមេត្តានិយាយឲ្យបានច្បាស់ ហើយវែងបន្តិចបានទេ?

**ស៖** គឺវាគ្រប់គ្រាន់ចំពោះខ្ញុំហើយ ចំពោះការឆ្លើយតបអំពីរយៈពេលដែលពួកគេនៅទុំង ដែលគេរង់ចាំមុនពេលដែលបញ្ជូនទៅ ។

**ឆ៖** ខ្ញុំថាកញ្ញាអត់យល់សភាពការណ៍ទេ ។ មិនដែលមានអ្នកទោសណា យើងខ្ញុំបញ្ជូនពីម-១៣ "ក" ទៅ ម-១៣"ខ" ទេ ខ្ញុំបានជម្រាបតុលាការម្សិលមិញច្បាស់លាស់ ។ ថ្ងៃណាម-១៣"ខ" កកើតគេចូលពីមូលដ្ឋានមកមកនៅម-១៣"ខ" ។ គ្មានការបញ្ជូនជនរងគ្រោះ ដែលជាជាប់ទោសនៅទីនោះទៅ ម-១៣"ខ" វិញទេ ។ គ្មានរឿងរង់ចាំនៅទីនោះទេ ឯចំណែកការរង់ចាំនៅ ម-១៣"ខ" ដើម្បីដោះលែង ជាការសម្រេចរបស់គណៈតំបន់ ហើយនិងគណៈភូមិភាគ ។ ឯត្រូវជាប់មួយខែ កន្លះខែ ឬពីរខែ គ្មានទេ ស្រេចនឹងគេ គេយល់ឃើញសភាពការណ៍ធូរស្រាល គេដោះ ។

**ស៖** ខ្ញុំចូលអំពីការដាក់ទណ្ឌកម្ម និងការធ្វើទារុណកម្មនៅលើវិធីទាំងអស់នោះ ។ ខ្ញុំចង់ដឹងថាតើកដែ ថាតើដោះរបស់ស្ត្រីត្រូវបានដុតដោយសារតែនេះជាអំពើការដាក់ទោសទណ្ឌកម្ម និងការធ្វើទារុណកម្មដែរឬទេ ដែលថាដោះគាត់ត្រូវបានគេដុត?

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូនកញ្ញាថា អ្នកសួរចម្លើយស្រីៗ គ្មាននរណាក្រៅពីខ្ញុំទេ ។ ខ្ញុំអត់មានដុតទេ ដូច្នេះ គ្មានដោះស្រីៗណាម្នាក់ខ្ញុំបានត្រូវខ្ញុំមើលឃើញទេ បើមើលវាមិនឃើញហើយ ខ្ញុំបានអីទៅដុត?

[០៩:៤៣:៥៧]

**ស៖** ថាតើវាកើតឡើងដែរឬទេចំពោះអំពើបែបនេះ? គឺជាវិធីដែលយើងដុត យកចន្លុះ យកឈើចាក់នៅក្នុងយោនីរបស់ស្ត្រី?

**ឆ៖** កញ្ញាសួរខ្ញុំពីរឿងមន្ទីរ១៣ ឬសួរនៅ២១ ? សូមបញ្ជាក់ ?

**ស៖** ម-១៣?

**ឆ៖** ម-១៣ គ្មានទេ បើនៅ២១ មានម្នាក់ ។

**ស៖** ថាតើអ្នកទោសនៅម-១៣ ត្រូវបានគេដោះខោអាវដែរឬទេ ?

[០៩:៤៥:00]

**ឆ៖** អាអ្នកទោសប្រុសៗ វាដោះវាអីស្រេចតែវា វាអត់ដែលដោះរហូតដល់ស្រាតទេ ពីព្រោះមានស្រីៗនៅជាប់ឃុំហ្នឹង ឯចំណែកស្រីៗគ្មានអ្នកណាដោះ ប៉ុន្តែវាមានពេលផ្លាស់ខោអាវចុះងូតទឹក ។

**ប្រធានអង្គជំនុំ៖**

សូមជម្រាបមេធាវីថា ពេលវេលាខ្លីហើយ ។ មេធាវីមានពេលវេលាប្រាំមីនុតទៀត សម្រាប់តាំងសំណួរនេះ ។

**លោកស្រី ស៊ីលឃីស្នូត ហ្សីនស្គី៖**

លោកប្រធាន ប្រសិនបើលោកប្រធានអនុញ្ញាត យើងអាចចែករំលែកក្នុងចំណោមក្រុមយើងចំពោះពេលវេលានោះ ដើម្បីយើងយករយៈពេលមួយម៉ោងហ្នឹង ហើយយើងចែករំលែកក្នុងក្រុមរបស់យើងតែម្តង ។ តើលោកប្រធានអនុញ្ញាតដែរ ឬទេ ចំពោះសំណើបែបនេះ?

**ប្រធានអង្គជំនុំ៖**

ក្រុមយ៉ាងម៉េចទៅ ក្រុមណា? រវាងក្រុមណា នឹងក្រុមណា?

ឥឡូវអស់សែសិបមីនុតហើយ សែសិបប្រាំមីនុតហើយ នៅសល់តែដប់ប្រាំមីនុតទៀតទេ ។ មួយក្រុមកន្លះម៉ោង ។ មានព្រំដែនរបស់វា ។

**លោកស្រី ស៊ីលយីស្វត ហ្សីនស្គី៖**

លោកប្រធាន ខ្ញុំយកម៉ោង រយៈពេលកំណត់នេះចែករំលែកជាមួយនឹងក្រុមប្អូន ដើម្បីរំឭកថាខ្ញុំចាប់ផ្តើមសំណួររបស់ខ្ញុំ គឺខ្ញុំមើលទៅតាមម៉ោងនៅទីនោះ គឺខ្ញុំចាប់ផ្តើមនៅម៉ោងប្រាំបួនដប់នាទី គឺមិនមែន ម៉ោង៩គត់នោះទេ ។ ដូច្នេះខ្ញុំសូមបន្តសំណួរខ្ញុំបន្តទៀត ។

**ស៖** ថាតើមានវិធីដកក្រចកអ្នកទោសដែរឬទេ?

**ឆ៖** ខ្ញុំបានឆ្លើយជម្រាបលោកព្រះរាជអាជ្ញាហើយ នេះបើតាមខ្ញុំចាំ គ្មានទេនៅ ម-១៣ ខ្ញុំសូមបញ្ជាក់នៅ ម-១៣ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោក-- *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមម្តងទៀត អត់បានស្តាប់ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកចៅក្រម សូមអរគុណ ។ ខ្ញុំបានបញ្ជាក់ថា ព្រឹកនេះដើមបណ្តឹងរដ្ឋប្បវេណី បានរំឭកថាមិនឱ្យសួរសំណួរដដែលឡើងវិញទេ ដែលបានសួររួចមកហើយនោះ ។ ខ្ញុំកត់សម្គាល់ឃើញថា ចំពោះពេលនេះសំណួរទាំងដប់ ដែលបានមេធាវីបានសួរទៅ ហើយជនជាប់ចោទ លោកបានឆ្លើយហើយ។ គាត់ក៏បានបញ្ជាក់ដែរ គាត់ឆ្លើយទៅចៅក្រម ឡាវែន៍ ឆ្លើយទៅសហព្រះរាជអាជ្ញា ហើយខ្ញុំក៏បានឆ្លើយទៅអង្គបុរេអង្គជំនុំជម្រះដែរហើយ ។ អ៊ីចឹងហើយគឺឆ្លើយដប់ដង ដប់សំណួររួចហើយ គឺភាគច្រើនគឺសំណួរដដែល ។ សូមឱ្យមេធាវីកុំសួរសំណួរដដែលៗសាឡើងសារចុះបែបនេះ សូមអរគុណ ។

[០៩:៤៨:៥៨]

**ប្រធានអង្គជំនុំ៖**

រំឭកមេធាវីម្តងទៀត អង្គជំនុំជម្រះក៏កត់សម្គាល់ឃើញដូច្នេះដែរ ។ សុំមេធាវីសួរនូវសំណួរណាដែលជៀសវាងនូវការសួរនូវសំណួរច្រំដែល ។ ហើយបញ្ហាទីពីរ គឺសូមស្តាប់ឲ្យបានច្បាស់លាស់នៅចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយជាមួយនឹងចៅក្រម ជាមួយនឹងភាគីដែលបានតាំងសំណួររួចហើយ ជៀសវាងការសួររឿងនេះដដែលទៀត ។

**សួរដោយលោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

**ស៖** ឥឡូវនេះខ្ញុំចូលទៅដល់វិធីកម្ទេច ឬក៏សម្លាប់មនុស្ស ។ តើលោកបានឮសម្រែកអ្នកទោសដែរឬទេ នៅពេលដែលគេរងអំពីទារុណកម្ម? ឬនឹងមុនពេលដែលគេសម្លាប់អ្នកទោសនោះ បានឮសម្រែកដែរឬទេ?

**ឆ៖** មិនមែនតែខ្ញុំដែលនៅហ្នឹងកន្លែងទេ អ្នកដែលនៅកន្លែងទាំងប៉ុន្មាន អត់ឮសម្រែកជនរងគ្រោះ ដែលគេប្រហារជីវិត ដោយសារគល់ឫស្សីវែងធំ *សៀវរើលេ* នេះទេ ។

**ស៖** តើលោកអាចបំពេញចម្លើយនេះទេ ពីព្រោះខ្ញុំលែងបញ្ជាក់ពីថា ការសម្រែករបស់អ្នកទោស នៅពេលដែលគាត់រងទារុណកម្ម ហើយមួយទៀត មុនពេលដែលគេសម្លាប់ហ្នឹង មានឮសម្រែកទ្រហោយំអ្វីទេ? តើលោកបានឮទេ?

[០៩:៥០:៥៨]

**ឆ៖** អត់ឮទេៗ អត់ឮសោះ ។

**ស៖** តើមានការអារ-ក ឬក៏កាត់កររបស់អ្នកទោសដែល ដើម្បីបង្ហូរឈាមទៅដាក់កន្លែងណាមួយ ឬក៏បំពង់អ្វីមួយទេ?

**ឆ៖** គ្មានទេ ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់ចំណុចមួយទៀត ខ្ញុំចង់ដឹងថា តើលោកបានដឹងអំពីកំហុសអសីលធម៌-- កំហុសសីលធម៌ហ្នឹង ដូចម្តេចដែលថា ផល បានធ្វើហ្នឹង តើលោកបានដឹងថាម៉េច ដែលថា ផល បានប្រព្រឹត្តខុសសីលធម៌នោះ?

**ឆ៖** ផល ប្រព្រឹត្តខុសសីលធម៌ ប្រព្រឹត្តខុសសីលធម៌នៅមន្ទីរម-១៣“ខ” ក្នុងឋានៈគាត់ជាអនុប្រធានទៅប៉ះពាល់សីលធម៌ជាមួយនឹង-- ខ្ញុំមិនហៅថាអ្នកទោសទេ ស្ត្រីម្នាក់ដែលគេយកមកអប់រំសាថ្មី

គាត់ស្អាត ។ គ្នាគេពីរនាក់ មិត្តភី ហើយនឹងមិត្ត ផល ។ ផល បែកការណ៍ មិត្ត ស៊ុំ វាយការណ៍ទៅខាងលើផ្ដាស់ទៅ ថែមមិត្តភីមួយទៀត ។ ដូច្នេះ រឿងហ្នឹង វាបែកខ្ចរខ្ចាយពេញម-១៣"ខ" ។ ខាងលើត្រូវតែទទួលស្គាល់ថា នេះជាការពិត ទាំងខ្ញុំ ទាំងខាងលើទៅទៀត ។

**ស៖** តើលោកអាចបញ្ជាក់បន្ថែមបានទេ តើប្រភេទនៃកំហុសសីលធម៌នេះ ដែលគាត់រងការចោទប្រកាន់ពេលនោះ គេចោទប្រកាន់ខុសសីលធម៌អ្វី?

**ឆ៖** ភាសាខ្ញុំ ភាសារបស់បក្សកុម្មុយនីស្ត អាហ្នឹងគេហៅថា សីលធម៌ផ្លូវភេទ។ ហើយត្រង់អ្នកស្រីថា-- កញ្ញាថាម៉េច អាហ្នឹងមិនដឹងទេ ថាទៅចុះ ។

[០៩:៥៣:៤៦]

**ស៖** តើលោកបានទទួលការណែនាំអ្វីទេ ដែលទាក់ទងទៅនឹងកំហុសសីលធម៌នោះ ថាលោកទទួលការណែនាំឲ្យធ្វើដូចម្ដេច?

**ឆ៖** ដោយឡែក ចំពោះករណីមិត្ត ផល ខាងលើជ្រាប ខាងលើដោះស្រាយ ផ្ទេរគាត់ចេញពីអង្គភាពម-១៣"ខ" ទៅកន្លែងមួយផ្សេងទៀត ។ ឯចំណែកមិត្តភី ខាងលើជ្រាប ខាងលើសម្រេចមិនឲ្យចូលយុវកក ។ ខ្ញុំបានជម្រាបតុលាការរួចម្សិលមិញអស់ហើយ ។

**ស៖** ខ្ញុំព្យាយាមសួរម្ដងទៀត តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បានទេ? តើអ្វីជាកំហុសសីលធម៌ នៅពេលនេះ តើផលបានធ្វើអ្វីដោយជាក់ស្ដែង ដែលថាខុសសីលធម៌ខាងផ្លូវភេទហ្នឹង គាត់ធ្វើអ្វី?

**ឆ៖** ទំនៀមទម្លាប់ខ្មែរ ក៏ដូចជានៅក្នុងជួរបដិវត្តន៍ដែរ យើងទៅខូចក្រាញ់នឹងគ្នា ដោយគ្មានរៀបការ អាហ្នឹងគេហៅថា ខុសសីលធម៌ហើយ ។ នៅក្នុងជួរបដិវត្តន៍ បើកាលណាអង្គការមិនរៀបការឲ្យអ្នកឯងទេ អ្នកឯងកុំទៅដេកជាមួយគ្នា ។ អាហ្នឹងតែដេកជាមួយគ្នា ខុសសីលធម៌ហើយ តែដល់រៀបការ ហើយដេកជាមួយគ្នា អាហ្នឹងជាកិច្ចការគ្រួសារគេ ។ នេះយើងខ្ញុំ បែងចែកអ៊ីចឹង ។

**ស៖** តើអំពើហ្នឹងរាប់បញ្ចូលទាំងកំហុសសីលធម៌ ឬក៏ថាការរួមភេទដោយចេតនា ដោយមានបំណង ឬក៏ដោយអចេតនាពីភាគីណាមួយដែរឬទេ?

**ឆ៖** អារំលោភដោយខាងភាគីស្រី គេមិនព្រម អាហ្នឹងកាន់តែធ្ងន់ ។ បើថាវាព្រមល្មមទាំងអស់គ្នា អាហ្នឹងវាល្មមទេ ដូចរឿងមិត្ត ផល ហើយនឹងអាឡា នោះ ស្រីៗនោះ នាងស្រីនោះ អាហ្នឹងម៉ាល្មមដែល គេមកផ្ដាស់ទៅ ។ បើអ្នកឯងរំលោភវិញ អ្នកឯងចាប់ខ្មោះឥឡូវហ្នឹង អាហ្នឹងកាលណោះ ខ្ញុំឃើញគេអនុវត្តអ៊ីចឹង ។

[០៩:៥៦:៣៧]

**ស៖** ម្សិលមិញលោកបាននិយាយថា គឺថាមានការប្រជុំស្វ័យទិតៀន តើអ្នកណាជាអ្នកចូលរួមក្នុងការប្រជុំនេះនៅក្នុងម-១៣?

**ឆ៖** ប្រជុំទិតៀននិងស្វ័យទិតៀន វាធ្វើតាមក្របខ័ណ្ឌរបស់វា ។ ខ្ញុំជាបក្ខជន ខ្ញុំធ្វើនៅក្នុងសាខាបក្ស ។ គ្នាខ្ញុំប្រជុំសាខាបក្ស មាន៤នាក់ ដំបូងមាន៤នាក់ គឺប្រធានមន្ទីរ៣០៥ ឈ្មោះ វស់ ជាតិថ្វ ហៅ ជាតិ ប្រធានមន្ទីរ៣០៧ ឈ្មោះ សៀង ប៉ៅសែ ហៅ នាគ ។ ប្រធានមន្ទីរ ម-១៣“ក” ឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច និងប្រធាន ម-១៣ “ខ” ឈ្មោះ ហ្វូ គឹមអេង ហៅ ស៊ុំ ។ នេះបក្ខជន៤នាក់នេះ វាប្រជុំរាល់កន្លះខែម្ដង ។

**ស៖** ហើយបន្ទាប់មក តើមានការប្រជុំសម្រាប់តែរវាងបុគ្គលិករវាងម-១៣“ក” និងម-១៣“ខ” ដែរ ឬទេ ទាក់ទងទៅនឹងការប្រជុំស្វ័យទិតៀននេះ?

**ឆ៖** ខ្ញុំបានជម្រាបកញ្ញាមិញហើយ ក្នុងការប្រជុំជីវភាពបក្ស មាន ហ្វូ គឹមអេង ហៅ ស៊ុំ ហើយនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅក្នុងហ្នុងហើយ ។ ដូច្នេះ សំណួររបស់កញ្ញានេះ ជាន់នឹងសំណួរលើកមុនហើយ ។

**ស៖** តើការប្រជុំទាំងនោះធ្វើឡើងនៅពេលយប់ ឬក៏ពេលណា?

**ឆ៖** ការប្រជុំទាំងអស់នោះធ្វើមួយថ្ងៃ ពីព្រឹកដល់ល្ងាច ។

**ស៖** តើការប្រជុំហ្នឹងពេញមួយថ្ងៃដែរឬទេ?

**ឆ៖** ជម្រាបកញ្ញាមិញរួចហើយ ពីព្រឹកទល់ល្ងាច បានន័យថា ពេញមួយថ្ងៃ ។ ដូច្នេះ សំណួរនេះ ជាន់លើអាសំណួរមិញទៀតហើយ ។

[០៩:៥៩:៣៤]

**ស៖** សូមទោស គឺថានៅក្នុងការបកប្រែអង់គ្លេស គឺថាមិនបានបង្ហាញថា ប្រើពេលប៉ុន្មានទេហើយ ខ្ញុំសូមទោស ប្រសិនជាលោកបានឆ្លើយពីម្សិលមិញរួចហើយនោះ គឺសូមប្រាប់ខ្ញុំ ។

តើលោកអាចប្រាប់យើងបានទេ ថាតើអ្វីដែលលោក ខ្លួនលោកផ្ទាល់ហ្នឹង លោកបានទទួលការទិតៀនអ្វីខ្លះ ឬក៏ទិតៀនគេអ្វីខ្លះ? តើលោកធ្វើស្វ័យទិតៀនហ្នឹង តើលោកលើកឡើងពីចំណុចអ្វីខ្លះ ទាក់ទងទៅនឹងកំហុសអ្នកដទៃ ឬក៏កំហុសខ្លួនឯងដែរផង?

**ឆ៖** ខ្ញុំសូមជម្រាបដំបូង បើសិនជាកញ្ញាពេញចិត្តស្តាប់ក៏សូមមេត្តាស្តាប់មួយព្រួសដំបូងសិន ។ ការប្រជុំជីវភាពវាមានរបៀបវារៈដូចតទៅ៖

ទី១) លើកឡើងការងារចាស់ រាយការណ៍ការងារចាស់អ៊ីចឹងទី១ ។ ទី២) ពិនិត្យការងារចាស់នេះមានស្អីជាគុណសម្បត្តិ ស្អីជាគុណវិបត្តិ ។ ទី៣ នៅក្នុងពេលហ្នឹង យើងធ្វើស្វ័យទិតៀនយើង បានន័យថា យើងធ្វើ *អូតូគ្រីទិច* ហើយឃើញថា យើងនេះ! វាមានអ្វីបាននាំឲ្យមានគុណវិបត្តិបែបនេះ ការងារវាដើរមិនបានបែបនេះ ។ ដល់ការណាយើងដាក់ខ្លួនជូនសមូហភាពអ៊ីចឹងហើយ ឲ្យគេទិតៀនមកយើង ។ គេថា "ន៉ែ!មិត្តឯងមើលឃើញតែប៉ុណ្ណេះទេ តាមពិតមិត្តឯងខុសអាត្រង់នុ៎ងទៀត មិត្តកែប្រែទៅអាត្រង់ហ្នឹង យកត្រចៀកស្តាប់ខ្ញុំបន្តិតទៅ កត់ត្រាទុកទៅ ហើយយកទៅកែទៅ" អាហ្នឹងគេហៅថា ទិតៀន ។ បារាំងគេហៅ *ឡាគ្រីទិច* ដល់គេទិតៀនចប់អ៊ីចឹងអស់គ្រប់គ្នាហើយ ។ កញ្ញាខ្ញុំសូមបន្តឲ្យចប់សិន ។ កាលណាដល់គេទិតៀនចប់អ៊ីចឹងសព្វគ្រប់គ្នាអស់ហើយ បានប្រធានសាខា លេខាសាខាគេសរុប ។ គេឲ្យយើងចាប់អារម្មណ៍ចំណុចណា ក្នុងរយៈកាល១៥ថ្ងៃនេះ សាខា-- ប្រធានសាខា លេខាសាខាគេសរុបហើយ ។ នេះការងាររបស់លេខាសាខា ។

ដូច្នេះ មួយរយៈពេល៣-៤ឆ្នាំនេះ កន្លះខែធ្វើម្តង ខ្ញុំពិបាកនឹងសរុបឲ្យខ្លីពីរ-បីម៉ាត់អំពីគុណសម្បត្តិ និងគុណវិបត្តិរបស់ខ្ញុំណាស់ ។

[១០:០២:៣៥]

**ស៖** តើលោកអាចផ្តល់ឧទាហរណ៍ឲ្យខ្ញុំមួយបានទេ? ថាតើអ្វីដែលលោកបានទិតៀន ឬក៏លោកធ្វើស្វ័យទិតៀនខ្លួនឯង តើអាចផ្តល់ជាឧទាហរណ៍មួយបានទេដែលថាលោកបានដាក់ជូនទៅប្រជុំ ឬក៏បានន័យថាធ្វើស្វ័យទិតៀនឲ្យអង្គប្រជុំដឹងនោះ?

**ឆ៖** ពេលធ្វើស្វ័យទិតៀនឲ្យគេដឹង ខ្ញុំច្រើននិយាយអំពីក្នុងរយៈកាល១៥ថ្ងៃនេះ ខ្ញុំធ្វើល្អបានស្អី? ម៉េចបានជាខ្ញុំធ្វើល្អបានយ៉ាងនេះ? មូលហេតុមកពីខ្ញុំបានរៀនសូត្រមាគ៌ាចេះដឹង ម្លោះហើយខ្ញុំខំអនុវត្តដោយស្មារតីទទួលខុសត្រូវ ។ នេះអំពីគុណសម្បត្តិរបស់ខ្ញុំ ខ្ញុំលើក ។ ដល់កាលណានិយាយអំពីគុណសម្បត្តិក្នុងរយៈកាលនេះ យើងខ្ញុំខ្វះខាតស្អី? ផ្ទាល់ខ្លួនខ្ញុំមិនយកចិត្តទុកដាក់នឹងការងារអប់រំឲ្យបានដិតដល់បានជាយុទ្ធជនខ្ញុំ គេបណ្តោយឲ្យអ្នកទោសរត់រួច ។ អាហ្នឹងរបៀបហ្នឹង ។ ដូច្នេះ ខ្ញុំត្រូវលើកវិធានការកែប្រែយ៉ាងម៉េច? អប់រំយុវជនកម្មាភិបាលឲ្យជ្រៅថែមទៀត ។ នេះសូមលើកឧទាហរណ៍ជូនប៉ុណ្ណេះ ។

[១០:០៤:១០]

**ប្រធានអង្គជំនុំ៖**

មេធាវីក្រុមពីរ ក្រុម៤ មានអ្វីត្រូវសួរទេ? ឬក៏ទុកឱកាស១០មីនុតទៀតនេះទៅមេធាវីក្រុម២និយាយទាំងអស់?

**លោក ហុង គឹមសួន៖**

លោកប្រធាន ខ្ញុំបាទមានសំណួរប្រហែលជា ១០សំណួរដែរ ។

**ប្រធានអង្គជំនុំ៖**

មេធាវីក្រុម២ អស់ពេលហើយ ។ សូមអញ្ជើញមេធាវីក្រុម៤ បន្តសំណួរ ។ មេធាវីក្រុម២ អស់ពេលហើយ អញ្ជើញមេធាវីក្រុម៤ ចាប់ផ្ដើមធ្វើសំណួរ ហើយសូមបញ្ជាក់រំឭកម្ដងទៀតទី១ ចៀសវាងសំណួរច្រំដែល ។ ទី២ សំណួរដែលជាចម្លើយរបស់ជនជាប់ចោទ បានឆ្លើយច្បាស់លាស់ហើយ មិនអនុញ្ញាតឲ្យសួរច្រំដែលទេ លើកលែងតែការបញ្ជាក់ចំណុចណាដែលមិនច្បាស់ប៉ុណ្ណោះ ។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សូមអរគុណលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងសូមគោរពអង្គសវនាការជាទីគោរព ។ ខ្ញុំបាទជាតំណាងឲ្យក្រុម៤ ដែលមានលោក ព្យែរ អូលីវីយេស័រ ដែលជាសហមេធាវីបរទេស ។ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធាន បើសិនជាសំណួរដែលមានការបកប្រែស្ដាប់គ្នាទៅមិនច្បាស់លាស់ទេ ។ ខ្ញុំបាទសូមបញ្ជាក់ឡើងវិញចៀសវាងថា ខ្ញុំបាទទទួលការណែនាំហើយនៅតែសួរសំណួរច្រំដែលបាទ ។ តទៅនេះ គឺខ្ញុំបាទសូមសួរលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ទាក់ទងទៅនឹងការបំភ្លឺខ្លីៗឡើងវិញ ព្រោះតាមការដែលខ្ញុំស្ដាប់អម្បាញ់មិញ លោកបានជម្រាបទៅកញ្ញា មេធាវីទាក់ទងអំពីរឿងថា ការសម្រេចយកបុគ្គិល ឬក៏ការជ្រើសរើសក្មេងដែលមកធ្វើការ គឺលោកធ្វើតាមរយៈឋានានុក្រមគេ មានសួរភូមិ មានឃុំ មានគណៈកម្មការអីនោះ បើសិនសម្រេចខ្លួនឯងខុសនឹងច្បាប់ អ៊ីចឹងមែនទេ? អាហ្នឹងខ្ញុំបញ្ជាក់បន្តិចសិន ។

[១០:០៦:២៨]

**ឆ៖** លោក គឹមសួន យើងជាខ្មែរនិយាយគ្នាស្រួលស្ដាប់ច្បាស់ ។ ឥឡូវខ្ញុំសូមជម្រាប ខ្ញុំចង់បានបុគ្គលិកថ្មី គុណធម៌ដែលខ្ញុំចង់បាន គឺវណ្ណៈភាពល្អ សីលធម៌ស្អាតស្អំ មាតាបិតាសុចរិតរស់នៅជាមួយភូមិឃុំគេចុះ ។ យើងខ្ញុំយកព័ត៌មានហ្នឹងអំពីបុគ្គលិករបស់យើងខ្ញុំ ។ ដល់កាលណាយើងខ្ញុំពេញចិត្តនឹង

បុគ្គលប៉ុន្មាននាក់ហើយ យើងខ្ញុំយកឈ្មោះហ្នឹងទៅស្នើដល់ភូមិភាគនោះ កាលណាភូមិភាគគេសម្រេច គេធ្លាក់មកដល់តំបន់ មកដល់ភូមិឃុំគេបញ្ជូនបុគ្គលិកនេះមកឱ្យខ្ញុំ ខ្ញុំចាប់ផ្ដើមអប់រំទទួលជាបុគ្គលរបស់ខ្ញុំសារថ្មី ។ នេះខ្ញុំជឿថា លោកស្រួលយល់យើងនិយាយគ្នា ។

**ស៖** សូមអរគុណ ។ ហើយខ្ញុំសួរបន្តទៅទៀតទាក់ទងជាមួយនឹងលោក ប្រើពាក្យថា "ខុសនឹងច្បាប់" នោះ ។ អ៊ីចឹង នៅក្នុងចន្លោះពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧១ មកដល់១៧ មេសា ឆ្នាំ១៩៧៥ ដែលអំឡុងពេលគេហៅថា តំបន់រំដោះនោះ លោកជាប្រធាននៅម-១៣ អ៊ីចឹងពេលហ្នឹងគេ-- "គេ" ហ្នឹងខ្ញុំបាទចង់និយាយថា ទោះជាអង្គការ ខ្ញុំក៏មិនទានច្បាស់ដែរ មកដល់ថ្ងៃនេះ រឿងអង្គការ ។ តើថ្នាក់ណាដែលគេចែងច្បាប់ឱ្យលោកអនុវត្ត?

[១០:០៧:៤៩]

**ឆ៖** សូមជម្រាបលោក គឹមសួន ខ្ញុំមិញសូមទោសណា! ខ្ញុំនិយាយភ្លាត់ប្រើពាក្យ "ច្បាប់" មិនមែនច្បាប់ទេ "មាគ៌ា" គោលការណ៍ ។ កាលនោះគេប្រើពាក្យពីរ "មាគ៌ា" ពាក្យ "គោលការណ៍" គ្មានពាក្យថា "ច្បាប់" ទេ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងជា "គោលការណ៍" សូមលោកពន្យល់បន្តិចមក គោលការណ៍ហ្នឹងគេចែងជារៀបឯកសារសរសេរ ដូចថា វាមានចំណុចទី១ ធ្វើអី ទី២ ធ្វើអី អ៊ីចឹងដែរទេ? មានចែងអ៊ីចឹងទេ?

**ឆ៖** ខ្ញុំអរគុណ ។ គោលការណ៍ ខ្ញុំសូមលើកបញ្ហាខ្លះជូន ។

**ស៖** ទាក់ទងនឹងម-១៣ ។

[១០:០៨:២៥]

**ឆ៖** បាទៗ, ម-១៣ វាអត់ឯករាជ្យ ដោយឡែកដាច់ពីគេទេ ។ គោលការណ៍មួយដែលដែល ម-១៣ ត្រូវតែគោរព អ្នកក៏ត្រូវតែគោរព ។ ខ្ញុំលើកជូននឹងជយភណ្ឌ និងយុទ្ធភណ្ឌ ជាកម្មសិទ្ធិរបស់បក្សៗ ស្អីជយភណ្ឌ? គឺរបស់ដែលយើងយកបានពីខ្មាំង ។ ស្អីយុទ្ធភណ្ឌ? អាវុធយុទ្ធភណ្ឌ ជាកម្មសិទ្ធិរបស់បក្សមិត្តអត់ត្រូវរំលោភទេ អត់ត្រូវរក្សាទុកទេ តែរក្សាទុកខុស ។

**ស៖** កន្លែងហ្នឹងខ្ញុំបាទឮៗលោកបានមានប្រសាសន៍ ជម្រាបជូនលោកចៅក្រមកាលពីពីរថ្ងៃមុនម្ល៉េះ ។

[១០:០៩:០០]

**ឆ៖** បាទៗអាហ្នឹងគេហៅថា “គោលការណ៍” ខ្ញុំអត់យកអាពាក្យហ្នឹងមក ដើម្បីពន្យល់អាហ្នឹងឡើងវិញទេ គឺជម្រាបលោកថា អាហ្នឹងគេហៅ “គោលការណ៍” ។ គោលការណ៍ហ្នឹងថ្មី ខ្ញុំទើបនឹងឃើញឯកសារ ក៏ប៉ុន្តែគោលការណ៍ខ្លះវា *ក្លាសស៊ិក* តាំងពីជាតិណាមក ថ្នាក់ក្រោមគោរពថ្នាក់លើទូទៅប្រទេសគោរពមជ្ឈិមបក្ស អាហ្នឹងគោលការណ៍ហ្នឹងវា *ក្លាសស៊ិក* វាមានយូរហែយរួមកហើយ ។ យើងខ្ញុំចូលទៅបក្សត្រូវគោរពគោលការណ៍ហ្នឹង ។

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោក អ៊ីចេះ? អាហ្នឹងខ្ញុំយល់ហើយ គ្រាន់តែថា តើលោកដែលថាគោលការណ៍វាយូរមកហើយហ្នឹង គេចែងសរសេរជាការណែនាំ ចំណុចទី១, ទី២, ទី៣ ឲ្យយើងធ្វើតាមហ្នឹង ឬមួយក៏ការស្តាប់បន្តៗគ្នា?

[១០:០៩:៣៩]

**ឆ៖** ចំណែកគោលការណ៍នេះ វាមានចែង-- គោលការណ៍ដែលខ្ញុំនិយាយមិញ ថ្នាក់ក្រោមគោរពថ្នាក់លើទូទាំងប្រទេសនេះ ។ គោរពមជ្ឈិម បុគ្គលគោរពសមូហភាព វាមាននៅក្នុងលក្ខន្តិកបក្សដែលខ្ញុំរៀន ។

[១០:០៩:៥៤]

**ស៖** សូមអរគុណ ហើយខ្ញុំសូមសួរបន្តបន្ទិចទៀត ។ ទាក់ទងជាមួយនឹងការសាកសួរចម្លើយមនុស្សដែលចាប់បញ្ជូនទៅ ម-១៣ លោកថា វាទាក់ទងគ្នាជាមួយគោលការណ៍អីទាំងអស់ហ្នឹង មិនមែនច្បាប់ទេ ។ អ៊ីចឹងខ្ញុំសូមសួរថា នៅពេលដែលលោកធ្វើការសាកសួរចម្លើយ ព្រោះនៅក្នុងឯកសារថាលោកជំនាញខាងសួរចម្លើយ លោកសួរដោយផ្ទាល់ទូទៅទាំងប្រុសទាំងស្រី ឬសួរតែស្រីដូចលោកលើកអំមិញ?

**ឆ៖** មនុស្សសំខាន់ត្រូវនៅលើដៃខ្ញុំ នេះទី១ គោលការណ៍ទី១ ដែលខ្ញុំអនុវត្ត ។ គោលការណ៍ហ្នឹង រៀបចំដោយខ្លួនឯងនៅក្នុងម-១៣ ទេ ។ មនុស្សសំខាន់នៅដៃខ្ញុំដំបូង ឧទាហរណ៍ TC១ លោកចាំមើលអញ្ជើញមកឥឡូវហើយ ។

**ស៖** ស្គាល់ហើយបាទ ។

[១០:១០:៤៤]

**ឆ៖** ហើយទី២ ជាទូទៅស្រី ខ្ញុំខ្លាចក្មេងៗគេប្រព្រឹត្តសីលធម៌ គឺនៅលើដៃខ្ញុំ ។ ស្រីៗជាទូទៅនៅលើដៃខ្ញុំ ខ្លាចក្មេងៗគេល្មើសសីលធម៌ ។

ទី៣) អ្នកណាដែលខ្ញុំមើលទៅត្រូវដោះលែង ខ្ញុំសួរខ្លួនឯង រៀបចំសំណុំរឿងខ្លួនឯង ដើម្បីទៅអង្គការខាងលើឲ្យបានដោះលែង ។ ហ្នឹងគឺបីហ្នឹងនៅលើខ្ញុំ ។

**ស៖** សូមអរគុណ ហើយខ្ញុំសូមភ្ជាប់នឹងអាចម្លើយរបស់លោក អំមិញហ្នឹងបន្តិចទៀត ។ លោកអ្នកណាដែលជា មនុស្សសំខាន់ ពាក្យថា សំខាន់ហ្នឹង ខាងថ្នាក់លើហ្នឹងអ្នកណា? ថ្នាក់លើហ្នឹង ដូចលោកលើកឧទាហរណ៍អំមិញអ៊ីចឹងថា ជាបក្ស ឬក៏ជាគណៈមជ្ឈិម ឬបងអីណាដែលលោកតែងហៅនោះ?

[១០:១១:៣៣]

**ឆ៖** ថ្នាក់លើសម្រាប់ខ្ញុំកាលនៅ ម-១៣ ថ្នាក់លើផ្ទាល់ៗដែលចាត់ចែងកិច្ចការខាងសន្តិបាលខាងភូមិភាគពិសេសដំបូងមាន បងវន គឺ វន វ៉េត នេះ បន្ទាប់មក--

**ស៖** និយាយជុំវិញ ម-១៣ ។

**ឆ៖** ទេៗ លោក គឹមសួនៗ ការងារមានពីរ ទី១ ការងារបក្ស ដូចខ្ញុំឆ្លើយជាមួយកញ្ញា ស៊ីលឃីស្ទូត ហ្សីនស្គី អំមិញអ៊ីចឹង ។ ការងារបក្សមានប្រជុំគ្នា ១៥ថ្ងៃម្តង អាហ្នឹងការងារបក្ស ទិតៀន ស្វ័យទិតៀនអាហ្នឹងហៅការងារបក្ស ។ មួយទៀត គេហៅថា ការងារសន្តិបាល *ឌីហ្វាស់ហ្វែរ* ។ ខ្ញុំសូមទោសខ្ញុំអត់និយាយបារាំងទៀតទេ ភ្លាត់ៗ ។ ការងារសន្តិបាល គឺការងារទទួលមនុស្សយកមកដាក់គុកសួរចម្លើយ បានចម្លើយយកទៅរាយការណ៍ឲ្យគេ អាហ្នឹងគេហៅ ការងារសន្តិបាល ។ ការងារសន្តិបាលខ្ញុំអត់ឆ្លងបក្សលេខាសាខារបស់ខ្ញុំទេ ។ *(សំឡេងកាត់)* ការងារសន្តិបាលហ្នឹងរបស់ ម-១៣ ខ្ញុំត្រូវឆ្លងកាត់ពីរភូមិ ។ បើមនុស្សរបស់មនុស្សភូមិភាគពិសេស ខ្ញុំត្រូវរាយការណ៍ជូន បងវន ឬ វន វ៉េត ។ បាទបើមនុស្សរបស់ខាងភូមិភាគនិរតីជាទូទៅខ្ញុំជួបតែ ជូ ជេត ហៅ ស៊ី ទេ ខ្ញុំរាយការណ៍ជូនបងស៊ី ឬពេលខ្លះខ្ញុំទៅរាយការណ៍ជូនបង ប៉ាល់ ។

[១០:១២:៥០]

**ស៖** សូមអរគុណ ខ្ញុំសូមសួរបន្តទៅទៀត ។ តើចំណុចសំខាន់ដែលលោកចាត់ទុកថា ជាមនុស្សសំខាន់នៅពេលថ្នាក់លើ ឬក៏ថ្នាក់ណាដែលបញ្ជូនមកលោកនោះ គេមានសរសេរដៅថា ឧទាហរណ៍ព្រោះលោកបានលើកឡើងហើយនោះ អ្នកនេះជាគិញរបស់ លន់ នល់ អ្នកនោះជាខ្មាំងបង្កប់អ៊ីចឹង ។ តើគេមានដៅចំណុចមកឲ្យលោកសួរអ៊ីចឹង ឬស្រេចតែលោកចង់សួរពីចំណុចណាដែលលោកចេះ? ពេលនៅ ម-១៣ ហ្នឹង ។

[១០:១៣:១៧]

**ឆ៖** បាទៗ មនុស្សនៅ ម-១៣ មនុស្សសំខាន់ ខាងភូមិភាគពិសេស ។ ជាពិសេសជាមួយនឹងលោកគ្រូ សុន សេន ខ្ញុំនោះ ច្បាស់លាស់ណាស់ការងារ ។ មិនដូចសង្កត់អានេះ អានេះសំខាន់អ៊ីចេះ ហ្នឹងមេខ្ញុំច្បាស់ ការងាររបស់គាត់ច្បាស់ណាស់ ។ ឯចំណែកខាងភូមិភាគនិរតីវិញ ខ្ញុំក្តាប់ហើយខ្ញុំទៅសុំយោបល់បងស៊ី ព្រោះបង ស៊ី បងស៊ី គាត់នៅប្រចាំនឹងកន្លែងហ្នឹងជាប់ តែខ្ញុំក្តាប់ហើយ ខ្ញុំទៅសុំយោបល់បងស៊ី ។

**ស៖** សូមអរគុណ ។ អ៊ីចឹងខ្ញុំសូមបន្តទៅទៀត រាល់ការសាកសួរដែលលោកចាត់ទុកថា កាលនោះ គេហៅ អ្នកទោស ឬខ្មាំងនោះ រាល់ការសាកសួរនោះ តើចេញពីឆន្ទៈរបស់លោកចង់សួរឲ្យស្រាលឲ្យធ្ងន់ នៅលើលោកមែនទេ?

**ឆ៖** លោកនិយាយ លោកមានប្រសាសន៍វាប៉ះត្រូវនឹងពាក្យខ្ញុំហើយ ។ ប៉ុន្តែខ្ញុំជម្រាប កាលណាឃើញសំណុំរឿងអ៊ីចឹង ចិត្តខ្ញុំមានគំនិតមួយចង់លែងឲ្យបានច្រើន ។ ដូច្នេះ ធ្វើម៉េចដោះលែងបានខ្ញុំរកច្រកហើយ ឲ្យតែមានប្រហោងចេះតែរកច្រកហើយ ។ ដូចរឿងករណី ហាម អ៊ិន លោកក្តាប់សំណុំរឿងនេះបានហើយ ។ ហាម អ៊ិន មកគ្នា៥នាក់ ខ្ញុំឃើញ៤នាក់ អត់មានច្រកសម្រាប់សុំឲ្យរួចខ្លួនទេ មានឃើញតែ ហាម អ៊ិន ម្នាក់ដោយយកលេសឪពុកគាត់ជាបក្ខជនជើងចាស់ ។ ឪពុកគាត់ជាគណៈកម្មាធិការឃុំអមលាំង ឪពុកគាត់ក្រជាងគេ ឪពុកគាត់ស្លូតជាងគេ ខ្ញុំចាប់មួយហ្នឹង យកទៅរាយការណ៍សុំយោបល់បងស៊ី ថាសុំដោះលែង ។ នេះវាច្បិច ចេះតែច្បិចរកចំណុចដើម្បីដោះលែងហើយ ។

[១០:១៥:០០]

**ស៖** អរគុណ។ អ៊ីចឹងសូមបន្តបន្តសំណួរទៀត ។ រាល់ពេលការសាកសួរហើយ លោកថានៅម-១៣“ក” មិនមានការដោះលែងទេ អ៊ីចឹងណ៎ា។ មុននឹងយកទៅកម្ទេច ឬដែលសព្វថ្ងៃគេហៅថាសម្លាប់នោះ លោកមានសម្រេចប្រជុំជាមួយគណៈកម្មាធិការ ឬថ្នាក់លើរបស់លោកដែរឬទេ?

**ឆ៖** ម្សិលមិញ ដូចខ្ញុំឆ្លើយបញ្ហាហ្នឹងជាមួយនឹងលោកចៅក្រម រ៉ូប៊ឺត ពើទីត ។

កាលណាខ្ញុំសួរចម្លើយចប់ ខ្ញុំយកទៅចម្លើយហ្នឹង ទៅរាយការណ៍ជូនមេ ។ បើកាលណាគេចិត្តអឺស! យកទៅចុះ អាហ្នឹងស្វ័យប្រវត្តិ ខ្ញុំបញ្ជាកូនចៅឲ្យគេយកចេញហើយ ។

**ស៖** បាទ, អរគុណ ដោយសារអម្បាញ់ហ្នឹង វាទាក់ទងជាមួយនឹងការសម្រេច ។

មួយទៀត រាល់ការប្រជុំ អំមិញលោកបានវែកញែកច្បាស់ ជូនអង្គសវនាការហើយថា ប្រជុំបក្សយ៉ាងម៉េច ប្រជុំបក្ខជនក្រុមអីម៉េចនោះ ខ្ញុំមិនសូវយល់ទេ រឿងផ្នែកកុម្មុយនីស្ត ។

តែខ្ញុំសួរថា ពេលអ្នកទោសរត់អំមិញគ្រាន់តែផ្នែកមួយណ៎ា! ដែលលោកមានប្រសាសន៍ថានៅភ្នំពីស ទៅធ្វើស្រែ ។ ហើយខាងកញ្ញាសួរថា មានរត់រួច ប្រហែលជា៣០នាក់នោះ ។ លោកថាកាលណោះ ទៅធ្វើស្រែ ។ អ៊ីចឹង តើការរត់រួចពេលនោះមានចាប់បានមកវិញទេ?

**ឆ៖** សុំទោស, កាលនុ៎ង អត់មានចាប់បានអីម៉ាគ្រាប់ ។ មានតែគ្នាយើងរបួស មានតែកងការពារខ្ញុំរបួស មិត្តប៉ុន ក៏របួស ខ្មោចមិត្តមាស ក៏របួស មិត្តម៉ៅ មួយទៀតក៏របួសដែរ ។

**ស៖** ខ្ញុំសុំសួរចេះថា...

**ឆ៖** បាទ ។

**ស៖** ពីភ្នំពីស ?

**ឆ៖** អត់ចាំ ។

[១០:១៦:២៦]

**ស៖** ពីភ្នំពីស ហ្នឹងមកដល់ បើនិយាយមកខាងឧដុង្គក៏ដោយ មកដល់ខាង កំពង់ស្ពឺ ក៏ដោយ ខាងណាដែលចម្ងាយឆ្ងាយជាង?

**ឆ៖** ខ្ញុំមិនដឹងទេណ៎ា! ដូចខ្ញុំឆ្លើយជូនលោកផានិតម្សិលមិញអ៊ីចឹង ។

ពីឧដុង្គមកច្បារមន ក៏ខ្ញុំមិនដឹងចម្ងាយ ហើយពី-- *(សុំទោស)* ពីអមលាំងមកច្បារមនក៏ខ្ញុំមិនដឹងចម្ងាយ ពីអមលាំងមកឧដុង្គ ក៏ខ្ញុំអត់ដឹងចម្ងាយដែរ ។ ដូចខ្ញុំឆ្លើយ ជូនលោក គឹមសួន ម្សិលមិញ ។

**ស៖** ខ្ញុំចង់សួរ--

**ឆ៖** ក៏ប៉ុន្តែ--

**ស៖** ខ្ញុំចង់សួរឲ្យជាក់លាក់អំពី តើ--

**ឆ៖** បាទៗ--

**ស៖** ខ្ញុំចង់សួរឲ្យជាក់លាក់អំពី ថាតើប៉ុន្មានគីឡូទេ? យើងគ្រាន់តែ ឆ្ងាយឬតិចជាងប៉ុណ្ណឹង ។

**ឆ៖** បាទ, តែតាមពិតជាក់ស្តែង ពួកជនរងគ្រោះទាំងអស់នោះ ជាង៣០នាក់ ដែលរត់ហ្នឹងណ៎ា ។ គេរត់សំដៅច្បារមន ។

[១០:១៧:០៥]

**ស៖** បាទ, អរគុណ ។

តើជំរំ ឬក៏កន្លែងគេហៅថា "ភ្នំពីស" ដែលលោកថាអ្នកទោសរត់រួចហ្នឹង និងកន្លែងម-១៣ កន្លែងឃុំឃាំងហ្នឹង បើយើងនិយាយវិញ កន្លែងម-១៣ នេះមកខាងតំបន់លោក លន់ នល់ វាជិតជាងពីភ្នំពីស ឬក៏វានៅឆ្ងាយជាង?

ចង់និយាយថា ភ្នំពីស "ម-១៣" "ច្បារមន" ចង់និយាយអ៊ីចឹង ។ តើពីរនេះម-១៣ និងភ្នំពីស នេះ មួយណាដែលយើងថា រយៈចម្ងាយវាជិតជាងមកកំពង់ស្ពឺ ឬទៅឧដុង្គ?

**ឆ៖** សូមជម្រាបលោក គឹមសួន អាៗភ្នំពីស ឬក៏ខ្ញុំហៅថាឲ្យចំទីតាំងរបស់គេ ខ្ញុំហៅថា "ទួលស្វាយមាស" ឬក៏ "តាលាវ" នេះ គឺជាទីតាំងរបស់មន្ទីរម-១៣ ។ ទីតាំងរបស់មន្ទីរម-១៣ គឺភ្នំនៅខាងជើងភ្នំពីស ឬក៏នៅលើទួលមួយ គេហៅថា "ទួលស្វាយមាស" ឬក៏ "តាលាវ" ។

**ស៖** អរគុណ ។ សំណួររបស់ខ្ញុំ សួរចុងក្រោយសួរថា ដែលលោកបានធ្លាប់មានប្រសាសន៍ នៅក្នុងកំណត់ហេតុរួចហើយ ។ ការដែលលោកថា បើលោកមានចិត្តមួយមិនចង់ធ្វើទេ ការងារសន្តិបាលនោះ ទោះវាមើលទៅវាថាមានការកម្ទេចសម្លាប់ សូម្បីតែសំណួរ អ្នកទោសក៏លោកចាត់ថា វាមិនមែនជាការសារភាពត្រឹមត្រូវដែរ ពីមុនណ៎ា ។

ខ្ញុំសួរថា លោកមានចិត្តដកខ្លួនចូលមកខាងតំបន់លោក លន់ នល់ វិញ តែទាក់ទងជាមួយនឹងឆ្ងាយ និងការស្គាល់មុខ ។ តើលោកអាចបំភ្លឺកន្លែងហ្នឹងតិចបានទេ? ព្រោះអាហ្នឹង ខ្ញុំអាចឮលោកបានជម្រាបច្រើនហើយ គ្រាន់តែចង់ដឹងកន្លែងហ្នឹងតិចទេ?

**ឆ៖** លោក គឹមសួន, ខ្ញុំចង់បញ្ជាក់បន្តិច ។ ចម្លើយរបស់ខ្ញុំ ខ្ញុំចង់ឲ្យលោកអានម្តងទៀត ។ ខ្ញុំចង់ដកខ្លួនពីមន្ទីរនគរមែន ក៏ប៉ុន្តែនិយាយអំពីលទ្ធភាពរត់មកនេះ ខ្ញុំរត់អត់រួចទេៗ ។

**ស៖** ហេតុផល? សុំៗទោស ។

**ឆ៖** ហេតុផលច្បាស់លាស់ហើយ ម្ស៊ៀលមិញ សហព្រះរាជអាជ្ញាលោកសួរខ្ញុំ ទេអ្នកណាអ៊ីចេះចៅក្រមមិនដឹងទេ ។

អ្នកឯងដើរមានលិខិតដើរផ្លូវនៅនឹងខ្លួនទេ ខ្ញុំថាមាន ។ ខ្ញុំដើរនៅក្នុងដីរបស់និរតី លិខិតដើរផ្លូវរបស់ខ្ញុំមាន ខ្ញុំដើរនៅក្នុងដែនដីភូមិភាគពិសេសលិខិតដើរផ្លូវរបស់ខ្ញុំមាន ។

ហ្នឹង! ខ្ញុំរត់អត់រួចទេ ។ ហើយដាក់ស្ដែងម្សិលមិញ ដូចជាលោកចៅក្រម ឡាវែន៍ សួរខ្ញុំ ដែលខ្ញុំនិយាយអំពីខ្ញុំយល់អំពីរឿង លន់ នល់ យ៉ាងម៉េច អំពីម្ដាយខ្ញុំគាត់ទៅទាក់ទងសុំការដោះលែងពី លន់នល់យ៉ាងម៉េចហ្នឹង ខ្ញុំមាននិយាយច្បាស់ អាហ្នឹងវាបំភ្លឺខ្ញុំបានហើយ ។

**ស៖** ស្ដាប់ហើយ កន្លែងហ្នឹង បាទ ។

**ឆ៖** បាទៗ ។

[១០:១៩:៤៨]

**ស៖** សួរសំណួរតែមួយទៀតទេ មុនពេលបិទ ម-១៣ ខ្ញុំមើលនៅក្នុងឯកសារដែលលោកឆ្លើយជាមួយសហចៅក្រមអង្កេត ថាវាមានសល់មនុស្សជាង១០នាក់ បញ្ជូនទៅកម្មេច និងបញ្ជូនទៅតំបន់២៥អ៊ីចេះ មិនដឹងទេ?

តើមានអ្នកទោស ដែលខាងលោកចាត់ទុកថាខ្មាំងនោះ បញ្ជូនមកចូលស-២១ ទាក់ទងគ្នាដែរឬទេ?

**ឆ៖** អត់ទេៗ អត់នាំពី ម-១៣ មក ស-២១ ទេ ។ ម-១៣ ចប់ត្រឹមថ្ងៃ៣០ មេសា ។

**ស៖** សូមអរគុណ, លោកចៅក្រម ។ ខ្ញុំបាទអស់សំណួរ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅទៀតនេះ សូមប្រគល់វេទិកានេះ ជូនដល់មេធាវីការពារក្ដី ។

តើលោកមានសំណួរអ្វីសួរដល់ជនជាប់ចោទទេ ពាក់ព័ន្ធជាមួយនឹងអង្គហេតុ ម-១៣ នេះ?

ប្រសិនបើមានសូមអញ្ជើញ ។

[១០:២១:០៤]

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមលោកបញ្ជាក់ឲ្យច្បាស់មើល ។ តើនៅក្នុងម-១៣ នេះលោកមានសិទ្ធិចាប់អ្នកនេះអ្នកនោះយកមកបញ្ចូល ម-១៣ ឬអត់ទេ?

**ជនជាប់ចោទ៖**

**ឆ៖** និយាយពីសិទ្ធិដើរចាប់មនុស្ស គ្មានទេ ។ គោលការណ៍ដែលបង វន គាត់ណែនាំមានបី ។

គោលការណ៍ទីមួយ៖ ដាច់ខាត់មិនឲ្យចាប់មនុស្ស ។ ម-១៣ ត្រូវរង់ចាំទទួលតែមនុស្សដែលគេបញ្ជូនមកបានហើយ នេះគោលការណ៍ទីមួយ ។

គោលការណ៍ទីពីរ៖ មិត្តកុំប៉ះពាល់ជយភណ្ឌឲ្យសោះ ។

គោលការណ៍ទីបី៖ មិត្តកុំប៉ះពាល់នារីឲ្យសោះ ។ នារីកូនចៅអ្នកភូមិក៏ដោយ នារីជាអ្នកទោសដែលនៅជិតនឹងដៃយើងក៏ដោយ ។

ខ្ញុំមិនប៉ាានសោះ ខ្ញុំខំគោរពគោលការណ៍បីហ្នឹង ។ ខ្ញុំជឿថា ខ្ញុំអាចរស់បាន ទល់សព្វថ្ងៃនេះ ក៏ដោយសារ ខ្ញុំខំគោរពគោលការណ៍បីហ្នឹងដែរ ។

**ស៖** សំណួរទីពីរ តាំងពីអ្នកឯងនៅជាប្រធានម-១៣ តើមានដែលសម្លាប់មនុស្សដោយផ្ទាល់ដៃអ្វើ?

**ឆ៖** ខ្ញុំសុំនិយាយឲ្យវែងតិចទៅចុះ ។ នៅពេលដែលបង ឆាយ គឹមហ៊ គាត់ណែនាំខ្ញុំ ខ្ញុំថាខ្ញុំមិនប៉ាានសម្លាប់មនុស្សទេ ។ បង គឹមហ៊ គាត់ថា អាហ្នឹងជាចំណុចខ្សោយរបស់បញ្ញាជន ហើយជាពិសេសចំណុចខ្សោយរបស់មិត្តហើយ ។ ត្រូវរៀនសូត្រពីកសិករ ទុកឲ្យកសិករគេធ្វើចុះ មិត្តចាំតែបញ្ជាឲ្យគេទៅបានហើយ ។

ដូច្នេះ ជាគោលការណ៍ គឺវានៅក្នុងកន្លែតហ្នឹង ច្បាស់លាស់ គោលការណ៍វានៅត្រង់បញ្ហានេះច្បាស់លាស់ ។ ឯចំណែក ក្នុងការអនុវត្តវិញ ខ្ញុំពិតជាបានណែនាំគេអំពីយុទ្ធវិធីសម្លាប់ ។ ខ្ញុំពិតជាបានប្រគល់ឈ្មោះឲ្យគេតាមគោលការណ៍ ដូចខ្ញុំឆ្លើងឆ្លើយជាមួយលោក គឹមស្វន អំមិញអ៊ីចឹង ឲ្យតែកាលណាសួរចប់ មេថា អឺ! ពេញចិត្តហើយ ។ ខ្ញុំឲ្យកូនចៅយកចេញទៅ ។

ដូច្នេះ ថាឲ្យសម្លាប់ផ្ទាល់ដៃ សុំនិយាយម៉ាត់ម្តងទៀត ខ្ញុំនិយាយច្រើនដងហើយ សុំនិយាយជម្រាបមេធាវីម្តង ថាអត់ដែលសម្លាប់មនុស្សដោយផ្ទាល់ដៃទាល់តែសោះ ។

[១០:២៣:៣២]

**ស៖** អត់បាន អត់ដែលបានសម្លាប់មនុស្សដោយផ្ទាល់ដៃទេ ចុះថ្នាក់លើគេប្រគល់មកជាប្រធានម-១៣ តើថ្នាក់ប្រគល់សិទ្ធិឲ្យលោកសម្លាប់មនុស្សទេ?

**ឆ៖** អារឿងមនុស្ស ដែលគេសម្រេចចាប់ ខាងម-១៣ ត្រូវតែដាក់គុកឲ្យគេ សួរចម្លើយឲ្យគេឲ្យបានហើយកម្ទេចឲ្យគេ នេះជាគោលការណ៍ ។ ក៏ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង បានចម្លើយហើយខ្ញុំរត់ទៅសួរគេ គេថាឲ្យកម្ទេច អាហ្នឹង ខ្ញុំក៏កម្ទេចទៅ ។ បើថា អេស៎! កុំអាល ឌុច សួរអានេះតិចទៀតមើល ខ្ញុំក៏រត់មកឲ្យគេសួរតទៅទៀត ដល់កាលណាគេចិត្តហើយ គេថាឲ្យកម្ទេច ក៏កម្ទេចទៅ នេះក្នុងន័យអនុវត្តជាក់ស្តែង ។

**ស៖** អ៊ីចឹងបានចម្លើយហើយ លោកអត់មានទៅ-- ឲ្យបញ្ជូនទៅឲ្យគេសម្លាប់ភ្លាម ឲ្យកម្ទេចភ្លាមទេទាល់តែសួរយោបល់គេសិន ។

**ឆ៖** សិន, ជាឧទាហរណ៍ លោកមេធាវីអាចឃើញស្រាប់ហើយ ក្រោយ១មករា ដែលខ្ញុំដាច់ខ្សែពីខាងលើ ខ្ញុំនៅសល់អ្នកទោសប្រហែលជា១០នាក់ ខ្ញុំរក្សាទុកនៅហ្នឹងរហូត ដល់ថ្ងៃ៣០ មេសា ដែលខ្ញុំជួបមេ មេឲ្យបែងចែកជាពីរ ខ្ញុំគោរពតាមការហ្នឹងបែងចែកជាពីរ ។

ដូច្នេះ មិនប៊ានធ្វើខុសពីរឿងអីៗអ៊ីចឹងទេ ។ ដូច្នេះ សួរចម្លើយហើយហ្នឹង វាទាល់តែគេ *អូខេ* មកបានៗខ្ញុំយកចេញនេះតាម ។

[១០:២៥:០១]

**អ្នកបកប្រែ៖**

សុំអភ័យទោស, លោកចៅក្រម សុំឲ្យជនជាប់ចោទ និងមេធាវី ធ្វើការផ្អាកបន្តិច ដើម្បីរង់ចាំឲ្យអ្នកបកប្រែ បកប្រែទាន់នៅពេលគាត់បញ្ចប់ឃ្លារបស់គាត់ ។

**ប្រធានអង្គជំនុំ៖**

សុំៗមានការពន្យឺតបន្តិច ដោយសារតែមានការ ការបកប្រែមានបញ្ហា ដោយសារគាត់ស្តាប់ហើយ ឆ្លើយភ្លាមទៅ ការបកប្រែមិនទាន់ ។

សុំៗពន្យឺត បង្អង់ នៅពេលដែលឆ្លើយណ៎ា លោកជនជាប់ចោទ ។

សូមអញ្ជើញបន្តទៀត ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** អ៊ីចឹង មតិទូទៅ គេតែងឡើងថា លោកជាប្រធានគុក លោកសម្លាប់ច្រើនណាស់ ។

លោកព្រមទទួលទេ?

**ឆ៖** ក្នុងឋានៈជាប្រធានមន្ទីរ១៣ ក៏ដោយ ក្នុងថ្នាក់ជាប្រធានមន្ទីរស-២១ ក៏ដោយ ។

ឧក្រិដ្ឋកម្មគ្រប់បែបយ៉ាង ទាំងដាក់ឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ជាទីបំផុត ទៅលើមនុស្សរួមទាំងស្ត្រី និងកុមារផង រហូតទៅដល់សម្លាប់ទាំងស្ត្រី ទាំងកុមារផង ។

ខ្ញុំទទួលទាំងអស់ បើគ្មានខ្ញុំនៅហ្នឹងនេះ ជាអ្នកបញ្ជាឲ្យអនុវត្តគោលការណ៍ឲ្យបានហ្មត់ចត់ទេ ។ អាហ្នឹងគេផ្តាស់អ្នកផ្សេងទៀតក៏ពិតមែន ។ ក៏ប៉ុន្តែនៅក្នុងទីនោះ ខ្ញុំជាបង្គោលឲ្យគេទាំងអស់គ្នាអនុវត្តគោលការណ៍នេះ ។

ដូច្នេះ ឧក្រិដ្ឋកម្មនេះវានៅលើខ្ញុំ អត់ផ្ដើយដាក់អ្នកណាទេ ។ ពិតជានៅលើខ្ញុំហើយ ។

**ស៖** បាទ, សូមអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ហ្សង់ស្វ័រ រូ មានសំណួរអ្វី ចង់សួរដល់ជនជាប់ចោទថែមទៀតទេ?

សូមអញ្ជើញ បាទ ។

[១០:២៦:៥៨]

**សួរដោយលោក ហ្សង់ស្វ័រ រូ៖**

អរគុណ ។

លោក ឌុច នៅពេលដែលលោក ឡាវ៉ែន៍ បានចាប់ផ្ដើមតាំងសំណួរជូនលោក យើងបាននិយាយបន្តិចអំពីបក្សកុម្មុយនីស្ដកម្ពុជា ហើយនិងការចូលរួមរបស់លោកនៅក្នុងបក្សនេះ។

**ស៖** ដូច្នេះ ខ្ញុំចង់ឲ្យលោក ធ្វើការពន្យល់ជូនយើងខ្ញុំ នៅក្នុងបក្សកុម្មុយនីស្ដកម្ពុជានេះ ថាតើមានន័យយ៉ាងម៉េចចំពោះពាក្យថា “សម្ងាត់”នោះ? ថាតើលោកធ្វើការយ៉ាងម៉េច? ដោះស្រាយយ៉ាងម៉េចចំពោះបញ្ហាសម្ងាត់ នៅពេលដែលលោកធ្វើការនៅម-១៣ និងនៅស-២១ ថាតើគោលការណ៍នៃពាក្យថា “សម្ងាត់” នេះនៅក្នុងបក្សកុម្មុយនីស្ដកម្ពុជា មានន័យយ៉ាងម៉េច?

**ជនជាប់ចោទ៖**

**ឆ៖** ខ្ញុំតាំងពីចូលធ្វើបដិវត្តន៍មក គេអប់រំឲ្យរក្សាការសម្ងាត់ ។

ឧទាហរណ៍ យើងទៅបាចត្រាក់ ទោះបីគេប៉ាន់ប្រមាណត្រូវថាយើងអ្នកបាចក៏ដោយ ក៏យើងមិនត្រូវដើរអួតប្រាប់គេថាខ្ញុំអ្នកបាចទេ នេះទីមួយ។ ទីពីរ តើខ្សែបក្សរបស់អ្នកឯងជាប់នឹងអ្នកណា? អ្នកណានៅពីលើអ្នកឯងខាងការងារបក្ស? មិនត្រូវប្រាប់អ្នកណាទេ ។ អ្នកណានៅពីក្រោមអ្នកឯង? ក៏មិនត្រូវប្រាប់គេដែរ ។ ខ្ញុំចេញពីស្លាន់ ការងារបក្សនៅស្លាន់នៅតែដើរ ខ្ញុំមានអ្នកបន្តវេន តែខ្ញុំអត់និយាយឈ្មោះអ្នកណាទេ ។ ការងារនៅម-១៣ ស្អែក ឧបមាថា៥ថ្ងៃទៀត ចាប់ កុយ ធួន ហើយ *(សុំទោស)* ខ្ញុំនិយាយហ្នឹងហួសហើយ ។ ឧទាហរណ៍ គេឲ្យឈ្មោះ ពត ប្រាជ្ញ សុន ហៅ ពត មកឲ្យខ្ញុំសួរចម្លើយ តាម៉ុក ស្ដីឲ្យខ្ញុំយ៉ាងម៉េច ក៏ខ្ញុំអត់ត្រូវប្រាប់អ្នកណាដែរ ។

[១០:៣០:១៥]

ហ្នឹងខ្ញុំសម្លាប់អ្នកណា? បានន័យថា ឲ្យគេសម្លាប់អ្នកណា? ប៉ុន្មាននាក់? កប់ត្រង់ណាក៏មិនត្រូវនិយាយត្រង់ណាដែរ ។ ឧទាហរណ៍មួយទៀត មិត្តសំ ប្រធានមន្ទីរ-២០១ មកឲ្យខ្ញុំរង់ចាំចាប់មនុស្សម្នាក់ ។ ខ្ញុំចេញទៅរង់ចាំ ខ្ញុំអត់ប្រាប់អ្នកណាក្រៅអំពីកម្លាំងដែលខ្ញុំត្រូវនាំចេញទៅចាប់ហ្នឹងទេ ។ ដូច្នេះអ្នកណាមើលមក ក៏ឃើញខ្ញុំនាំកម្លាំងទៅចាប់ ខ្ញុំចាប់ ក៏ប៉ុន្តែខាងលើគេសម្រេចរួចទៅហើយ ។

ដូច្នេះ ការធ្វើរក្សាការសម្ងាត់បែបនេះ យើងបានលាក់បានអ្នកសម្រេច យើងលាក់បានគ្រប់កិច្ចការងារទាំងអស់ ។ ខ្ញុំឮពាក្យស្លោកមកក្រោយ តែខ្ញុំមិនរៀនទេហ្នឹង ។ គេថា "លាក់ខ្លួសរស់បានយូរ" ឬក៏គេហៅថា "សម្ងាត់បួនមិន" មិននិយាយ មិនដឹង មិនឃើញ មិនឮ ។ ដូច្នេះគេឲ្យយើងខំរក្សាការសម្ងាត់គ្រប់សកម្មភាពទាំងអស់បែបនេះ ។ សូម្បីតែកន្លែងកប់សាកសពរបស់ម-១៣ហ្នឹងក៏ដោយក៏មិនឲ្យអ្នកណាគេទៅអើតដែរ ។

ខ្ញុំបានជម្រាបលោកសហព្រះរាជអាជ្ញាម្សិលមិញហើយ ខ្ញុំមានការទាក់ទងរាប់អានគ្នា ជាមនោសញ្ចេតនា-- ខ្ញុំបានរាប់អានជិតស្និទជាមួយនឹងប្រធានភូមិ ។ មែនប្រធានភូមិនៅជុំវិញហ្នឹង គេឲ្យសុខខ្ញុំ ខ្ញុំរាប់អានគេ ។ ដូច្នេះ ការងារគេៗផ្សេង ការងារគេៗដឹង ការងារខ្ញុំ ខ្ញុំដឹង ក៏ប៉ុន្តែ មនោសញ្ចេតនារាប់អានគ្នា ។ ការងាររាប់អានគ្នា ខ្ញុំរាប់អានគ្នា គោរពគ្នា យកអាសារគ្នាក្នុងឋានៈជាអ្នកបដិវត្តន៍ដូចគ្នា ។ ដូច្នេះសរុបមកវិញ យើងខ្ញុំរក្សាសម្ងាត់គ្រប់បញ្ហា ។

គ្រប់ការងារទាំងអស់ស្ថិតនៅក្នុងសម្ងាត់ ។ មានពាក្យស្លោកមួយទៀត គេនិយាយថា "រក្សាសម្ងាត់បាន ជ័យជម្នះហាសិបភាគរយហើយស្រេច" ។

[១០:៣៥:១៤]

**សៈ** លោកបាននិយាយថា នៅពេលដែលអ្នកយាមថ្មីមក ម-១៣ លោកធ្វើការអប់រំអំពីបញ្ហានយោបាយ ។ ថាតើនៅពេលនោះលោកបានបង្រៀនពួកគេ អំពីបញ្ហាសម្ងាត់និងគោលការណ៍ដែរ ឬទេ? ហើយលោកបានប្រាប់គេដែរ ឬទេនៅពេលមានការរំលោភ? ឬក៏បំពានទៅលើសម្ងាត់នេះពួកគេនឹងទទួលទណ្ឌកម្ម?

**ឆៈ** សម័យនោះ មូលដ្ឋានចាស់ដូចនៅអមលាំង អំពីការលាក់ការណ៍សម្ងាត់នេះគ្រប់គ្នា ។ ទីតាំងរបស់ម-១៣ ប្រជាជននៅអមលាំងស្គាល់ហើយ ។ មុខខ្ញុំ ឈ្មោះខ្ញុំ ប្រជាជននៅអមលាំង នៅភូមិជុំវិញនុ៎ង ស្គាល់ទាំងអស់ គេស្គាល់ទាំងអស់ ។ តែគេមិននិយាយ មិនប្រាប់អ្នកណា ។ នេះខ្ញុំនិយាយអំព លក្ខណៈរួមដែលប្រជាជនយើង ខ្ញុំដឹង ។

ដោយឡែកសំណួររបស់ៗលោកមេធាវីសួរថា យុទ្ធជន ដែលខ្ញុំយកមកធ្វើកងការពារ តើខ្ញុំអប់រំទេ?

មុននឹងអប់រំអី? ត្រូវអប់រំអំពីការសម្ងាត់ហ្នឹងជាការចាំបាច់ ។ អប់រំជញ្ជាំមួយថ្ងៃ ហើយមួយថ្ងៃទៀត មួយអាទិត្យហើយ មួយអាទិត្យទៀត រហូត ។ ធម្មតាតាមពិសោធន៍របស់ខ្ញុំ អាការសម្ងាត់នេះ ទោះបីមានលក្ខណៈវា-- ទោះបីមានលក្ខណៈ*ក្លាសស៊ិក*យ៉ាងនេះក៏ដោយ ក៏ត្រូវតែរំឭកជាប់ អប់រំជាប់ បើមិនដូច្នេះទេៗ វារសាប់រសាយ វាហើរ ។

[១០:៣៩:០៣]

**ស៖** ខ្ញុំអាចនិយាយថា នៅក្នុងបក្សពីលើដល់ក្រោមនៅក្នុងឋានានុក្រមនេះ អ្នករាល់គ្នាត្រូវតែរក្សាការសម្ងាត់ ហើយអ្នករាល់គ្នាបានដឹងថា ប្រសិនបើគាត់រំលោភទៅលើការណ៍សម្ងាត់នេះ គឺជីវិតរបស់គាត់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ។ ដូច្នេះ នេះជាចម្លើយមួយដែលលោកឆ្លើយត្រឹមត្រូវដែរឬទេ?

**ឆ៖** នេះជាការពិតៗ ។

**ស៖** លោកតែងតែ--យើងជារឿយៗនិយាយចំពោះមុខតុលាការនេះថា “លោកទទួលការកម្ទេចលោកគោរពបញ្ជាពីថ្នាក់លើ” ខ្ញុំអាចសន្និដ្ឋានពីចម្លើយនេះថា នៅក្នុងបក្ស អ្នករាល់គ្នា គឺគោរពបញ្ជាពីថ្នាក់លើចំពោះតួនាទីរបស់គាត់នៅក្នុងឋានានុក្រម ហើយអ្នកដែលមិនគោរពបញ្ជារបស់ថ្នាក់លើ គឺគាត់នឹងជួបបញ្ហាជីវិតរបស់គាត់ស្ថិតនៅក្នុងគ្រោះថ្នាក់?

**ឆ៖** ត្រូវហើយ នេះក៏ជាការពិត ដែលអ្នកណាក៏គេមើលឃើញអ៊ីចឹង ហើយលោកមេធាវីក៏អាចមានប្រសាសន៍អំមិញរបៀបហ្នឹង ។

[១០:៤០:៣៩]

**ស៖** លោកបាននិយាយថា ខ្ញុំទទួលខុសត្រូវជូន វន វ៉េត ខ្ញុំរាយការណ៍ជូន វន វ៉េត ។ ថាលោកនិយាយថា វន វ៉េត ខ្លួនឯង ក៏គោរពថ្នាក់លើដែរ ឬក៏យ៉ាងម៉េច? លោកជឿដែរឬទេថា វន វ៉េត បន្ទាប់មកស្លាប់នៅស-២១ នេះ គឺដោយតែគាត់មិនគោរពបញ្ជារបស់ថ្នាក់លើរបស់គាត់ឬយ៉ាងម៉េច? តើវាត្រឹមត្រូវដែរឬទេក្នុងការនិយាយដូច្នេះ?

**ឆ៖** ចំពោះ បងវន ខ្ញុំមិនដែលគាត់ល្មើសនឹងបញ្ជារបស់បង ប៉ុល ទេ ។ ខ្ញុំបាននិយាយអំពីការជជែកគ្នារវាង បងម៉ុក ហើយនិង បងវន ក្នុងករណីដោះលែង TC១ ។ វាបង្ហាញឲ្យឃើញថា វន វ៉េត ចេញមុខការពារសេចក្តីសម្រេចរបស់លេខាបក្ស ។ គាត់ចេញមុខការពារសេចក្តីសម្រេចចិត្តរបស់លេខា

បក្សយ៉ាងនេះ គេហៅថា "គោរពថ្នាក់លើ" ហើយ ។ នៅពេលដែល បងវន គេចាប់ ខ្ញុំមិនបានកំណត់មូលហេតុអីច្បាស់លាស់ទេ ដូចខ្ញុំបានជម្រាបលោកចៅក្រមស៊ើបអង្កេតរួចហើយ ។ នៅពេលដែលខ្ញុំចូលទៅជួប បងវន នៅពេលដែលគេចាប់ហើយមកភ្លាម ដើម្បីសុំខមាទោសគាត់ផង ហើយសុំយោបល់គាត់ផង ។ ពេលហ្នឹង បងវន ថា បងប៉ុល ទៅត្រដេវរិច យកជើងទ្រមេឃ អ្នកណាក៏គាត់មិនទុកចិត្តដែរ ។

**ស៖** សូមអភ័យទោស នៅពេលដែលយើងនិយាយអំពី បងប៉ុល ។ លោកសំដៅលើ ប៉ុល ពត ឬយ៉ាងម៉េច?

[១០:៤៥:១០]

**ឆ៖** ខ្ញុំសូមតទៅទៀត។ ខ្ញុំសូមតទៅទៀតថា ការចាប់ វន វ៉េត នេះ ដោយសារការសង្ស័យរបស់ ប៉ុល ពត ។ ខ្ញុំមិនបានកំណត់ថា តើមកពី បងវន គាត់ល្មើសវិន័យប៉ុន្មានដង? ល្មើសសេចក្តីសម្ងាត់ប៉ុន្មាន-- អ៊ូនេះ! ល្មើសមិនព្រមគោរព បងប៉ុល ប៉ុន្មានដង? ខ្ញុំអត់ដឹងទេ ។ ក៏ប៉ុន្តែ គាត់ល្មើសរហូតដល់ធ្វើឲ្យគេមិនទុកចិត្ត ។ សរុបមក បាតុភាពល្មើសវិន័យសុទ្ធតែនាំទៅរកសេចក្តីស្លាប់ ។ បាតុភាពល្មើសមិនគោរពខាងលើសុទ្ធតែនាំទៅរកសេចក្តីស្លាប់ ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានសំណួរអីនៅច្រើនទៀតទេ? នៅមានសំណួរច្រើនទៀតទេ? ឥឡូវនេះអង្គជម្រះប្រកាសសម្រាកម្ភៃមីនុត ។ ម៉ោង១១:០៥នាទី ត្រឡប់ចូលមកវិញ សូមបន្តកិច្ចដំណើរការនីតិវិធីយើងទៀត ។ សូមសម្រាកចុះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:៤៦ នាទី ដល់ម៉ោង ១១:១០នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយជាបន្តនេះសូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ឡើងបន្តនូវសំណួរដល់ជនជាប់ចោទបន្តទៀត ។ សូមអញ្ជើញ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** អរគុណលោកចៅក្រម ។ ដូច្នេះយើងបានឈប់អម្បាញ់មិញនេះ គឺបានមិនលើកឡើងទាក់ទងទៅនឹង-- ឈប់លើកឡើងអំពីភាពសម្ងាត់ហើយ ។ ហើយយើងកំពុងនិយាយអំពីភាពចាំបាច់នៃការគោរព ។ ខ្ញុំជឿថា យើងបានយល់ពីចម្លើយរបស់លោក ដែលលោកខ្លួនឯងបានគោរពបញ្ជារបស់ថ្នាក់លើដោយមានការភ័យខ្លាច ដូច្នេះ ហើយទើបលោកគោរពបញ្ជាថ្នាក់លើ ។ ថាប្រធានរបស់លោកផ្ទាល់គោរពលោកដែរឬទេ? គោរពដូចគ្នាដែរឬទេ? ដូចអារម្មណ៍ដែលគេភ័យខ្លាចហ្នឹង តើគេនឹងគោរពលោកដែរឬទេ?

**ឆ៖** រឿងនេះគឺអ៊ីចឹងហើយ ។

**ស៖** អ្នកយាមមួយចំនួនពីម-១៣ ហើយយើងគឺដូចនៅ ឃើញដូចនៅស-២១ ផងដែរ ។ លោកគឺជាអ្នកផ្ដាច់ការ មេមួយផ្ដាច់ការ មេផ្ដាច់ការ ។ ថាតើលោកនិយាយយ៉ាងម៉េចចំពោះការលើកឡើងដូច្នេះ?

**ឆ៖** ដំបូងខ្ញុំសូមឆ្លើយមួយម៉ាត់ ថាប្រាកដជាអ្នកដឹកនាំមួយដែលមានអំណាចពិតប្រាកដ ។ ខ្ញុំមិនដែលនិយាយពាសវាលពាសកាលទេ អ្នកណាក៏ខ្លាចដែរ តែខ្ញុំនិយាយម៉ាត់ណា ខ្ញុំធ្វើម៉ាត់ហ្នឹង ។ វន វ៉េត គាត់ឲ្យគំរូខ្ញុំអារបៀបហ្នឹង គាត់មិនមាននិយាយទេ តែនិយាយគាត់ធ្វើ ។ សុន សេន ក៏ឲ្យគំរូខ្ញុំអ៊ីចឹង ។ ពាក្យស្លោករបស់អ្នកដឹកនាំគឺ "ទន់ភ្លន់តែម៉ឺងម៉ាត់" ។

**ស៖** របៀបនៃការអនុវត្តអំណាចនេះគឺ របៀបនេះគឺបានបង្កើតបន្តទៀតនៅក្នុងថ្នាក់ក្រោមដែរឬទេ? ថាតើបុគ្គលិកក្រោមបង្គាប់របស់លោកគឺថាគាត់មានអំណាចដូចគ្នាដែរ ឬទេនៅក្រោមឋានានុក្រមនៃជួរ ខ្សែបញ្ជានេះ?

[១១:១៤:៣៨]

**ឆ៖** ធម្មតាមិនដែលមានការដូចគ្នាសុទ្ធសាធទេ ។ កម្មាភិបាលដែលមកពីកងពល៧០៣ ច្រើនតែមានរូបភាពច្រងេងច្រងាង មាត់ឡូឡាបន្តិច។ ច្រើនតែមានមាត់ឡូឡា មាត់ធំមាត់តូចបន្តិច ។ ចំណែកខ្ញុំខ្ញុំហ្នឹង ក៏ប៉ុន្តែខ្ញុំថាម៉ាត់ណា គឺម៉ាត់ហ្នឹង អ្នកណាក៏ខ្លាចខ្ញុំដែរ សូម្បីតែអនុប្រធានខ្ញុំជួនកាលញ្ញាក់សាច់

នឹងខ្ញុំដែរ ។ ដូច្នេះ អារឿងឫកពាក្នុងឋានៈដឹកនាំមិនដូចគ្នាពីកម្មាភិបាលមួយទៅកម្មាភិបាលមួយ ។ ក៏ប៉ុន្តែកម្មាភិ--

**ស៖** ខ្ញុំចង់និយាយអំពីការស្វ័យទិតៀន ការប្រជុំស្វ័យទិតៀន ដែលលោកបាននិយាយ ហើយវាជាផ្នែកនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លោកបានឆ្លើយតបទៅនឹងសំណួរមុនៗទាក់ទងទៅនឹង មានអ្វីកើតឡើងនៅក្នុងកិច្ចប្រជុំស្វ័យទិតៀន ដូច្នេះខ្ញុំមិនលើកឡើងបញ្ហានេះទេ។ ខ្ញុំចង់សួរ ហើយសូមឲ្យលោកពន្យល់យើងខ្ញុំ អំពីទស្សនទានរបស់បក្ស ។ តើអ្វីជាគោលបំណងរបស់-- នៅក្នុងកិច្ចប្រជុំដែលទាក់ទងទៅនឹងកិច្ចប្រជុំស្វ័យទិតៀននេះ មានគោលបំណងក្នុងការចង់បានអ្វីនៅក្នុងបក្ស?

**ឆ៖** ប្រជុំទិតៀន ស្វ័យទិតៀននេះ ជាពាក្យប្រែៗទៅជាភាសាបរទេស ដើម្បីឲ្យស្រួលយល់ ។ តាមពិតគេហៅពាក្យចំរបស់គេ គេហៅ “ប្រជុំជីវភាពបក្ស” ។ យើងត្រូវការប្រជុំជីវភាពបក្សនេះ ដូចយើងត្រូវការបាយសម្លអីចឹង ។ យើងត្រូវការប្រជុំជីវភាពបក្ស ដូចយើងត្រូវការបាយសម្ល ។ ខានហូបមិនបាន ។ “ប្រជុំជីវភាពបក្ស” ដើម្បីកសាងអី? ដើម្បីកសាងទស្សនៈនយោបាយថ្មី ដែលស្របមិនស្របនឹងគោលនយោបាយរបស់បក្សក្នុងរយៈកាលនីមួយៗ យើងកសាងគ្នាឲ្យយល់ ។ យើងកសាងឲ្យយល់អំពីគោលនយោបាយនៅក្នុងជីវភាព នៅក្នុងការប្រជុំជីវភាព ។ ដូច្នេះ យើងយកមាគ៌ានយោបាយរបស់បក្សក៏ដោយសារ “ប្រជុំជីវភាព” ។ យើងមានគោលជំហរសតិអារម្មណ៍ថ្មីក៏ដោយសារយើង “ប្រជុំជីវភាព” ។

[១១:២០:១៧]

យើងកសាងគោលជំហរសមូហភាព កម្ចាត់ចោលគោលជំហរស្វ័នតួ លះបង់គោលជំហរស្វ័នតួ គោលជំហរបុគ្គល គោលជំហរអំណាច ។ យើងកសាងគោលជំហរសមូហភាព ។ យើងកសាងគោលជំហរគោរពអង្គការវិន័យ ។ កាលណាយើងមានគោលជំហរ អង្គការវិន័យនៅក្នុងខ្លួនយើងចេះគោរពថ្នាក់លើ យើងចេះគោរពសេចក្តីសម្រេចចិត្តរបស់បក្ស យើងទុកនេះជាសារសំខាន់ ។

ឧទារណ៍មួយទៀត ខាងគោលជំហរចាត់តាំង ខាងគោលជំហរចាត់តាំងនៅឆ្នាំ១៩៨៣-៨៤ ។ អូយយូយ! ខ្ញុំច្រឡំបាត់ហើយសុំទោស ខ្ញុំច្រឡំ។ នៅឆ្នាំ១៩៧៣ ឬ៧៤ បក្សលើកមាគ៌ាចាត់តាំងមួយច្បាស់លាស់ ។ មាគ៌ាវណ្ណៈណា កម្មាភិបាលវណ្ណៈនោះ ។ ដូច្នេះ បើគេកើតមកជាកសិករក្រីក្រ ត្រូវតែប្រកាន់វណ្ណៈដឹកនាំយើង ។ នៅក្នុងតំបន់៣២ ខ្ញុំសូមជូនឧទាហរណ៍មួយ ពីដើមមក ឆាយ គឹមហ៊

គាត់គ្រប់គ្រងកសិករប៉ុន្មាននាក់នៅពីក្រោមគាត់ ក្នុងឋានៈកម្មាភិបាលតំបន់ដូចគ្នា។ ដល់ក្រោយចេញមាក៏ហ្នឹងមក ឆាយ គឹមហ៊ា ធ្លាក់ទៅនៅខាងក្រោមគេ ឡើងកសិករគេដឹកនាំ ។ ក្រោយឆ្នាំ១៩៧៥ តាម៉ុក ឡើងជាបុគ្គលទីបួន ច្បាស់ថែសកសិករក្រីក្រ ។ នេះគេហៅថា ការប្រជុំជីវភាពដើម្បីកសាងគោលជំហរនយោបាយ ដើម្បីកសាងគោលជំហរសតិអារម្មណ៍ និងគោលជំហរចាត់តាំងឲ្យសមស្រប ទៅតាមគោលជំហរនយោបាយ និងគោលជំហរចាត់តាំងរបស់បក្ស ។ យ៉ាងនេះហើយបានជាគេហៅការប្រជុំទិតៀន និងស្វ័យទិតៀន ហៅថា "ប្រជុំជីវភាពបក្ស" ។

**ស៖** ដូច្នេះ ដើម្បីធ្វើការក្តោប និងសន្និដ្ឋាន និងសង្ខេប នៅពេលនោះលោកខ្លួនឯង គឺមានតួនាទីជាអ្នកដឹកនាំ និងប្រធានម-១៣ ។ អ្វីដែលលោកធ្វើការនោះគឺ ប្រព័ន្ធមួយដែលប្រតិបត្តិការក្រោមភាពសម្ងាត់ ដូចដែលលោកបានលើកឡើង ដោយផ្អែកទៅលើការគោរពបញ្ជាដាច់ខាតរបស់ថ្នាក់លើ ហើយនិងពាក់ព័ន្ធទៅនឹងការកសាងទៅលើ ការកម្ទេចទៅលើជាតិ ហើយគឺចំណុចទាំងអស់នេះ គឺបានអនុវត្តនិងប្រតិបត្តិការឡើងក្នុងសង្គ្រាមគ្រប់គ្រងអំណាច គឺដើម្បីធ្វើការចាប់យកអំណាច ។

**ឆ៖** ការងារនេះ មិនមែនតែនៅក្នុងសង្គ្រាមដើម្បីដណ្តើមអំណាចទេ គឺជាជីវិតបក្ស បក្សវណ្ណៈអធនប្រកាន់គោលជំហរហ្នឹង នេះជាធាតុពិតរបស់វណ្ណៈអធន នៅលើសកលលោកគ្រប់បក្ស និយាយពិសេសឲ្យចំ ។

[១១:២៧:៤៦]

**ស៖** យើងនិយាយអំពីម-១៣ ដូច្នេះ ហើយខ្ញុំនិយាយអំពីសង្គ្រាមស៊ីវិលនៅពេលនោះ យើងនិយាយអំពីម-១៣ ។ មានសំណួរពីរ និងបីបន្ថែមទៀត លោកសហព្រះរាជអាជ្ញាលោក ពេទីត បានសួរលោកកាលពីម្សិលមិញចំពោះសំណួរមួយចំនួន ចំពោះលទ្ធភាពរបស់លោកក្នុងការធ្វើការធ្វើដំណើរទៅកន្លែងផ្សេងៗ ក្នុងឋានៈជាប្រធានម-១៣ ហើយសហព្រះរាជអាជ្ញាសុំឲ្យលោកនៅពេលនោះ បញ្ជាក់នូវអ្វីដែលបានកើតចំពោះលោក ដែលលោកចំណាយពេលមួយយប់នៅក្រៅម-១៣ ។

ដូច្នេះ យើងខ្ញុំសូមលើកបញ្ជាក់បន្ថែមបន្តិចទៅលើចំណុចនេះ ។ លោក ឌុច ថាតើមានតាម-- អ្វីដែលលោកចាំ តើលោកចំណាយប៉ុន្មានយប់នៅដេកនៅក្រៅម-១៣ នៅអំឡុងឆ្នាំ៧១ និង៧៥ តើលោកស្នាក់ខាងក្រៅពីម-១៣ នេះប៉ុន្មានយប់ដែរ?

**ឆ៖** ខ្ញុំបានជម្រាបលោក រ៉ូបឺត ពេទីត កាលពីម្សិលមិញហើយ ខ្ញុំជម្រាបគាត់ថា ខ្ញុំជាមួយនឹងវន វ៉េត ខ្ញុំបានទៅដេកនៅក្នុងផ្ទះរបស់គាត់ជាមួយនឹងគាត់ ។ តែជាមួយនឹងលោកគ្រូ សុន សេន ខ្ញុំមិន

ដែលបានទៅដេកទេ ។ ជាមួយនឹង វន វ៉េត ដំបូងថ្ងៃទៅទទួលបញ្ជាចាត់តាំងមន្ទីរ១៣នេះ ខ្ញុំទៅជួបគាត់ គាត់ប្រុងខន្ទេសនាមការងារ នៅល្ងាចថ្ងៃ២០ កក្កដា ហ្នឹងឯង ។ ប៉ុនដល់គាត់មានភ្ញៀវមកពីភ្នំពេញជាកម្មាភិបាលសម្ងាត់របស់កម្លាំងក្រុងភ្នំពេញ គាត់ក៏ឲ្យខ្ញុំចងអង្រឹងដេកនៅមន្ទីរគាត់ ព្រឹកឡើងសឹមខ្ញុំមកវិញ ។ ឯចំណែកមួយលើកទៀត ខ្ញុំទៅថ្ងៃដែលពួកគេវ៉ៃគុកហ្នឹង ខ្ញុំទៅដល់ម៉ោង៧ ខ្ញុំជួបគាត់ រាយការណ៍ជូនគាត់ហើយ ។ ខ្ញុំប្រញាប់ត្រឡប់មកវិញ ។ ឯចំណែក ថ្ងៃមួយនោះពេលដែល វន វ៉េត អញ្ជើញមកត្រឡប់មកពីវៀនវិញ ខ្ញុំជួបគាត់ពីថ្ងៃ ហើយគាត់ដល់ឃើញខ្ញុំគាត់អរដែរ គាត់ថា មិត្ត ឌុច យប់នេះនៅដេកនេះហើយ ។ ដូច្នេះ យប់នោះមែន ខ្ញុំមានការងារពិគ្រោះជាមួយនឹងគាត់ច្រើនណាស់ ខ្ញុំសូមទុកការងារពិគ្រោះរឿងអីខ្លះសិន ខ្ញុំនិយាយតទៅទៀត ។

ខ្ញុំសូមបញ្ជាក់ម្តងទៀត ជាមួយលោកគ្រូ សុន សេន។ គាត់ហៅខ្ញុំទៅមានម៉ោងមានពេល ចេញពីធ្វើការត្រឡប់មកផ្ទះវិញ ។ ជាមួយនឹង ជូ ជេត ខ្ញុំមានលិខិតដើរផ្លូវកាលណាខ្ញុំមានកាន់ការចាំបាច់ ខ្ញុំទៅជួបការងារហើយ ខ្ញុំត្រឡប់មកវិញ ។ ក្នុងការប្រជុំជីវភាពក៏ខ្ញុំមិនដែលហ៊ាន មិនមានសិទ្ធិ មិនមានលក្ខណៈសម្បត្តិ ខ្ញុំមិនមានលក្ខណៈសម្បត្តិប្រជុំនៅកន្លែងទេ ត្រូវទៅប្រជុំនៅលេខាផ្ទះ មន្ទីរ ៣០៥ ។ ដូច្នេះ ខ្ញុំទៅពីព្រឹកប្រជុំចប់ល្ងាចខ្ញុំត្រឡប់មកវិញ ។ មន្ទីរខ្ញុំនៅអមលាំង មន្ទីរ៣០៥ នៅភូមិក្រាំងបេង ឃុំពាង ។

នៅពេលដែលបានម៉ូតូ អាហ្នឹងដែលខ្ញុំប្រើពាក្យជិះម៉ូតូដើរលេង ។ ដែលខ្ញុំប្រើពាក្យជិះម៉ូតូដើរលេងហ្នឹង គឺខ្ញុំទៅផ្ទះ សឺន វិសុទ្ធ ហៅ កន ប្អូនរបស់មេខ្ញុំហ្នឹង ដើម្បីរង់ចាំដំណឹងពីមេៗ ហើយជួនពេលខ្លះទៅផ្ទះ ឃុន ផូ ហៅ កែវ លេខាពញាឮដើម្បីរង់ចាំដំណឹងដូចគ្នា ។ ដូច្នេះ ផ្លូវដើរពីភូមិភាគពិសេស សំបុត្រដើរផ្លូវមាន ។ ពីមន្ទីរខ្ញុំទៅភូមិភាគពិសេស សំបុត្រដើរផ្លូវមាន ។ ការងារខ្ញុំមាន កម្មា-ភិបាលដែលខ្ញុំត្រូវទៅជួប គេក៏ស្គាល់ខ្ញុំ ។ បើសិនជាគេចាប់ ខ្ញុំមានគ្រប់សព្វ មានសំបុត្រដើរផ្លូវ ។ បើសិនជាខ្ញុំត្រូវគេចាប់ខ្ញុំមានសំបុត្រដើរផ្លូវ ខ្ញុំមានទិសដៅដែលខ្ញុំទៅ កម្មាភិបាលដែលខ្ញុំស្គាល់ ។

ដូច្នេះសរុបមក សិទ្ធិដើរហើរ មាននៅក្នុងក្របខ័ណ្ឌវិន័យមួយច្បាស់លាស់ ។

[១១:៣៥:៤៥]

**ស៖** អរគុណ ។ លោកក៏បានចង្អុលបញ្ជាក់ផងដែរ ដោយឆ្លើយសំណួររបស់ខ្ញុំមួយចំនួននោះ ។ លោកបានបញ្ជាក់ថា លោកមានការគ្រប់គ្រងលក្ខណៈចង្អៀតមួយ ហើយលោកបានអនុវត្តក្នុងការដោះលែងអ្នកទោសម-១៣ ប៉ុន្តែ លោកមិនបានទទួលជោគជ័យក្នុងការដោះលែងអ្នកទោសនៅស-២១ ហ្នឹង

ទេ ហើយយើងនឹងនិយាយជាក់លាក់អំពីស-២១ នៅពេលក្រោយ ហើយនៅពេលនេះយើងផ្តោតទៅលើ ម-១៣ សិន ។ ដូច្នេះលោកអាចជម្រាបយើងដែលឬទេ? សូមលោកបញ្ជាក់ចំណុចមួយចំនួន វាអាចវែងជាការពិតណាស់ អំពីរបៀបដែលលោកបានដោះស្រាយទៅលើបញ្ហាហ្នឹង-- ដែលលោកបានដោះលែង ដែលលោកដោះលែងមួយចំនួន ថាលោកទទួលសុំសិទ្ធិអនុញ្ញាតពីមេរបស់លោកយ៉ាងម៉េច?

**ឆ៖** រឿងដោះលែងជនរងគ្រោះដែលគេបញ្ជូនមក ស-២១ នេះ រឿងTC១ ។ រឿង TC១ នេះ ខ្ញុំសុំមិននិយាយតទៅទៀតទេ ខ្ញុំសុំមិននិយាយអំពីTC១ ខ្ញុំនិយាយដូច ច្រើនមកហើយ ។ ខ្ញុំសុំនិយាយពីមនុស្សម្នាក់ដែលខ្ញុំដោះលែងដំបូងគេ គឺស្រីម្នាក់ ។ គេបញ្ជូនមកម-១៣ ពីព្រោះគាត់ត្រូវគេចោទថា "លួចក្រវិល" លួចក្រវិលមាសទម្ងន់ប្រាំ-- តិចទេ ប្រាំហ៊ុន ។ ខ្ញុំមិនជឿ ហើយប្រធានរណសិរ្សស្រុក អនុលេខាស្រុកឈ្មោះ បងប៉ុន ក៏គាត់មិនជឿ ។ ខ្ញុំបានគ្នាពីរនាក់តវ៉ាជាមួយនឹង ឆាយ គឹមហ៊ៃ ។ ឯមិនចេះតវ៉ាអី ឈ្ងងណាំងអីនឹងគេ ទៅដល់សុំអង្វរកគេថា នារីនេះមិនគួរណាជាប់នៅម-១៣ ទេ ពីព្រោះគ្នាមិនមែនខ្លាំង ។ ក៏ប៉ុន្តែបង គឹមហ៊ៃ គាត់ឆ្លើយថា ឌុច "នាងនេះប្តីដើម គឺជា*អាកស្លុងដង់សែហ្សូ*របស់ទាហាន លន់ នល់" ។

ខ្ញុំពុះពារពន្យល់មេខ្ញុំហើយ បង គឹម ហ៊ៃ ហើយ ។ ខ្ញុំថា បងប្តីគេខ្លាំងជាទាហាន ក៏ប៉ុន្តែគេទៅចោលប្រពន្ធគេហើយ ។ យើងមិនត្រូវរុញមនុស្សទៅឲ្យខ្លាំង យើងមិនត្រូវចាប់មនុស្សមិនទាន់ច្បាស់លាស់ជាខ្លាំងទេ គួរយើងថែរក្សាគ្នាទៅទុកទៅ ព្រោះក៏បងមានប្រសាសន៍ដែរ ប្រាប់ថាយើងរំដោះយកមនុស្សមិនមែនរំដោះយកដីទេ ។ ដល់និយាយនឹងគាត់ទៅ គាត់ថាចាំមើលពីរ-បីថ្ងៃទៀត ។ ប្រហែលជាមួយអាទិត្យក្រោយមកគាត់ប្រាប់ថា "ដោះលែងទៅ"។

[១១:៤០:៤៧]

ហើយរឿងមួយទៀត រឿងទីពីរនៅក្នុងខែ-- រឿងនារីនេះ គឺនៅក្នុងខែប្រាំបី ខែសីហា ១៩៧១ ។ ឯចំណែករឿងទីពីរ គឺប្រហែលជាក្នុងខែប្រាំបី ឬចុងខែប្រាំបី ឬដើមខែប្រាំបួន ។ មាន KW-30 យើងនេះ គាត់ទៅកាត់ក្បាលគេ ដល់ពេលក្រោយពីការសុំអង្វររបស់ខ្ញុំ ឆាយ គឹមហ៊ៃ សុខចិត្ត អាហ្នឹងទំនាស់ក្នុងផ្ទៃប្រជាជន ដោះលែងគេទៅ ទុកជាមួយ ឌុច ឯង មិត្តឯងតែបីបួនថ្ងៃដោះ លែងគេទៅ ។ ហើយទំនាស់ទីបី រឿងទីបីដូចដែលខ្ញុំបានជម្រាបលោកចៅក្រមហើយ ក៏ប៉ុន្តែមិនបានរៀបរាប់ គឺពួកកប់ស្រូវ កម្មាភិបាលរបស់រណៈសិរ្សរួបរួមជាតិ មានគ្នាបួននាក់ ដល់ទាស់គ្នាអីចឹង ខ្ញុំទៅរាយការណ៍សុំដោះលែង គាត់សុខចិត្ត ។ ហើយបន្ទាប់មកទៀត ខ្ញុំដោះលែងបានម្នាក់ទៀត គាត់លក់គោ ខ្ញុំមិនទទួល

ស្គាល់ថា ការលក់គោជាអំពើក្បត់ជាតិទេ លក់គោទៅដីខ្មាំង ។ ដល់ទាមទារសុំដោះលែងអ៊ីចឹងបាន ។ ហើយបន្ទាប់មកទៀត មានក្មេងជំទង់ម្នាក់ ខ្ញុំថាក្មេងជំទង់មិនត្រូវកម្ទេចទេ ។ ក្មេងជំទង់មិនត្រូវកម្ទេចទេ តស៊ូនឹងគាត់យូរណាស់ទម្រាំគាត់សុខចិត្ត ។ ខ្ញុំឡើងទៅដល់ វន វ៉េត បាន១ទទួលការដោះលែង ។ ខ្ញុំឡើងទៅដល់ វន វ៉េត បាន វន វ៉េត គាត់សុខចិត្តដោះលែងនាងហ្នឹង ។ ដល់ចុងបញ្ចប់ TC-1ហ្នឹងឯង ។ ហើយដែលពិបាកបំផុត គឺ ហាម អ៊ីម ហ្នឹងឯង ដែលខ្ញុំត្រូវ ចំណាយពេលវេលាច្រើន ហើយភ័យខ្លួនឯងញាក់សាច់ក្នុងការដោះលែង ហាម អ៊ីម សុំដោះលែង ហាម អ៊ីម ។

សរុបមក ខ្ញុំដោះលែងបានដប់នាក់ ។ ដប់នាក់បើប្រៀបធៀបនឹងមនុស្សដែលបាត់បង់ជីវិតទៅរងគ្រោះទារុណកម្មនៅម-១៣“ក” វាមានតិចណាស់ បើត្រឹមតែក្នុងចំណោមដប់ក្នុង-- ដូច្នេះខ្ញុំមិនទុកជាគុណសម្បត្តិអីទេ ក៏ប៉ុន្តែខ្ញុំចង់និយាយអំពីការដែលខ្ញុំខំពុះពារ ដូចខ្ញុំចង់និយាយអំពី រឿងស៊ូបានជាគេសុខចិត្តដោះលែង ។ រឿងដែលខ្ញុំដោះលែងបានទាំងប៉ុន្មាន គឺនៅមុនឆ្នាំ១៩៧៣ ។ លើកលែងតែ ហាម អ៊ីម មួយក្រោយ៧៣ ។ សរុបមក កាលនោះមាគ៌ាគេនៅប្រមូលកម្លាំងរណសិរ្ស ដល់ក្រោយចិតបី មាគ៌ាគេទៅផ្សេងហើយ ។

ដូច្នេះ ការដែលខ្ញុំដោះលែងនេះមិនមែនជាគុណសម្បត្តិដែលគួរនេះទេ-- ខ្ញុំដឹងថាខ្ញុំបានធ្វើមែន ក៏ប៉ុន្តែមិនមែនជាគុណសម្បត្តិដែល-- វាប្រៀបធៀបទៅនឹងទឹកមួយដំណក់ទៅនឹងឧក្រិដ្ឋកម្មរបស់ខ្ញុំដ៏ធំធេង ។

[១១:៤៦:៤០]

**ស៖** ជាការពិត ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានលើកឡើងអំពីទារុណកម្ម ដែលប្រព្រឹត្តឡើងចំពោះអ្នកទោសដែលលោកមាននៅម-១៣ ខ្ញុំជឿថា មានភាពចាំបាច់ក្នុងការនិយាយអំពីបញ្ហានេះឡើងវិញ ។ លោកទទួលស្គាល់អំពីបញ្ហាហ្នឹង ហើយខ្ញុំចង់ចូលទៅដល់អង្គហេតុមួយសាថ្មី ដែលលោកបានលើកឡើងកាលពីម្សិលមិញ ។ លោកបានពន្យល់ជូនក្រុមប្រឹក្សាជំនុំជម្រះថា “លោកព្យាយាមអនុវត្តវិធីទារុណកម្ម ដោយឲ្យស្ត្រីចុះងូតក្នុងទឹក ហើយឲ្យគាត់ហាលខ្យល់ត្រជាក់ ថាតើចំណុចនេះលើកឡើងអ្វីដែលបានលើកឡើងនេះត្រឹមត្រូវដែរឬទេ?

ជាបឋមខ្ញុំចង់សួរសំណួរទីមួយ ដែលអាចជាបញ្ហាបន្តិចបន្តួចទាក់ទងទៅក្នុងការបកប្រែថា តើអ្នកទោសនោះ គឺគាត់មានស្លៀកពាក់ដែរ ឬទេនៅពេលដែលគាត់បោះចូលទៅក្នុងបឹង-- ឲ្យចូលក្នុងបឹង ឬក៏គាត់អត់មានសំលៀកបំពាក់ គាត់ខ្លួនទទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពាក្យបារាំងហៅថា “*ប្លុងស្សេ*” នេះមិនដឹងថាមានកម្លាំងសង្កត់ដែរ ឬអត់? បើសិនជាមានកម្លាំងសង្កត់វាអត់ បើសិនជាមានកម្លាំងសង្កត់មិនត្រូវទេ អត់មានសង្កត់ទេ ។ គាត់ចុះទៅងូតទឹក បើតាមខ្ញុំយល់ថាគួរប្រើពាក្យ “*ស៊ីបាយេ*” ។

ខ្ញុំនិយាយអំពីរឿងដែលខ្ញុំសម្រេចធ្វើទារុណកម្ម ហើយនិងរបៀបខ្ញុំនិយាយដើម្បីធ្វើទារុណកម្មបន្តិចសិន ។ មុននឹងធ្វើទារុណកម្ម ខ្ញុំមិនដែល ធ្វើទារុណកម្មអ្នកណានៅក្នុងសាច់រឿងទេ ។ សាច់រឿងរបស់នារីនេះ គាត់ជាស្រីខូច ជាស្រីសំផឹង ។ ខ្មាំងចាត់តាំងគាត់ឲ្យចូលមកដីរំដោះយកការណ៍ ។ គាត់សារភាពប៉ុណ្ណឹង ។ ខ្ញុំចង់ដឹងទៀតថាតើគាត់មានគ្នាមកប៉ុន្មាននាក់? យើងចាប់សួរសំណួរថ្មី ប៉ះពាល់ដល់អ្នកផ្សេង ឬក៏ប៉ះពាល់ដល់សាច់រឿង ខ្ញុំអត់ធ្វើទារុណកម្មនៅក្នុងរឿងនេះទេ ។ ខ្ញុំនាំចេញពីក្រៅរឿងទៅផ្សេង ខ្ញុំសួរថាអាយុប៉ុន្មានហើយ? គាត់ឆ្លើយថាអាយុ២៨ឆ្នាំ ។ ខ្ញុំបើកមាត់ ឲ្យគាត់បើកមាត់មើល ឲ្យគាត់រាប់ធ្មេញ ឲ្យគាត់រាប់ខ្លួនគាត់ទេ ដល់គាត់រាប់វាមិនគ្រប់ធ្មេញសាមពីរ ។ ខ្ញុំរៀនវិទ្យា-សាស្ត្រអ្នកណាអាយុលើសពីអាយុម្ភៃប្រាំ ធ្មេញគ្រប់សាមពីរហើយ ។ ដល់ទាស់អ៊ីចឹង ខ្ញុំថាមិនបានទេ៎ ភរអញ! ទៅ ។ ឥឡូវចុងបញ្ចប់សួរគាត់ថា ហ្អែងរងាអត់? ដូច្នេះ គាត់ឆ្លើយថា រងាស្អីៗគាត់ យើងធ្វើទារុណកម្មគាត់អារឿងធ្មេញ អារឿងគាត់ភរនេះទេ ។ ដល់ហើយស្រួលបួលបានខ្ញុំចាប់ផ្ដើមសួររឿងថ្មីទើប-- បានខ្ញុំទាញចូលទៅក្នុងសាច់រឿង ។ ដល់ផុតមួយថ្ងៃអីទៅ ខ្ញុំទាញចូលទៅសាច់រឿងសួរចម្លើយគាត់ទៀត ។

[១១:៥២:១០]

បានថារបៀបសួរចម្លើយរបស់ខ្ញុំ ធ្វើទារុណកម្ម គឺបែបនេះ ។ ដល់ខ្ញុំខំនិយាយរឿងនេះ វាវាងផុតសំណួររបស់លោកមេធាវីហើយ ។ ឥឡូវខ្ញុំចូលមកសំណួរវិញ ខ្ញុំម្សិលមិញដូចបានបញ្ជាក់ដែរ ខ្ញុំអត់ឲ្យគេស្រាតឲ្យខោអាវទេ គ្រាន់តែខ្ញុំមិនបានបញ្ជាក់ ។ ខ្ញុំគ្រាន់-- ម្សិលមិញខ្ញុំអត់បានបញ្ជាក់ថាខ្ញុំអត់បានឲ្យគេស្រាតខោអាវ ខ្ញុំថាដល់ណាគេត្រូវទឹកអ៊ីចឹងទៅ គេស្រីខោអាវវារឹបទៅនឹងខ្លួនគេ វាធ្វើឲ្យយើងជាប្រុសមានការជ្រួលច្របល់ក្នុងចិត្ត ។ ធម្មតាទេស្រីតែកាលណាគេ--ខោអាវគេត្រូវទឹកសើមអាខោអាវនឹងវារឹបទៅនឹងខ្លួនគេ ។

ដូច្នេះ អាដើមទ្រូងគេក៏យើងឃើញ អាស្អីៗត្រគាកអីឯណា ក៏យើងឃើញរាងពីក្រៅ ។ រឿងនេះហើយខ្ញុំឃាត់ឲ្យធ្វើទារុណកម្មដោយជ្រលក់-- នែ៎ដោយឲ្យគេមកមុជទឹក ហើយមកហាលខ្យល់ ។

ដូច្នេះ ចម្លើយមួយម៉ាត់ដែលចំជូនលោកមេធាវី គឺខ្ញុំអត់បានឲ្យនាង សុខ នោះដែលជាស្រីសំផឹងក៏ដោយ គេស្រាតទេ ។ ខ្ញុំគ្មានបំណងអីចង់ទៅមើលរបស់គេទេ ។

**ស៖** លោកបានបន្ថែមកាលពីម្សិលមិញថា លោកបានបញ្ចប់ទៅលើព្រឹត្តិការណ៍នោះ ដោយសារតែវាបានបង្កើតឲ្យមានអារម្មណ៍ ថាតើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយថាបង្កើតឲ្យមានអារម្មណ៍នោះ?

**ឆ៖** ហើយវារីបទៅនឹងសាច់។ វាងវៅគេវាច្បាស់ថែសមកធ្វើឲ្យយើងរំភើបដែរ ។ លើកនេះម្តងខ្ញុំទប់ជាប់ មិត្តប៉ុន ក៏ទប់ជាប់ ។ ខ្ញុំលើកនេះម្តងខ្ញុំទាំងពីរនាក់ទប់ជាប់ ចុះលើកក្រោយទប់ជាប់ឬមិនជាប់ បើទប់មិនជាប់កំបុតក ។ ម្សិលមិញខ្ញុំបាននិយាយពាក្យមួយទៀត ជូនលោកសហព្រះរាជអាជ្ញាថា មិនដឹងថាសហព្រះរាជអាជ្ញា ឬក៏លោកចៅក្រមទេថា “មិនបានប្រយោជន៍” ។ ម៉េចមិនបានប្រយោជន៍ព្រោះក្រោយអំពីឲ្យគេមុជទឹក ហើយទៅហាលខ្យល់ហ្នឹង នាងសុខ ហ្នឹង នៅតែឆ្លើយចម្លើយដដែល ។ គាត់ថា “គាត់អត់មានគ្នាមកទេ គេចាត់តាំងគាត់មកតែម្នាក់ឯង” ។

ដូច្នេះ សេចក្តីសន្និដ្ឋានរបស់ខ្ញុំ អត់ទាន់ប៉ានថាគេលាក់ ឬក៏គ្នាថាត្រង់មកប៉ុណ្ណឹង ។ ដូច្នេះទារុណកម្មនេះមិនមែនគ្រាន់តែអត់ប្រយោជន៍ទេ ស្រួលមិនស្រួលគ្រោះថ្នាក់ផង ។

[១១:៥៧:៤៥]

**ស៖** ឌុច លោកអាចជម្រាបយើងបានឬនៅ តើមានអ្វីកើតឡើងនៅពេលហ្នឹង?

**ឆ៖** ការណ៍ទៅឲ្យគេ ខាងនិរតី គេសម្រេចថា “កម្ទេច” ។

**ស៖** តើគាត់ត្រូវបានគេកម្ទេចដែរឬទេ តាមបញ្ជារបស់លោក?

**ឆ៖** *(និយាយភាសាបារាំង)*

**ស៖** ថាតើលោកបញ្ជាក់យ៉ាងម៉េច ចំពោះបញ្ហានេះ? ថ្ងៃនេះ?

**ឆ៖** បើជំនាន់នោះ យើងនិយាយថា យើងគោរពបទបញ្ជារបស់បក្ស វាជាគុណសម្បត្តិមួយឬក៏ជាកាតព្វកិច្ចមួយរបស់យើង ។ ឥឡូវនេះយើងត្រូវមើលឃើញថា អាហ្នឹងជាឧក្រិដ្ឋកម្មទៅលើអ្នកស្លូតត្រង់ ហើយគ្នាជាស្រីទៅទៀត ។ ជំនាន់នោះ១ ខ្ញុំមើលឃើញថា១ គ្មានផ្លូវអីដោះស្រាយ១ ក្រៅអំពីការគោរពវិន័យបានទេ ។

ដូច្នេះ ហើយបានជាខ្ញុំតែងតែនិយាយជាញឹកញាប់ថា កើតមកជាមនុស្សវាត្រូវតែធ្វើការងារអីដែលយើងមិនចូលចិត្តអ៊ីចឹងហើយគេដឹង នៅពេលហ្នឹងដើម្បីល្បួងចិត្ត ខ្ញុំយកកំណាព្យ *“ឡាម៉ង់ដុយឡូ”*

របស់ *អាល់ក្រីឌីប៊ីនី* មកសូត្រ ។ កំណាព្យហ្នឹង ពេលនោះខ្ញុំសូត្រទាំងខុសទេ ។ ឯកំណាព្យដែលត្រូវរបស់គេវិញគឺ១ *"ប្លឺរ៉េ ហ្សេមៀរ ប្រ៊ីយ៉េ អ៊ែ អេកាឡឺម៉ុង ដឺឡាស"* (*"Pleurer, gémir, prier est également lâche)* ។ គឺ-- ដើម្បី-- ហើយជាបន្ទុក ហើយ គឺជាព្រហ្មលិខិតបានដាក់ទៅលើលោកនាក់ហើយបន្ទាប់មកដូចខ្ញុំរងគ្រោះ ហើយស្លាប់ដោយមិនបានឆ្លើយតបនឹងសំណួរមួយណាជាក់លាក់ ។

[១២:០២:០៥]

**ប្រធានអង្គជំនុំ៖**

អស់សំណួរហើយលោកមេធាវី? អញ្ជើញលោក ពេទីត!

**ចៅក្រម រ៉ូប៊ែត ពេទីត៖**

អរគុណលោកប្រធាន។ គឺយើងមានលក្ខណៈជាក់ស្តែង ខ្ញុំសូមធ្វើការបញ្ជាក់នៅក្នុងការបកប្រែនៅក្នុងយោបល់របស់ជនជាប់ចោទ ភាសាបារាំង គឺនិយាយនៅពេលមួយនោះ គឺម-១៣ ត្រូវបានគេវាយប្រហារ ។ ថាតើជាការបកប្រែអ៊ីចឹងមែន ឬយ៉ាងម៉េច? ខ្ញុំសូមឲ្យមានការបំភ្លឺពីជនជាប់ចោទ ។ គាត់បាននិយាយថានៅពេលមួយនោះ គឺគាត់ទៅឆ្ងាយពីម-១៣ នៅពេលដែលម-១៣ ត្រូវបានគេវាយប្រហារ នេះជាការបកប្រែដែលយើងទទួលបាន ។ យ៉ាងហោចណាស់សូមឲ្យលោកចៅក្រមបញ្ជាក់ទៅលើបញ្ហាហ្នឹង ។ ហើយខ្ញុំសូមឲ្យមានការបញ្ជាក់ពីជនជាប់ចោទ ដោយសារតែខ្ញុំសូមលើកឡើងថា អង្គហេតុនេះជាអង្គហេតុថ្មី ហើយវាពាក់ព័ន្ធទៅនឹងម-១៣ ។ ហើយគាត់បានលើកឡើងថា ម-១៣ រងការវាយប្រហារ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីក្រុមប្រឹក្សាជំនុំជម្រះធ្វើការឆ្លើយបំភ្លឺ ពីជនជាប់ចោទទៅលើបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្គេកអ៊ាវ អាចឆ្លើយបញ្ជាក់លើៗបញ្ហានេះបានទេ? ពីព្រោះការប្រើប្រាស់ពាក្យវាយប្រហារ ហើយនៅក្នុងន័យដែលអង្គជំនុំជម្រះទទួលបាន បើមិនច្រឡំទេ គឺមានការវាយដណ្តើមពីជនរងគ្រោះដែលត្រូវចាប់ឃុំឃាំង ចំនួន៣០នាក់ ។ ឥឡូវនេះប្រើពាក្យឲ្យបានច្បាស់លាស់ ថាតើមន្ទីរម-១៣ ហ្នឹង មានអំឡុងពេលណាមួយ មានការវាយប្រហារពីមជ្ឈដ្ឋានណាដែរឬទេ?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! សូមអរគុណលោកសហព្រះរាជអាជ្ញាដែលបានលើកសំណួរនេះ ដើម្បីឲ្យខ្ញុំបានបញ្ជាក់ច្បាស់លាស់ ។ មន្ទីរ-១៣ របស់យើងខ្ញុំ ត្រូវពួកជនរងគ្រោះដែលមកជាប់ទោសនៅទីនេះ នៅកន្លែងនោះឆក់កាំភ្លើង បាញ់អ្នកយាម ហើយរត់ ។

[១២:០៤:៥០]

**ប្រធានអង្គជំនុំ៖**

ខ្ញុំគិតថា ចម្លើយនេះច្បាស់លាស់ហើយ ហើយប្រហែលជាព្រះរាជអាជ្ញាអាចយល់ហើយ ។

ឥឡូវនេះដល់ម៉ោងហើយ ដល់ម៉ោងត្រូវសម្រាកអាហារថ្ងៃត្រង់ ។ អង្គជំនុំជម្រះសូមប្រកាសផ្អាកដំណើរការសវនាការដើម្បីពិសារអាហារថ្ងៃត្រង់ រហូតដល់ម៉ោងមួយ និងសាមសិបនាទីបន្តដំណើរការសវនាការតទៅទៀត ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំជនចោទត្រឡប់ទៅកាន់បន្ទប់រង់ចាំ និងឲ្យនាំគាត់ត្រឡប់មកវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។ ហើយអ្នកចូលរួមនិងសាធារណជនក៏ដូចគ្នា សូមអញ្ជើញចូលមកកាន់កន្លែងរៀងខ្លួន ឲ្យបានមុនម៉ោងមួយនិងសាមសិបនាទីរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង១២:០៦នាទី ដល់ម៉ោង១៣:៣៥នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ!

[១៣:៣៥:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់ តុរាងក្រចកសេះ ។

អញ្ជើញជនជាប់ចោទក្រោកឈរ!

នៅថ្ងៃនេះ អង្គជំនុំជម្រះបានទទួលលិខិតរបស់មេធាវីការពារក្ដី លោក ការ សាវុត្ថ និង លោក ហ្វ្រង់ស្វ័រ រូ បានធ្វើលិខិតមកអង្គជំនុំជម្រះសាលាដំបូង ដោយសុំដាក់មេធាវី លោកស្រី ម៉ារី ប៉ូល កានី

ហ្សា សម្រាប់ជំនួសឲ្យលោកមេធាវី ហ្វ្រង់ស្វ័រ រូ នៅក្នុងកាលៈទេសៈដែលលោកមេធាវី អវត្តមាន ។ តើជនជាប់ចោទទទួលយល់ព្រមនូវកិច្ចដំណើរការនីតិវិធីសវនាការ ដែលមានការជំនួសរបៀបនេះទេ?

**ជនជាប់ចោទ៖**

ខ្ញុំទទួលទាន ។

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ ។

ជាកិច្ចបន្ត ដោយអនុលោមតាមវិធាន២៧ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង សូមអញ្ជើញ មេធាវីការពារក្តីជនជាប់ចោទ មេធាវីជាតិឡើងធ្វើសេចក្តីស្នើសុំទទួលមេធាវីបរទេស ដែលលោកបានស្នើឡើងអម្បាញ់មិញនេះ ។ ហើយ ដែលមិនទាន់បានទទួលស្គាល់កន្លងមក ។

សូមអញ្ជើញលោកមេធាវី ការ សាវុត្ថ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន និងលោកចៅក្រមជាតិ និងចៅក្រមអន្តរជាតិ ។ ខ្ញុំជាមេធាវីជាតិ សូមអនុញ្ញាត លោកប្រធាន និងលោកចៅក្រមជាតិ និងចៅក្រមអន្តរជាតិ មេត្តាទទួលស្គាល់លោកស្រី ម៉ារី ប៉ូលកានីហ្សារ៉េស ដែលជាសមាជិកគណៈមេធាវីនៃទីក្រុងម៉ុងប៉ូលលីយេ ប្រទេសបារាំង គាត់បានស្បថនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅចំពោះមុខព្រះរាជអាជ្ញាសាលាឧទ្ធរណ៍កាលពីថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ ។ ហេតុនេះ សូមលោកប្រធាន ក៏ដូចជាលោកចៅក្រមជាតិ និងចៅក្រមអន្តរ-ជាតិ មេត្តាទទួលស្គាល់លោកស្រី ម៉ារី ប៉ូលកានីហ្សារ៉េស ជាសហមេធាវីការពារឲ្យ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចាប់ពីពេលនេះតទៅ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រោកឈរ មេធាវី ម៉ារី ប៉ូលកានីហ្សា ។

មេធាវី ម៉ារី ប៉ូលកានីហ្សា អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ លោកស្រី ធ្វើជាមេធាវីការពារក្តីឲ្យជនជាប់ចោទ សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ដោយយោងតាមការទទួលស្គាល់នេះ លោក លោកស្រីៗមានសិទ្ធិនិងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិដែរ ចាប់ពីពេលនេះតទៅ ។

សូមអង្គុយ អង្គុយចុះ ។

ជាកិច្ចបន្ត អង្គសវនាការ ផ្តើមធ្វើការសវនាការស្តាប់ចម្លើយសាក្សី ឈ្មោះ ហ្វ្រង់ស្វ័រ ប៊ីហ្សូ ។

មន្ត្រី តុលាការចាត់ការអញ្ជើញសាក្សីរូបនេះ ចូលមកកាន់បន្ទប់សវនាការ ។

*(សាក្សីទី១ TC-1:លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ ចូលមកកាន់បន្ទប់សវនាការ)*

[១៣:៤១:២២]

**លោក រ៉ូប៊ីត ពេទីត៖**

សូមអត់ទោស លោកប្រធាន ។ តើនេះជាគោលបំណងរបស់អង្គជំនុំជម្រះ ដើម្បីឲ្យសាក្សីមកផ្តល់សក្ខីកម្ម ចំពោះមុខគ្រប់ករណីទាំងអស់ ឬក៏សុំឲ្យជនជាប់ចោទអង្គុយនៅខាងក្រោយមេធាវីគាត់វិញ ឬយ៉ាងម៉េច? ខ្ញុំសូមបំភ្លឺ ការបំភ្លឺ ពីអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកសហព្រះរាជអាជ្ញា ។ អម្បាញ់មិញនេះ យើងមានកិច្ចនីតិវិធីមួយ ដែលត្រូវសួរគាត់អំពីសិទ្ធិនៃការទទួលនូវមេធាវីរបស់គាត់ ហើយអរគុណនូវការរំឭកនេះ ដោយសារមិនមែនជាគោលការណ៍ទេ ប៉ុន្តែដោយសារ ជាកិច្ចដែលត្រូវធ្វើបន្ទាន់ ។

អ៊ីចឹង គឺអនុរក្សមន្ទីរឃុំឃាំង គឺអាចនាំគាត់ទៅកាន់កន្លែង ជនជាប់ចោទ ដែលបម្រុងទុកនៅក្រោយមេធាវីរបស់គាត់វិញ ។

លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ នៅសវនាការនាពេលនេះ អង្គជំនុំជម្រះអញ្ជើញលោកមកផ្តល់សក្ខីកម្មអំពីអ្វី ដែលលោកបានដឹង បានឮបានឃើញពាក់ព័ន្ធជាមួយនឹងអង្គហេតុម-១៣ ដែលមានទីតាំងឋិតនៅអមលាំង ឃុំអមលាំង ស្រុកស្តូង ខេត្តកំពង់ស្ពឺ ហើយនៅក្នុងអំឡុង ក្នុងអំឡុងឆ្នាំ១៩៧១ ។

**ស៖** ហើយជាដំបូងនេះ អង្គជំនុំជម្រះ សូមសួរទៅលោកថា តើលោកឈ្មោះ ហ្វ្រង់ស័រ ប៊ីហ្សូ ដូច្នេះ មែនទេ?

**សាក្សី TC-1៖**

**ឆ៖** បាទ! ខ្ញុំឈ្មោះ ហ្វ្រង់ស្វ័រ ប៊ីហ្សូ មែន ។

**ស៖** តើលោកមានអាយុប៉ុន្មានហើយ?

**ឆ៖** ខ្ញុំបានធ្វើការនៅសាលាបារាំង ខ្ញុំអាចចាប់ផ្តើមនិយាយឥឡូវបានទេលោកប្រធាន? សូមអត់ទោស ។

**ស៖** អង្គជំនុំជម្រះ ចាប់ផ្តើមសួរសំណួរតែប៉ុន្មានទេ ពាក់ព័ន្ធជាមួយនឹងពិនិត្យអត្តសញ្ញាណសាក្សី ដូច្នេះ សូមលោកស្តាប់សំណួររបស់ខ្ញុំ ដើម្បីបានយល់អំពីអត្តសញ្ញាណនេះ ។

សំណួរបន្ទាប់ ខ្ញុំសួរថា តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

[១៣:៤៥:០៥]

**ឆ៖** ខ្ញុំអាយុ៦៩ឆ្នាំ ។

**ស៖** តើលោកមានសញ្ជាតិអ្វីដែរ?

**ឆ៖** ខ្ញុំសញ្ជាតិបារាំង ។

**ស៖** លោកមានទីលំនៅបច្ចុប្បន្នហ្នឹង នៅឯណា?

**ឆ៖** ឥឡូវនេះ ខ្ញុំរស់នៅឈាងម៉ៃ នៅក្នុងប្រទេសថៃ នៅភាគខាងជើង ។

**ស៖** លោកប្រកបអ្វីដែរសព្វថ្ងៃ?

**ឆ៖** ខ្ញុំជាអ្នកស្រាវជ្រាវ ហើយជាសាស្ត្រាចារ្យ ហើយគឺជាសមាជិកនៃសាលាបារាំងមួយ ។

**ស៖** យោងតាមរបាយការណ៍របស់ក្រឡាបញ្ជីថា លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ មិនមានចំណងជាញាតិ លោហិត ជាពន្ធ ឬក៏ជាសហព័ទ្ធជាមួយភាគីក្នុងសំណុំរឿងក្តីនេះ ពិតមែនទេ?

**ឆ៖** នេះជាការពិត ខ្ញុំមិនមានទំនាក់ទំនងសាច់ញាតិអ្វីជាមួយ-- ទាក់ទងទៅនឹងបញ្ជីរាយឈ្មោះដែលខ្ញុំបានទទួលមើលនោះទេ ។

**ស៖** លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ ក្នុងនាមលោកជាសាក្សី អង្គជំនុំជម្រះសូមឲ្យលោកធ្វើសម្បថជាមុន មុននឹងផ្តល់សក្ខីកម្ម ។ តើលោកយល់ព្រមទេ?

[១៣:៤៧:០៧]

**ឆ៖** ខ្ញុំឯកភាព ខ្ញុំយល់ព្រម ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជី សូមក្រឡាបញ្ជីយកពាក្យសម្បថប្រគល់ទៅឲ្យសាក្សីរូបនេះជាភាសាបារាំង ។

**សាក្សី TC-1៖**

**ឆ៖** ខ្ញុំនិយាយតែការពិត អ្វីដែលមិនពិត ខ្ញុំមិននិយាយ ហើយខ្ញុំនិយាយតែការពិត អ្វីដែលមិនពិត ខ្ញុំនឹងមិននិយាយ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ តើលោកពិតជាត្រូវបានកងទ័ពខ្មែរក្រហម ចាប់លោកនៅវត្តអូរនៅឧដុង្គ និងនាំខ្លួនលោកយកទៅឃុំឃាំងនៅមន្ទីរសន្តិសុខ ម-១៣ ដែលមានទីតាំងស្ថិតនៅអមលាំង ស្រុកថ្ពង ខេត្តកំពុងស្ពឺ ក្នុងអំឡុងឆ្នាំ១៩៧១ ពិតមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោកចៅក្រម ។

**ស៖** លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ តើលោកអាចនិទានរៀបរាប់អំពីទិដ្ឋភាពជាក់ស្តែង ដែលលោកបានឃើញ បានដឹងឮនៅមន្ទីរម-១៣ ដែលមានទីតាំងស្ថិត ដូចយើងបានជម្រាបខាងលើ ក្នុងអំឡុងពេលដែលលោកបានត្រូវបានចាប់ខ្លួននាំយកទៅឃុំឃាំងនៅទីនោះ រហូតដល់ពេលលោកត្រូវដោះលែង និងបានវិលត្រឡប់មកកាន់ទីក្រុងភ្នំពេញកាលណោះ ។

**ឆ៖** ពិតហើយលោកចៅក្រម។ ប៉ុន្តែ ខ្ញុំសូមចាប់ផ្តើមសក្ខីកម្មរបស់ខ្ញុំ ដោយការបញ្ជាក់អំពីនៅរឿងរ៉ាវមួយរហូតដល់ចុងបញ្ចប់ហ្នឹង គឺថារហូតដល់ពេលដែលខ្ញុំត្រូវបានដោះលែងនោះ នៅក្នុងខែធ្នូ ឆ្នាំ៧១ ជនជាប់ចោទ "ឌុច" បានរៀបចំពិធីលាគ្នាមួយ អាហារថ្ងៃត្រង់ទៅដល់អ្នកជាប់ឃុំឃាំងជាមួយខ្ញុំដែលបានចាប់ចំណងនៅឡើយ ។ ហើយយើងមានស្ងោរស៊ុបសាច់មាន់ដែលបានរៀបចំ ។ ហើយសូមអរគុណដែលគាត់បានឲ្យលុយមកវិញ ដែលគេបានដកហូតពីខ្ញុំ ដើម្បីយកទៅទិញចំណីអាហារនោះ ។ គឺជាលុយបន្តិចបន្តួច ដែលខ្ញុំអាចចំណាយសម្រាប់ការជប់លៀងលាគ្នានោះ ។ អ្នកផ្សេងទៀត ក៏បានមកជួបខ្ញុំ គេបានជួបបារាំង ខ្ញុំបកប្រែ គឺថា "សមមិត្តបារាំង" សូមកុំភ្លេចយើងឲ្យសោះពេលដែលលោកទៅនោះ ។

ថ្ងៃនេះ គឺជា ឌុច គឺជាជនជាប់ចោទ ។ គាត់នោះហើយ គឺជាអ្នកដែលដាក់បញ្ជាឲ្យមានការដាក់ខ្នោះ ដាក់ច្រវ៉ាក់អ្នកទាំងនោះ ។ ហើយក្នុងកាលៈទេសៈនេះ គឺថាខ្ញុំចងចាំពីអ្នកទោសនៅម-១៣ ខ្ញុំមិនអាចបំភ្លេចពួកអ្នកទាំងនោះបានទេ ហើយជាពិសេស ជាអ្នកជំនួយការពីរនាក់របស់ខ្ញុំ ហុក ឡាយ ហើយនឹង បាំង សុន ដែលត្រូវបានសម្លាប់នៅក្នុងមន្ទីរឃុំឃាំងខុសគ្នាពីរ ពីព្រោះថាដោយសារអ្នកទាំងពីរនោះធ្វើការឲ្យខ្ញុំ ។

[១៣:៥១:០៩]

នៅក្នុងនាមអ្នកទាំងពីរនាក់នោះហើយ ហើយនិងក្នុងនាមអ្នកជនរងគ្រោះទាំង អស់នោះ ខ្ញុំសូមអនុញ្ញាតនឹងផ្តល់សក្ខីកម្មថ្ងៃនេះ ដើម្បីបំភ្លឺការនិយាយបែបនេះ ដែលថាពីរបីមីនុតខាងដើមនោះ នៅក្នុង

បរិបទនៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំអំពីពុទ្ធសាសនាកម្ពុជា ។ ខ្ញុំទៅកាន់តំបន់ឧដុង្គ តំបន់មួយនៅឧដុង្គ ហើយខ្ញុំបានទៅធ្វើការនៅខាងអង្គការអភិរក្សអង្គរ ហើយខ្ញុំក៏ត្រូវគេចតំបន់នោះ ដោយសារមានការឈ្លានពានទឹកដី ហើយខ្ញុំបន្តការស្រាវជ្រាវរបស់ខ្ញុំនៅក្នុងខេត្តកណ្ដាល ។

នៅថ្ងៃទី១០ ខែតុលា ខ្ញុំបានចាប់ផ្ដើម ហើយខ្ញុំបានធ្វើដំណើរទៅខាងភូមិភាគ ខាងជើងឧដុង្គ ទៅវត្តអារាមមួយ ដែលហៅថា “វត្តអូរ” នៅជិតភូមិទួលតាពី ។ ខ្ញុំទៅដល់កន្លែង ដោយបានប្រើរថយន្តតូចមួយ អំពីសាលា *អេកូលហ្វ្រង់ស្វ័រ ដូលីយ៉ង់* ដូចជាមានកូនស្រីខ្ញុំឈ្មោះ អេឡែន គឺថាអាយុច្រើនជាង២ឆ្នាំ ពេលនោះ ហើយនិងអ្នកជំនួយការ២នាក់របស់ខ្ញុំ ដែលខ្ញុំបានបញ្ជាក់ឈ្មោះខាងដើម ហើយក៏មាន អ្នកភូមិពីរ-បីនាក់ទៅជាមួយផងដែរ ។ គំនិតនោះ គឺថាដើម្បីឲ្យគេបង្ហាញផ្លូវយើងទៅកាន់វត្តអូរនោះ ហើយយើងបាន-- ចៅអធិការនៅវត្តនោះបានទទួលយើង ហើយនិងព្រះសង្ឃមួយចំនួន ហើយខ្ញុំគិតថា ពេលនោះ គឺថាៗរឿងមិនមែនធម្មតាទេ ហើយម្នាក់ៗមានការភ័យខ្លាចហើយខ្ញុំគិតថា វាមានលក្ខណៈដូចជា *អំបូស្កាត* គឺការឡោមព័ទ្ធហើយមានការឃាមត្បាតដោយឈ្លប ហើយភ្លាមៗនោះក៏គេបានមកសង្កេតយើងដោយពួកអ្នកឈ្លានមកជួបយើង ហើយក៏បានចាប់យើងចងស្លាបសេក ហើយខ្ញុំបានតទល់ កុំឲ្យចងដៃខ្ញុំហើយខ្ញុំទាមទារថា ប៉ុន្តែខ្ញុំបានស្នើសុំជួបអ្នកដែលទទួលខុសត្រូវ ហើយគេយកយើងទៅកាន់ទួលតាពី ដែលគេទុកយើងនៅទីនោះ២ម៉ោង ។ នៅក្នុង២ម៉ោងនោះ គេបានសួរយើងដោយកម្មាភិបាលទទួលបន្ទុកមួយ ជាពិសេសយើងបានទាក់ទងទៅរឿងដែលយើងទៅវត្ត ទាក់ទងទៅនឹងពិធីបុណ្យ ឬក៏ពិធីសាសនា ពុទ្ធសាសនាមួយ យើងចង់សិក្សា ។ ហើយនៅក្នុងពេលខ្ញុំពន្យល់ចប់ ហើយគេបានយោង ហើយគេហៅថា ខ្ញុំជាភ្នាក់ងារ *ស៊ីអាយអេ* ជា *សេអ៊ីអា* ហើយប្រហែលគេរកមេក្រូហើយគេរកប្រដាប់ថតសំឡេង ហើយខ្ញុំបានយកអ្នកជួយខ្ញុំទៅឆ្ងាយទៅកាន់ផ្សេង ហើយក៏បានចងអ្នកទាំងហ្នឹងទៅដែរ ។

[១៣:៥៤:៣៩]

គេក៏បានយកខ្ញុំចេញទៅនៅក្នុងរថយន្តមួយ ។ គឺជា ហើយមានអ្នកយាមពីរនាក់ក្មេងៗសន្តិសុខពីរនាក់ដែលមានអាវុធទៅជាមួយខ្ញុំផងដែរ ។ យប់ទីមួយ យើងនៅក្នុងកន្លែងសាលាមួយនៅជិតភូមិផល នៅព្រឹកបន្ទាប់នោះ ខ្ញុំបានទៅដល់ភូមិមួយដែលខ្ញុំមិនចាំឈ្មោះទេ ។ នៅទីនោះខ្ញុំ បានជួបសហសេវិកខ្ញុំពីរនាក់នៅកន្លែងហ្នឹង ហើយដែលថាឃើញជើងរបស់គេត្រូវបានជាប់ខ្នោះរួចទៅហើយ ។ គឺខ្នោះឈើ គឺជាប្រព័ន្ធខ្នោះមួយដែលយើងមានរបាររឈើពីរ ដោយមានឈើដែលគេឆ្កៀល ដែលអាចនឹង

ចាក់ភ្ជាប់កជើងទៅនឹងរបារនោះ ហើយខ្ញុំគេដាក់ខ្នោះខ្ញុំជាប់ជាមួយអ្នកទីនោះនៅក្នុងជួយជាមួយគ្នា ។ ជួនកាលគេវាយដំយើង ។ ហើយយើងឃើញមានពួកអ្នកខ្លះជាពួកខ្មែរក្រោម ហើយមានអ្នកកត់ត្រាមួយចំនួន នៅពេលដែលខ្ញុំនិយាយគេមានកត់ត្រា ។ ហើយគេហៅថា “តុលាការប្រជាជន” មានអ្នកភូមិ ៥០នាក់ នៅខាងក្រោយខ្ញុំ ហើយនិងនៅសងខាងខ្ញុំនោះផងដែរ ។

អ្នកដែលសួរខ្ញុំនោះ គឺៗអង្គុយផ្អែកនៅលើតុមួយនៅក្នុងនោះ គាត់ថាស្គាល់ខ្ញុំ ហើយគាត់ថាគាត់បានជួបខ្ញុំនៅ *សាយហ្គន* ហើយគាត់ថាផ្អែបម្រើរបស់ *សេអ៊ីអា* អាមេរិកគឺថាត្រូវតែចេះភាសាខ្មែរល្អ ហើយនិងភាសាអង់គ្លេសល្អ ហើយជាអ្នកផ្តល់លុយកាក់ទៅឲ្យអ្នកណា ដែលធ្វើការប្រយុទ្ធប្រឆាំងក្នុងនាមអាមេរិកាំង ។

ជាធម្មតាខ្ញុំបដិសេធការចោទប្រកាន់នោះ ដែលថាមិនមានន័យអ្វីទេ ។ ហើយខ្ញុំសួរថា តើលោកប្រាកដទេលោកចង់សម្លាប់ខ្ញុំទៅពេលនេះ? ខ្ញុំសួរទៅអ៊ីចឹង ដែលធ្វើឲ្យអ្នកនៅពីខាងក្រោយខ្ញុំទាំងអស់ហ្នឹង គឺថាគេគាំទ្រនឹងសម្តីនោះ បន្ទាប់ពីហេតុការណ៍នោះមក ។ ខ្ញុំនឹងសង្ខេបរឿងហ្នឹងបន្តិច មិនបានទាំងស្រុង ទាំងអស់ទេ ។ អ្នកសួរនោះ គឺថាមានការខ្វែងគ្នាអ្វីដែលអង្គការបានដឹង រួចហើយអ្វីដែលខ្ញុំទើបតែឆ្លើយអម្បាញ់មិញនោះ ។ គឺថាជាលទ្ធផលនោះ គឺថាគេចាត់ទុកខ្ញុំថាជាអ្នកដែលមានជាអ្នកជនជាប់ចោទចំពោះបទល្មើសដែលខ្ញុំមិនដឹងថាគេចោទពីអ្វីទេ ។ ភ្លាមនោះគេដាក់ក្នុងខ្នោះឡើងវិញ ជាមួយនឹងសហការីខ្ញុំពីរនាក់ទៀត ហើយដោយបានឮថា ឮសំឡេងដែលបានស្រែកនៅជុំវិញផ្ទះដែលថាមនុស្សមួយចំនួន ។ ថាតើអ្នកឯងចាំអីម៉េច មិនសម្រាតខោអាវគាត់ហើយសម្លាប់គាត់ហ្នឹងទៅ? ដែលពេលនោះ គឺថាខ្មែរក្រហម គេបានចេញមុខមក ហើយចងមុខខ្ញុំ ហើយក៏យកខ្ញុំទៅចេញកន្លែងមួយ ទៅកន្លែងមួយ ដែលគេនឹងបម្រុងសម្លាប់ខ្ញុំមិនដឹងថា តើជាការសម្លាប់និងថាជាការឬក៏របៀបម៉េច?

ប៉ុន្តែផ្ទុយទៅវិញ គឺខ្ញុំគេមិនបានសម្លាប់ខ្ញុំទេ ។ គេបានដឹកខ្ញុំតាមឡានមួយនៅព្រឹកបន្ទាប់នោះ ហើយខ្ញុំក៏បានទៅដល់ម-១៣ ដោយមិនបានយកខ្មែរពីរនាក់ជាសហការីខ្ញុំទៅជាមួយផងទេ ដូចជាលោកឡាយ ហើយនិងលោក សុន នោះ ។

ខ្ញុំបានទៅដល់កន្លែងនោះ គឺគេក៏មកជាប់ចោទជាមួយខ្ញុំ គេចោទពីបទល្មើសដូចគ្នា នៅពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំមិនមានទស្សនៈយល់ដឹងពីកន្លែងនោះទាំងស្រុងទេ ។ ប៉ុន្តែប្រធាននៅកន្លែងនោះដែលគាត់បង្ហាញខ្លួនថា គាត់គឺជាអ្នកដែលឃោរឃៅ ដែលជាអ្នកចេញបញ្ជានៅកន្លែងនោះ ។ ដែលចាកជើងរបស់ខ្ញុំមួយត្រូវបានដាក់ជាប់ខ្នោះនៅចុងរបារមួយ ដែលមានរបារដែក ដែលមានអ្នកទោស

ប្រហែល១០ ឬ១៥នាក់ នៅនោះរួចជាស្រេច ។ ពេលនោះខ្ញុំមានការភ័យខ្លាចណាស់មិនមែនដោយសារ តែគំនិតដែលបានឃើញនោះទេ ក៏ប៉ុន្តែដោយសារស្ថានភាព គឺថាខ្ញុំនៅចុងខ្នោះពេលហ្នឹង ដោយបាន-- ។ ហើយខ្ញុំក៏មានឆ្អឹងធំផង ដាក់ទៅវាវិតឃើ កជើងរបស់មិនអាចដាក់ចូលទៅក្នុងរង្វង់ខ្នោះនោះបាន ។ ហើយប្រធាននោះ បានការណែនាំគឺថា យកខ្នោះណាមួយទៀតដែលមានទំហំធំ ដែលអាចដាក់ក ជើងខ្ញុំបាន ។ ហើយពេលនោះ គេក៏បានយកកងមួយនោះ គឺថាក្មេង-- បុរសក្មេងម្នាក់បានមក-- នៅ ពេលដែលអ្នកនោះបានមកដល់ ខ្ញុំបាននិយាយថា គេបានរកខ្នោះមួយដែលថា ដែលអាចនឹងដាក់ខ្នោះធំ ទំហំជើងរបស់ខ្ញុំគឺថា ខ្ញុំក៏បានដាក់ខ្នោះជាប់ហើយដេកផ្ទាល់នឹងដី ។ ហើយយើងមិនបានដើរទៅណា ហើយយើងពេលខ្លះគេឲ្យយើងហ្នឹងដើរកាត់ភក់ គឺថាភក់នោះក៏បានសើមដោយភ្លៀង ។ ហើយខ្ញុំបាន ទទូចថា ហើយខ្ញុំត្រូវចំពេល-- ប្រើពេលប្រាំមីនុត ដើម្បីមុជទឹកនៅក្នុងទឹកស្ទឹង ហើយគឺថា បុរសក្មេង ម្នាក់ហ្នឹង-- នៅក្នុងភាសាខ្មែរថា តើលោកចង់ងូតទឹកទេ?

[១៤:០១:៥៩]

ហើយខ្ញុំអាចទៅចុះងូតទឹកបាន អ៊ីចឹងហើយ គឺថាមនុស្សដែលខ្ញុំបានជួបពីដំបូងនោះ គឺថាមាន ម្នាក់លើគាត់ ដែលថាមានសមត្ថភាព ដែលអាចនឹងនិយាយប្រឆាំងនឹងបញ្ហារបស់គេបាន ប៉ុន្តែប្រធាន ដំបូងដែលខ្ញុំស្នើសុំនោះ គេបានបដិសេធទាំងអស់ ។ ប៉ុន្តែក្រោយមក គេបានអនុញ្ញាតឲ្យខ្ញុំទៅងូតទឹក ។ បញ្ហាខ្នោះរបស់ខ្ញុំហ្នឹង គឺមិនទាន់បានដោះស្រាយរួចទេ គឺថាបុរសក្មេងម្នាក់នោះគឺថាបានអនុញ្ញាតឲ្យ ជូនខ្ញុំទៅងូតទឹក ហើយក៏ឲ្យនាំទៅកន្លែងមួយទៀតនៅខាងក្រៅ ។ នៅក្រៅផ្ទះបី ដែលនៅក្នុងនោះ មានទោសមួយចំនួនត្រូវបានដាក់នៅកន្លែងនោះ ប្រហែល៤០ ទៅ៥០នាក់ ហើយខ្ញុំក៏-- ខ្ញុំគេបាននាំខ្ញុំ ទៅជ្រកនៅក្រោម គឺកន្លែងដែលសង់ពីឫស្សីមួយមានដំបូល ដូចជាឃ្លាំង គឺនៅក្បែរហ្នឹងនៅនឹងមន្ទីរ នោះ ។ ជារៀងរាល់សប្តាហ៍ដែលគេដឹកសម្ភារមកដាក់កន្លែងនោះ មានស្រូវអង្ករជាដើមនោះ ។ ហើយ នៅក្នុងរោងហ្នឹងជាកន្លែងដែលខ្ញុំ-- គឺមានស្រូវបីបាវនៅកន្លែងហ្នឹង គឺជើងរបស់ខ្ញុំត្រូវបានចាក់សោដាក់ ច្រវាក់ភ្ជាប់ទៅនឹងបង្គោលឫស្សីមួយដែលជាសសរខ្ទមរោងនោះ ។ ខ្ញុំនៅកន្លែងហ្នឹងក្នុងមួយរយៈពេល ដែលថា វាមានភ្លៀងផង ពេលនោះក៏យប់ធ្លាក់មកដល់ ហើយគេយកម្ហូបអាហារមកឲ្យខ្ញុំហូបគឺអ្នក យាមក្មេងម្នាក់គឺថា ហូបនៅកន្លែងនោះ ។ នោះគឺជាយប់ទី១ ដែលខ្ញុំបានទៅដល់ជំរំនោះ ទៅដល់មន្ទីរ នោះ ។

[១៤:០៤:១១]

ថ្ងៃបន្ទាប់ខ្ញុំបានយល់បន្តិចថែមទៀត អំពីមនុស្សម្នាក់ដែលខ្ញុំបាន-- ដែលខ្ញុំគិតថា ជាប្រធាននៃមន្ទីរនោះ ។ ខ្ញុំក៏បានដឹងពីនាក់យាមនោះថា ឈ្មោះរបស់គាត់នោះគឺ ឌុច ដោយហេតុថា គេនិយាយរឿងគាត់នោះ តែគេនិយាយថា ឌុចៗ ។

ខ្ញុំនិយាយបញ្ជាក់ដោយសង្ខេបបន្តិចទៀត គាត់បានធ្វើសេចក្តីសម្រេចហើយក៏ធ្វើការសួរចម្លើយដោយខ្លួនឯង ហើយគាត់បាននិយាយមកកាន់ខ្ញុំថា “គឺថាមានបទចោទប្រឆាំងនឹងខ្ញុំ គឺជាបទចោទធ្ងន់ណាស់” ហើយខ្ញុំត្រូវគាត់សរសេរនៅសេចក្តីប្រកាសថា “ខ្លួនមានទោស ឬគ្មានទោស” ហើយខ្ញុំបានសរសេរសេចក្តីថ្លែងការណ៍មន្ទីរមួយដែលខ្ញុំទៅដល់ដំបូង ដែលថាខ្ញុំយល់ថា ប្រហែលជាខ្ញុំមិនអាចត្រឡប់វិញក្រោយទេមើលទៅ ។

ហើយអ្នកយាមក្មេងម្នាក់ ដែលថា ខ្ញុំនៅទីនោះមួយថ្ងៃទៅមួយថ្ងៃជាអ្នកតាមពីក្រោយខ្ញុំរហូតទៅណាក៏តាម គឺគេជាក្មេង គេមានអត្តចរិត គឺថាកោងកាច គេនិយាយ-- ប៉ុន្តែខ្ញុំក៏អាចយល់បានអ្វីដែលគេនិយាយដែរ ហើយក៏ថាអាចយល់ថា តើខ្ញុំអាចនឹងដឹងថាចង់បានអ្វីពីគេ? ចង់ដឹងអ្វីពីគេ? អ៊ីចឹងគេនិយាយអ៊ីចឹងការសួរចម្លើយក៏ចេះតែបន្តទៅ ។ ហើយមានតែប្រធានមន្ទីរនោះ ហើយនិងខ្ញុំទេដែលគាត់ជាអ្នកសួរ ហើយគាត់សួរសំណួរអំពី-- គាត់និយាយដោយមានភាពគួរសមពីដំបូងនោះ ។ ហើយខ្ញុំក៏បាននិយាយដោយខ្លួនឯងចេញពីអំពីកំហឹងដែលលាក់បង្កប់ដោយសម្បជញ្ញៈ ។ ប៉ុន្តែ ខ្ញុំបង្ហាញថាខ្ញុំមិនខឹងទេ ។

នៅក្នុងស្ថានភាពដែលអយុត្តិធម៌បែបនោះ ដែលខ្ញុំម្នាក់ឯង ហើយដែលធ្វើឱ្យគេគិតថាៗ ខ្ញុំជាគិញរបស់ *សេអ៊ីអា* តែតាមពិតនោះខ្ញុំមិនមែនសោះ ។ ហើយគេបាននាំខ្ញុំទៅតំបន់មួយដែលថា ជាតំបន់បះបោរដើម្បីឆ្លើយសួរសំណួរ ។ ហើយខ្ញុំក៏សួរសំណួរត្រឡប់ទៅគាត់វិញ ហើយការសួរតបទៅវិញនោះគឺថា សួរចម្លើយនោះពីរមួយសប្តាហ៍ទៅមួយសប្តាហ៍ទល់មុខគ្នាវែងអន្លាយ ។ អ៊ីចឹងហើយវាកើតទៅជាទម្លាប់មួយដែលបានកំណត់ ដូចដែលខ្ញុំបញ្ជាក់ដែលថាៗ ដែលបង្កើតនូវ-- មិនមែនជាមិត្តភាពទេ ប៉ុន្តែជាការស្គាល់គ្នា យល់គ្នា ។ បើខ្ញុំចាំមិនច្រឡំទេនោះ ខ្ញុំជារៀងរាល់សប្តាហ៍ ខ្ញុំត្រូវរាយការណ៍ ហើយគាត់ត្រូវធ្វើរាបាយការណ៍ ហើយគាត់កត់ត្រានូវពេលយប់យូរ ហើយក៏ព្រឹកឡើងនឹងបញ្ជូនទៅកន្លែងមួយទៀត ។ ហើយគាត់មានកិត្តិសព្ទមួយ គឺថាជាបុគ្គលិកធ្វើការច្រើន ប៉ុន្តែមិននិយាយច្រើនទេ ។ អ្នកផ្សេងគេនិយាយថា អ៊ីចឹង ។ អ៊ីចឹងហើយគាត់មានការលះបង់ចំពោះតួនាទីក្នុងឋានៈជាប្រធានមន្ទីរនោះ ។

[១៤:០៨:០៨]

ការសួរចម្លើយមកលើខ្ញុំនោះ តែងតែកើតឡើងតាមរបៀបមួយដែលទន់ភ្លន់គួរសមទេ គឺមិនវាយដំខ្ញុំទេ ។ ពេលខ្លះ ឌុច យល់ថា ប្រសិនបើគាត់យល់ថា ខ្ញុំជាភ្នាក់ងារ *សេអ៊ីអា* នោះគាត់នឹង-- ប្រហែលជាគាត់នឹងវ៉ៃខ្ញុំ ប៉ុន្តែគាត់និយាយ និងនិយាយប្រឆាំងខ្ញុំ ប៉ុន្តែក្នុងរបៀបមួយ ដើម្បីៗឲ្យយល់-- ដែលគាត់សួរសំណួរអំពីខ្ញុំ អំពីការងាររបស់ខ្ញុំ អំពីការអភិរក្សអង្គរ អំពីពុទ្ធសាសនា អំពីលទ្ធិពុទ្ធសាសនាកម្ពុជា ដែលអ្នកមិនសិក្សាមិនយល់ច្បាស់ដូចខ្ញុំហ្នឹង ។ ខ្ញុំផ្តល់ពន្យល់អំពីគោលជំហររបស់ខ្ញុំឲ្យច្បាស់លាស់ពីការងារ អំពីគោលបំណងដែលខ្ញុំបានបញ្ជាក់ដែរថាតាមពិត ខ្ញុំពិតជាមានគុណសម្បត្តិជាបញ្ញវន្តខាងពុទ្ធសាសនា នេះសមត្ថភាពដែលខ្ញុំត្រូវបង្ហាញដើម្បីប្រកាន់ជំហរ ជាបញ្ញវន្តដែលធ្វើការអំពីគម្ពីរសាសនា ពុទ្ធសាសនាហ្នឹង ។ ប្រសិនបើខ្ញុំអាចនិយាយអំពី *(ឮមិនច្បាស់)* ខ្មែរសៀវភៅ ដើម្បីកត់សម្គាល់នោះ ដែលមានឲ្យសៀវភៅមួយ ហើយនិងប្រដាប់សម្រាប់ចិតខ្មៅដៃមួយ ។ អ៊ីចឹងគឺថា ខ្ញុំចង់កោពុកមាត់ណាស់នៅពេលនុ៎ង ។

លោកចៅក្រមខ្ញុំមានសៀវភៅនេះហើយខ្ញុំអាចបង្ហាញលោកចៅក្រមអំពីគម្របសៀវភៅកំណត់សម្គាល់នេះ ។

*(បង្ហាញសៀវភៅតាមស្លាយ)*

[១៤:១១:៤៥]

អ៊ីចឹងខ្ញុំចង់បង្ហាញលោក លោកស្រីចៅក្រមអំពីចំណុចខ្លះនៅក្នុងសៀវភៅកំណត់ហេតុនេះដែល ឌុច បានឲ្យមកខ្ញុំ ហើយដែលខ្ញុំបានសរសេរ ហើយខ្ញុំបានសរសេរអំពីការចងចាំកាលពីនៅក្មេងខ្លះអំពីកំណាព្យមួយចំនួន ហើយខ្ញុំព្យាយាម-- ។ បើសរសេរអំពីចំណុចខ្លះដែលធ្វើឲ្យមានការជឿជាក់ថាអំពីកិច្ចការរបស់ខ្ញុំជាមួយនឹងខាងសាសនាព្រះពុទ្ធនោះ ហើយអំពីការសិក្សារបស់ខ្ញុំ ។ ហើយក្រោយមកទៀត ជាការច្បាស់ណាស់ដែលខ្ញុំនឹងត្រូវបានដោះលែង ឌុច បានសួរមកខ្ញុំថា-- ហើយតើខ្ញុំអាចទុកសៀវភៅកំណត់ហេតុនឹងបានទេ? គាត់ថាបាន នឹងអាន ហើយនឹងសម្រេចចិត្តនៅបន្ទាប់មកទៀត ។ ហើយនិងអានសៀវភៅកំណត់ហេតុរបស់ខ្ញុំដោយយកចិត្តទុកដាក់បំផុត ហើយបានសួរខ្ញុំអំពីសំណួរខ្លះអំពីសៀវភៅហ្នឹង ។ ហើយគាត់ក៏បានពិនិត្យមើលផងដែរ ហើយក្រោយមកក៏បានប្រគល់មកវិញ បានជាលោក លោកស្រីចៅក្រមឃើញហើយ ខ្ញុំនៅមានសៀវភៅកំណត់ហេតុនេះនៅឡើយ ។

[១៤:១៣:០៣]

អ៊ីចឹងខ្ញុំនិយាយថា សៀវភៅកំណត់ហេតុដែលខ្ញុំយកមកជាមួយខ្ញុំនៅថ្ងៃនេះ គឺខ្ញុំមិនដែលអានវាឡើងវិញទេ ។ ឌុច ដូចដែលខ្ញុំបាននិយាយអ៊ីចឹង យ៉ាងហោចណាស់ក្នុងមួយអាទិត្យម្តង គឺថាគាត់មក គាត់មកពីភូមិ ឬក៏មកពីកន្លែងផ្សេង ហើយអ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលនោះ គឺថាពេលនុ៎ង ឌុច គាត់មានសុខភាពអត់ល្អសោះ ហើយភាគច្រើនពួកយើងនៅទីនុ៎ង ។ មិនមែនភាគច្រើនទេ គឺថា ពេលនោះខ្ញុំសំណាងហើយ ដែលថាខ្ញុំអត់បានឈឺនោះ ហើយពេលនុ៎ងមានគេសួរខ្ញុំពីរបីសំណួរដែរ អំពីស្ថានភាពសុខភាពរបស់ខ្ញុំ ហើយពេលហ្នឹងភរ ខ្ញុំហ្នឹងឈឺ ឬក៏អ៊ីចឹងទៅដើម្បីកុំឲ្យអ្នកជាប់គុកអស់ហ្នឹងគេមានការច្រណែនខ្ញុំ ។ ហើយប្រហែលជានៅខែវិច្ឆិកា ឬខែធ្នូ ហ្នឹងមានជំងឺគ្រុនចាញ់ច្រើនណាស់ ហើយពេលនុ៎ងគឺថា គ្រុនចាញ់ហ្នឹងហើយ គឺថាវាវាយលុកពេញជំរំហ្នឹងតែម្តង ។ ហើយអ្នកថា មិនបានស្លាប់ក្តីក៏ស្ថិតនៅក្នុងស្ថានភាពដែលថា អស់កម្លាំងល្វិតល្វៃបំផុតផងដែរ ។

ហើយថ្ងៃមួយ ឌុច បាននិយាយប្រាប់ខ្ញុំថា-- និងនៅថ្ងៃបន្ទាប់មកហ្នឹង ប្រហែលជាគាត់ៗនឹងមានដំណឹងល្អខ្លះសម្រាប់ឲ្យខ្ញុំដឹង ហើយអ៊ីចឹងហើយគឺថា ពេលហ្នឹងខ្ញុំរងចាំ-- ទន្ទឹងរង់ចាំបំផុត រង់ចាំដល់គាត់ត្រឡប់មកវិញនៅថ្ងៃបន្ទាប់នោះ ។ បន្ទាប់ពីគាត់ត្រឡប់មកវិញ គាត់បានឲ្យខ្ញុំដឹងៗថា ខ្ញុំអាចត្រឡប់ទៅជួបជុំគ្រួសាររបស់ខ្ញុំវិញបាន ។ ហើយនៅពេលដែលខ្ញុំបានដឹងដំណឹងនេះ ដំបូងខ្ញុំអត់ជឿសោះគឺថា លោក លោកស្រីចៅក្រម ត្រូវដឹងថា គឺថាគ្មានអ្វីដែលត្រូវបានគេនិយាយច្បាស់លាស់ទេ ដែលការភរកុហក គឺវាកើតមានជារាល់ថ្ងៃទៅហើយនៅទីនោះ មានអ្វីដែលគួរឲ្យជឿទេ ពីព្រោះអីអ្វីៗគឺជាការកុហកទាំងអស់ ។ នៅពេលដែលយើង យើងពេលហ្នឹង ដូចថាចង់យកអ្នកណាទៅសម្លាប់ហ្នឹងក៏មិននិយាយពិតដែរ ការពិតដែរ គឺថាការភរកុហកគេហ្នឹងឯង ។

[១៤:១៥:៤៥]

អ៊ីចឹង ការសន្យាឲ្យផ្តល់សេរីភាពមកវិញឲ្យខ្ញុំហ្នឹង គឺថាខ្ញុំអត់ជឿទេ ។ ពីព្រោះតាំងតែពី ដូចដែលខ្ញុំបាននិយាយអ៊ីចឹងថា ខ្ញុំអត់មានភស្តុតាងអ្វី ដើម្បីបង្ហាញពីភាពសុចរិតត្រឹមត្រូវរបស់ខ្ញុំទេ ។ ហើយគាត់ក៏អត់មានភស្តុតាងអ្វី អំពីពិរុទ្ធភាពរបស់ខ្ញុំដែរ ។ អ៊ីចឹងបន្ទាប់ពីនិយាយអ៊ីចឹងហើយហ្នឹង ឌុច គាត់មិនដែលបានចាកចេញពីខ្ញុំទេ ។ ប៉ុន្តែ សេចក្តីសង្ឃឹមគឺថានៅមានជានិច្ច ចំពោះអ្នកគុកនោះ ។ ប៉ុន្តែនៅពេលដែលដំណាលគ្នានោះដែរ ខ្ញុំក៏បានយល់ដឹងថា ជីវិតរបស់ខ្ញុំគឺនៅក្នុងកណ្តាប់ដៃរបស់គាត់ មិនមែនគ្រាន់ជីវិតរបស់ខ្ញុំនោះទេ គឺអ្នកដទៃទៀតផងដែរ ។ អ៊ីចឹង គឺនៅពេលដែលគាត់និយាយថា ខ្ញុំនឹងត្រូវបានគេដោះលែងនោះ គឺជារឿងមួយដែលដូចថាខ្ញុំមិនជឿសោះៗ ហើយមិនមែនធ្វើឲ្យខ្ញុំសប្បាយ

លោតកញ្ចេងទេនៅពេលនោះ ។ ប៉ុន្តែ ពេលនោះ ថាបើអ៊ីចឹងមែន ឥឡូវបង្ហាញមើល ដោះលែងខ្ញុំ យកដោះខ្នោះចេញទៅ ពីព្រោះអីខ្នោះហ្នឹងគឺថាគឺថាកៀបខ្ញុំឈឺណាស់ ។ ហើយពេលនោះ ពិតហើយ គឺថាគាត់ចេញបញ្ជា បាននៅកន្លែងហ្នឹងតែម្តងឲ្យអ្នកយាមក្មេងហ្នឹង គឺថាឲ្យដោះខ្នោះចេញពីខ្ញុំមែន ។

បើអ៊ីចឹងក្នុងលក្ខខណ្ឌបែបនេះ បើសិនជាខ្ញុំមនុស្សស្លូតត្រង់មែន ហើយខ្ញុំត្រូវបានដោះស្រង់មែន មានន័យថាខ្ញុំជាមនុស្សត្រឹមត្រូវទេ ។ អ៊ីចឹង បើសិនជាខ្ញុំត្រឹមត្រូវមែន បើអ្នកខ្មែរពីរនាក់ដែលមកជាមួយខ្ញុំក៏ជាមនុស្សសុចរិតត្រឹមត្រូវដែរ សុំឲ្យដោះលែងផង ។ ពេលនោះ ឌុច ក៏ចេញបញ្ជាឲ្យអ្នកយាមក្មេងៗហ្នឹង បើកឲ្យដោះលែង សហសេវិកពីរនាក់របស់ខ្ញុំ ដែលជាជនជាតិខ្មែរនោះ ។ ហើយខ្ញុំក៏បានជួបពួកគាត់នៅពេលក្រោយមក ។

បាទជាថ្មីម្តងទៀត អ៊ីចឹង ខ្ញុំមិនចាំបាច់ប្រាប់លោក លោកស្រីចៅក្រមទេ ថានៅពេលហ្នឹងគឺជាពេលវេលាដ៏រឹងមាំមួយសម្រាប់ខ្ញុំ ។ ហើយខ្ញុំបានជួបគ្នាឡើងវិញ ប៉ុន្តែ យើងមិនបាននិយាយច្រើននោះទេ ។ បើសម្រាប់ខ្ញុំ នេះគឺជាហេតុផលមួយដ៏រឹងមាំសម្រាប់សេចក្តីសង្ឃឹមរបស់ខ្ញុំ សម្រាប់ជីវិតរបស់ខ្ញុំ ។ ហើយនៅពេលហ្នឹងភ្លាម គឺពួកគេបានជឿថា នេះគឺជាវិធីមួយដើម្បីលុបបំបាត់នូវអ្វីៗផ្សេងទៀត។ ហើយគ្មានអ្នកណាមួយក្នុងចំណោមពួកគេទាំង គ្មានអ្នកណាមួយក្នុងចំណោមអ្នកដែលជាប់គុកទាំងពីរនាក់ ជាសាក្សីរបស់ខ្ញុំ ជឿជាក់អ៊ីចឹងទេ ដែលថាខ្ញុំនឹងត្រូវបានគេដោះលែង ឬក៏បានគិតអំពីចំណុចនេះទេ ។ ដែលថាអ្វីដែលខ្ញុំធ្វើនឹងនោះ គឺជាវិធី ឬក៏មធ្យោបាយដែលពួកខាងមុខៗដែលជាប់ពីមុនមកគេបានធ្វើនោះ ។

[១៤:១៨:៣០]

ដូច្នេះហើយ ខ្ញុំៗត្រូវដោះលែងនៅថ្ងៃបុណ្យ *ណូអែល* ប៉ុន្តែដោយថាមានរឿងហេតុមួយតូចកើតឡើងនោះ ពេលហ្នឹងមានអ្នកយាមក្មេង អត់ៗបានយកកង់ត្រឡប់មកវិញទេ អ៊ីចឹងខ្ញុំត្រូវពន្យារពេលដល់ថ្ងៃបន្ទាប់មកទៀត ។ អ៊ីចឹង ការពន្យារពេលបន្តិចបន្តួចនេះ គឺវាទាក់ទងនឹងតាមគម្រោងដែលថារៀបចំឲ្យខ្ញុំដោះលែងនោះ ធ្វើឲ្យខ្ញុំមានការភ័ន្តច្រឡំ ។ ប៉ុន្តែពេលហ្នឹងហើយ គឺជាថ្ងៃមុនថ្ងៃបុណ្យ *ណូអែល* មួយថ្ងៃ ហើយនេះជាឱកាសមួយថា ខ្ញុំឥឡូវបានគេដោះលែងហើយនោះ ខ្ញុំបានចំណាយពេលមួយយប់ដោយអត់មានជាប់ខ្នោះនោះ ។ ហើយគប្បីដើម្បីបានដឹងឲ្យបានច្បាស់លាស់ ក៏មានទស្សនៈផ្សេងពីគ្នាដែរ ឬក៏ជាមនុស្សផ្សេងពីគ្នាដែរ ដោយមានអត្តចរិតផ្សេងចំពោះគាត់នោះ ។ អ៊ីចឹង ខ្ញុំនៅក្នុងស្ថានភាពមួយ ពីព្រោះពេលនោះ គឺថាខ្ញុំជិតមានសេរីភាពទៅហើយ ហើយគិតអង្គុយនៅជិតគប់ភ្លើង

បើជាទូទៅគឺថាអ្នកយាមនុំង តែងតែដុតគប់ភ្លើងនៅពេលយប់ ពីព្រោះវាត្រជាក់ណាស់ ។ ហើយគិតថាពេលនុំងឯងគឺជារដូវដ៏រងាមែនទែន យប់ឡើងរងាដល់ឆ្អឹងខ្នង ។ ហើយនៅក្នុងពេលយប់ដ៏លំបាកហ្នឹង ពេលហ្នឹងអ្នកយាមបានឲ្យឈើមួយដុំមកខ្ញុំ ដើម្បីឲ្យខ្ញុំអាចគេងនៅលើកន្លែងដែលស្ងួតបាន ហើយដូចថាមានក្ដៅជាង ដោយគេងនៅជិតគប់ភ្លើង ។

នេះគឺជាឱកាសមួយសម្រាប់ខ្ញុំផងដែរ ដើម្បីនិយាយ ។

ដូច្នេះ ក៏យើងបាននិយាយដោយសេរី យើងនិយាយអំពីគ្រួសាររបស់យើង ហើយយើងអាច-- ពេលហ្នឹងខ្ញុំមិនដឹងជា ឌុច អត់មានគ្រួសារអីផ្សេង គឺនិយាយតែពីឪពុកម្ដាយរបស់គាត់តែប៉ុណ្ណោះ ។ គាត់អត់មានកូនអីទេនៅពេលនោះ ។ ហើយគាត់ក៏បានសួរអំពីអ្វីដែលបានកើតឡើងចំពោះកូនស្រីរបស់ខ្ញុំទាំងពីរ ដែលជិះឡានជាមួយខ្ញុំនៅក្នុងភូមិនោះ គឺភូមិដែលជិតវត្តនោះ ។ ហើយគាត់បានស្នាក់នៅទីនុំងជាមួយនឹងកូនៗរបស់ខ្ញុំ ហើយបានលេងជាមួយក្មេងៗនៅទីនោះ ។

នេះគឺជាកាលៈទេសៈមួយ នេះគឺជាពេលមួយដែលជាហេតុផលបង្ហាញអំពីការឈឺចាប់របស់ខ្ញុំ គឺថាខ្ញុំបានបញ្ចូលជាប់ឃុំឃាំង ហើយពេលនោះខ្ញុំមិនដឹងថាកូនរបស់ខ្ញុំនៅទីណាទេ នៅពេលនោះ ។ ហើយពីរ-បីថ្ងៃមុននោះ នៅពេលពីរផ្សេងពីគ្នា ខ្ញុំមិនបានធ្វើ មានការរឿងឆ្ងល់អំពីមធ្យោបាយដែលមានសម្រាប់ជំរំហ្នឹង ដើម្បីឲ្យអ្នកជាប់គុកហ្នឹងដើម្បីនិយាយនោះ ពីព្រោះថាខ្ញុំយល់គឺថាគេតែងតែធ្វើការបកស្រាយសញ្ញា ឬក៏ដៃជាដើម ។ ហើយប៉ុន្តែទៅតាមអ្វីដែលខ្ញុំយល់ ពីអ្នកយាមទោះបីជាពួកគេទទួលបញ្ជាក៏ដោយ ក៏ពួកគេតែងនិយាយអ្វីៗទាំងអស់ប្រាប់ខ្ញុំ ហើយពួកគេពីរនាក់នោះគឺថានៅក្មេងៗពេក ។

[១៤:២២:៤៧]

អ៊ីចឹងហើយ ខ្ញុំព្យាយាមយល់ ថាតើអ្នកជាប់គុកទាំងអស់នោះត្រូវបានគេវ៉ៃ? ដែរថាខ្ញុំត្រូវបានគេតាមមើលនៅថ្ងៃទីដំបូងនោះ គឺវាកើតជារឿងរហូត បន្តបន្ទាប់មកទៀត ខ្ញុំត្រូវគេឲ្យមុជទឹកជារាល់ល្ងាចដែរ ។ ហើយនៅក្នុងអំឡុងពេល ដែលខ្ញុំមុជទឹកនោះ ប្រហែលជាទឹកហ្នឹងមិនលើសពីបីតឹកប៉ុន្នានទេ ហើយទឹកហ្នឹងក៏មិនស្អាតដែរ ។

ខ្ញុំបានឃើញនៅម្ខាងទៀតនៃភូមិនោះ គឺថាមានខ្ទមមួយ ហើយនៅក្នុងខ្ទមហ្នឹង ឬក៏នៅខាងមុខខ្ទមហ្នឹង ។ ហើយពេលនោះខ្ញុំប៊ាន ខ្ញុំទៅជិតខ្ទមនោះដើម្បីពិនិត្យមើល ហើយខ្ញុំបានឃើញគឺថាមានបង្គោលឫស្សីត្រង់ៗ ហើយដែលគេចងចេញជាឆ្កាង ជាដូចថារំពាត់ ជាផ្តៅ ពេលហ្នឹងខ្ញុំយល់ភ្លាម ឬក៏

ខ្ញុំបកស្រាយខ្លួនឯងភ្លាមថា នេះគឺជាកន្លែងដែលគេចង ចងកដៃប្រជាជនជាប់ទៅនឹងបង្គោលនោះ ។ ពេលនោះភ្លាមហ្នឹងៗខ្ញុំបានចេញពីកន្លែងនុ៎ង ហើយការចងចាំមួយទៀតរបស់ខ្ញុំ បន្ទាប់ពីបានមុជទឹក ហើយនុ៎ង ការចងចាំមួយទៀតនោះ ។ អ៊ីចឹង ការមុជទឹកគឺជាឱកាសដែលខ្ញុំអាចមានការគិតផ្សេងទៀត ពីទស្សនៈរបស់ខ្ញុំ ដែលខ្ញុំមាននៅកន្លែងផ្សេងនៅក្នុងអំឡុងពេលថ្ងៃនោះ ។ ហើយពេលមួយនោះ ខ្ញុំបាន ជួបអ្នកជាប់គុកពីមុន មកមុន ដែលជាប់គុកយូរមកហើយ ហើយនៅទីនោះដដែល ដូចជាគាត់ដូចជា អ្នកជាប់គុកដទៃទៀតដែរ ប៉ុន្តែគាត់ត្រូវបានគេដោះលែងពី-- គឺថាគាត់មិនចាំបាច់ធ្វើការដូចអ្នកដទៃ នោះទេ ។ ហើយគឺថាគាត់កំពុងតែរវល់សំលៀងៗដំបងថ្កោ ។

ពេលនុ៎ងខ្ញុំបានសួរគាត់ថា អ៊េក! មិត្តៗនិងយកអាដំបងទៅធ្វើស្អី ទៅវ៉ៃអ្នកណាទេ ពេលហ្នឹង គាត់និយាយថា អ៊េ! ខ្ញុំមិនមែនជាអ្នកវ៉ៃទេគឺថា ឌុច ទេ ជាអ្នកវ៉ៃ ។ ពេលនោះខ្ញុំមិនដឹងទេថា តើខ្ញុំ អារម្មណ៍នៅពេលនោះ ។ តើគាត់នឹងវ៉ៃអ្នកជាប់គុកជាមួយនឹងដំបងនោះ ឬក៏យ៉ាងម៉េចទេ? ប៉ុន្តែនេះ គឺជាអារម្មណ៍ដែលខ្ញុំមានបន្ទាប់ពីបានជួបប្រទះបែបនោះ ។ ហើយនៅពេលយប់នោះ ខ្ញុំបានសួរថា តើនរណាគេជាវ៉ៃអ្នកទោសនោះ? ពេលនោះ ឌុច អត់មានស្ទាក់ស្ទើរទេ បានឆ្លើយថា ជួនកាលគាត់ជា អ្នកវ៉ៃ គាត់នឹងវ៉ៃអ្នកទោសពីព្រោះ ពួកគេហ្នឹងវាភរ ហើយពីព្រោះចម្លើយរបស់ពួកគេហ្នឹងគឺវាផ្ទុយគ្នា ហើយគាត់ស្អប់ណាស់ គាត់ស្អប់អ្នកដែលភរណាស់ ពីព្រោះការស្អប់ជាអំពើអាក្រក់បំផុត ពីព្រោះការ ភរជាអំពើអាក្រក់បំផុត ។ ហើយការងារនេះ គាត់មិនចូលចិត្តទេ ក៏ប៉ុន្តែគឺជាតួនាទីរបស់គាត់ ដែល អង្គការបានដាក់បញ្ជាឲ្យគាត់ ដើម្បីធ្វើកិច្ចការនេះ ។ ហើយជាពិសេសនោះ នេះជាការងារពិសេស ទោះ បីជាគាត់មានភារកិច្ច ។ នេះជាភារកិច្ចរបស់គាត់ ពេលហ្នឹងខ្ញុំដូចជាមានអារម្មណ៍តក់ស្លុតណាស់ ។ ហើយព្រឹត្តិការណ៍ហ្នឹង គឺជាចំណុចត្រឡប់មួយសម្រាប់ខ្ញុំ ។ ហើយខ្ញុំគ្មានមន្ទិលសង្ស័យទេថា ប្រភពនៃ ការចាប់ផ្តើមនៃដំណើរការការគិតនៅក្នុងខ្លួនខ្ញុំនៅពេលនោះ គឺថាលោកចៅក្រមនៅពេលហ្នឹង ខ្ញុំមាន អារម្មណ៍ដូចជាប្រាកដថា ខ្ញុំបានគិតថា ខ្ញុំហ្នឹងគឺខ្ញុំជាអ្នកនៅខាងផ្នែកល្អរបស់មនុស្សជាតិ ហើយ ពួកគេហ្នឹងឯង គឺជាពួកនៅខាងអាក្រក់ ។

[១៤:២៧:៣១]

ហើយអរគុណ ដល់ឋានសួគ៌ គឺថាខ្ញុំមិនមែននៅក្នុងចំណោមពួកវានោះ ពីព្រោះពួកយើងមាន ភាពខុសគ្នា ដោយតាមប្រវត្តិសាស្ត្រ តាមអារម្មណ៍របស់ខ្លួន ហើយនេះគឺវាទាក់ទងទៅនឹងលក្ខខណ្ឌ នៃធម្មជាតិ ។ ហើយមិនមែនមនុស្សគ្រប់ៗរូបអាចជាមនុស្សអាក្រក់ដូចនោះទេ ។ អ្នកខ្លះកើតមកស្ថិត

នៅក្នុងក្រុមនោះតែម្តង ហើយខ្លះទៀតមិនដែលជាមនុស្សបែបនោះទេ ។ ក៏ប៉ុន្តែ នៅយប់នោះគាត់បានឆ្លើយ ហើយការយល់ដឹងរបស់ខ្ញុំនៅពេលនោះ អំពីគាត់ហ្នឹងគឺទៅតាមការសួរផ្សេងៗគ្នា ការសួរចម្លើយរបស់គាត់ផ្សេងៗគ្នានោះ ពេលនោះគឺថាជាការបើកភ្នែកមួយសម្រាប់ខ្ញុំដែលជាព្រឹត្តិការណ៍សម្រាប់បើកភ្នែកខ្ញុំដែរនៅពេលនោះ ។

គឺនៅយប់ទីមួយ មុនបុណ្យ *ណូអែល* គឺថាពេលហ្នឹងខ្ញុំបានជួបមនុស្សម្នាក់ដ៏សាហាវឃោរឃៅដែលគ្មានមនុស្សធម៌ ហើយនេះគឺជាអំពើមួយដ៏គួរឲ្យសោកស្តាយណាស់ ពេលនោះខ្ញុំមានអារម្មណ៍ថានៅទល់មុខខ្ញុំគឺជាមនុស្សម្នាក់ ដែលមើលទៅដូចជាមិត្តភក្តិជាច្រើនផងដែរ ដូចជាមនុស្សធម្មតាតែប៉ុណ្ណោះ ។ ប៉ុន្តែ គឺថាគាត់រៀបចំបូជាជីវិតរបស់គាត់សម្រាប់ប្រទេសរបស់គាត់ សម្រាប់បដិវត្តន៍របស់គាត់ គាត់ជឿអ្វីដែលគាត់ធ្វើ ។ ប៉ុន្តែ គោលបំណងចុងក្រោយរបស់គាត់នៃការប្តេជ្ញារបស់គាត់ ហើយនិងជំនឿរបស់គាត់ហ្នឹង គឺបានសុខុមាលភាព គឺសុខុមាលភាពរបស់ប្រជាជនកម្ពុជា ។

បើគិតថាគាត់កំពុងតែប្រយុទ្ធនឹងអ្វីដែលជាភាពអយុត្តិធម៌ ភាពមិនស្មើភាពនៅក្នុងសង្គម ហើយទោះបីជាតាមវិធីផ្សេងៗគ្នាការពិពណ៌នាអំពីកសិករខ្មែរ ដែលកុម្មុយនីស្តខ្មែរបានប្រើនៅក្នុងការឃោសនារបស់គេ ។ អ៊ីចឹងគឺថាមនុស្សហ្នឹងមិនចាំបាច់ថាជាអ្នកដែលគេបានបង្កើតឡើងនោះទេ ទោះបីជាមានបង្ហាញអំពីប្រភេទមនុស្សបែបនេះក៏ដោយ ប៉ុន្តែ នេះគឺជាវិធានការមួយបង្ហាញអំពីភាពស្មោះត្រង់ត្រឹមត្រូវមួយផងដែរ ។ ការយល់ដឹងរបស់គាត់ គឺវាដូចគ្នាសម្រាប់អ្នកដែលធ្វើបដិវត្តន៍ហ្នឹង នៅទីក្រុងប៉ារីសខ្ញុំក៏មានអ្នកដែលធ្វើបដិវត្តន៍ ដែលមានអារម្មណ៍ និងការប្តេជ្ញាចិត្តដូចជាគាត់ដែរ ដែលគាត់ព្យាយាមរកមើលនូវព្រឹត្តការណ៍ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជានោះ ។ ថាតើព្រឹត្តការណ៍នុ៎ង វាមានសភាពយ៉ាងម៉េចគួរឲ្យរន្ធត់ ឬក៏យ៉ាងម៉េច? ប៉ុន្តែនៅក្នុងជីវិតរបស់ពួកគេ គឺថាពួកគេតែងតែយល់ថា មានន័យថាអ្វីដែលគេបានធ្វើ គឺវាសមរម្យនឹងបុព្វបទរបស់គេហើយ ។ ហើយដើម្បីបង្ហាញអំពីមធ្យោបាយទាំងនុ៎ង គឺមានន័យថា គឺគេធ្វើអ្វីទាំងអស់ ដើម្បីឯករាជ្យរបស់ប្រទេសកម្ពុជា ហើយពេលហ្នឹង គឺថាគេមានសិទ្ធិសម្រេចខ្លួនឯងក្នុងនាមជាប្រជាជនកម្ពុជា ដើម្បីលុបបំបាត់ចោលនូវភាពក្រីក្រ ហើយសេចក្តីសង្ឃឹមរបស់ពួកគេសម្រាប់ទៅអនាគត ។

ហើយប្រទេសកម្ពុជាមិនមែនជាប្រជាជនតែមួយដែលបានសម្លាប់ប្រជាជនខ្លួនឯង ដើម្បីបំពេញបំណងដែលជាសុបិនរបស់ពួកគេទេ ។ ប៉ុន្តែជាការពិតណាស់ មនុស្សដែលជាមនុស្សអាក្រក់មួយដែលកំពុងអង្គុយចំពោះមុខខ្ញុំនៅពេលនុ៎ង គឺថានុ៎ងគឺជាភារកិច្ចរបស់គាត់ ជាភារកិច្ចក្នុងថ្នាក់ជាអ្នកសួរ

ចម្លើយ ។ ហើយទៅតាមអ្វីដែលខ្ញុំយល់ លោក លោកស្រីចៅក្រម ហើយពេលនុ៎ងខ្ញុំមិនបានយល់អ្វីអស់ទេ ឬក៏បានឃើញអ្វីអស់ទេ ខ្ញុំគ្រាន់តែ បានឃើញ បានសក្ខីកម្មអ្វីដែលខ្ញុំបានឃើញបានចងចាំ ។

ប៉ុន្តែអ្វីដែលខ្ញុំបានឃើញ បានចងចាំនោះ គឺថាការងាររបស់គាត់នោះ គឺដើម្បីសរសេររបាយការណ៍អំពីអ្នកដែលគេបានបញ្ជូនមកឲ្យគាត់ ដើម្បីគោលបំណងសម្លាប់ ។ ហើយខ្ញុំក៏បានដឹងដែរថា មនុស្សអាក្រក់នេះឯង តាមពិតគាត់គឺដូចជាមានលក្ខណៈមិនមែនជាមនុស្សធម្មតានោះទេ ហើយខ្លួនខ្ញុំផ្ទាល់ក៏ខ្ញុំមិនមានអារម្មណ៍ដូចថាភ័យខ្លាចពីគាត់ហ្នឹងដែរ ប៉ុន្តែប្រហែលជាអាចជាកំហុសមួយដ៏ធំបំផុតដើម្បីកែប្រែមនុស្សអាក្រក់ហ្នឹងឲ្យក្លាយទៅជាមនុស្សប្រភេទផ្សេងទៀតនោះ ។ ហើយអ្វីដែលពេលហ្នឹងហើយ ខ្ញុំមិនបានគិតពីចំណុចអស់ទាំងនោះទេ គឺថាអ្វីដែលខ្ញុំបានជួបប្រទះហ្នឹង ហើយអំពីបទពិសោធន៍ដែលខ្ញុំបានឆ្លងកាត់ ខ្ញុំគិតថាខ្ញុំបានស្លាប់បាត់ទៅហើយ ។ ហើយដូចជាការស្លាប់បន្តិចម្ដងៗនោះ រហូតដល់ពេលដែលខ្ញុំត្រូវបានគេដោះលែងនោះ ។

[១៤:៣២:២៧]

អ៊ីចឹង គឺថាចំណុចអស់ហ្នឹង វាកើតមានឡើងនៅក្នុងអារម្មណ៍ខ្ញុំនៅពេលក្រោយៗមកទៀត ។ ហើយក្នុងអំឡុងពេលហ្នឹងដែរ អំពីឧក្រិដ្ឋកម្មដ៏ធំធេងដែលកើតមាននៅទួលស្លែងបានកើតឡើងហើយបញ្ចៀសទម្ងន់បន្ថែមទៅលើអ្វីដែលកើតឡើងនៅម-១៣ នោះ ។ ហើយខ្ញុំក៏បានគិតទៀតថា ប្រសិនបើមានអ្វីមួយដែលត្រូវនិយាយ ហើយខ្ញុំត្រូវនិយាយថា ខ្ញុំបានដឹងគាត់នេះក្នុងករណីគាត់ជាបុរសក្មេងម្នាក់ដែលជាជនចង់ធ្វើបដិវត្តន៍ពីក្មេង ហើយដែលត្រូវបានគេហ្វឹកហ្វឺន ដោយមិត្តភក្តិរបស់គាត់ ហើយ គាត់បានទទួលនូវភារកិច្ចជាក់លាក់មួយ ហើយគាត់បានធ្វើការងាររបស់គាត់តាមវិធីមួយដ៏គួរឲ្យភ័យខ្លាចបំផុត ប៉ុន្តែគឺថាទទួលបានផលដ៏ឃោរឃៅបំផុត ហើយដែលមានទស្សនៈមួយ គឺថាគាត់នឹងធ្វើ ការងាររបស់គាត់ឲ្យបានជោគជ័យល្អ ហើយបានចប់សព្វគ្រប់ ។ ហើយពេលនោះ ខ្ញុំក៏បានយល់ផងដែរថា វាជាការចាំបាច់ណាស់ ដើម្បីឲ្យបានដឹងថា តើថាប្រភេទនៃគ្រោះថ្នាក់បែបនេះ គឺមិនមែន បណ្ដាលមកពីមនុស្ស ដែលជាមនុស្សអាក្រក់នោះទេ ដែលជាប្រភេទមនុស្សផ្សេងពីគេនោះទេ ។ ប៉ុន្តែ មនុស្សនេះគឺជាមនុស្សធម្មតាដូចជាយើងផងដែរ ។ ប៉ុន្តែ ជាការចាំបាច់ ដើម្បីធ្វើការបង្ហាញអំពីអ្វីដែលមនុស្សអាចធ្វើបាន និងឬក៏អ្វីដែលជាមនុស្សនោះ ហើយពេលហ្នឹងក៏ខ្ញុំអាចដឹងផងដែរថា ដើម្បីទទួល ជាពិរុទ្ធភាពនូវអ្វីដែលបានធ្វើនោះ មិនមែនជាការចាំបាច់ដើម្បីបង្ហាញថា ឲ្យមានការទទួលខុសត្រូវក្នុង នាមយើងជា

មនុស្សម្នាក់នោះទេ ។ ហើយក៏មិនចាំបាច់ បានន័យថាមានការពាក់ព័ន្ធ ប៉ះពាល់ទៅលើអ្វីដែលបានធ្វើនោះដែរ ។

ហើយពាក់ព័ន្ធទៅនឹងស្ថានភាពដែល ឌុច ជាមនុស្សនៅពេលនោះ គឺថាគាត់មិនអនុញ្ញាតឲ្យខ្លួនគាត់ហ្នឹងដកថយក្រោយវិញបាន ឬក៏ថយចេញបាន ពីព្រោះអី? គឺថាគាត់អាចនឹងមានការភ័យខ្លាចនឹងការស្លាប់ផងដែរ ។ ក៏ប៉ុន្តែ ទាក់ទងទៅនឹងអ្នកដទៃផ្សេងៗទៀត នៅពេលដែលយើងព្យាយាមប្តេជ្ញាចិត្តចិត្តធ្វើការងារបែបនេះក្នុងស្ថានភាពបែបនេះ គឺជាការលំបាកណាស់ដើម្បីថយចេញពីស្ថានភាពបែបនេះ គឺថាគាត់ជាប់នៅក្នុងអន្ទាក់នៅក្នុងស្ថានភាពបែបនោះហើយ ។ នុំងគឺជាអ្វីដែលគាត់មានអារម្មណ៍ ភ័យខ្លាចរហូតមកដល់ថ្ងៃនេះ ។ បាទ នេះគឺជាអ្វីដែលខ្ញុំបានបញ្ចប់នៅក្នុងសក្ខីកម្មរបស់ខ្ញុំហើយ ។

**ប្រធានអង្គជំនុំ៖**

តទៅនេះ តើលោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទេ? បើមានសូមអញ្ជើញ ។ សូមអញ្ជើញលោក ហ្សង់ម៉ាក ។

[១៤:៣៥:៣៦]

**សួរដោយលោក ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណ ចំពោះការផ្តល់សក្ខីកម្ម ។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅលើលោក ដើម្បីឲ្យលោកបំភ្លឺអំពីអត្ថន័យអ្វីៗដែលលោកបាននិយាយជាបឋមនោះ គឺទាក់ទងទៅនឹងជំរំនោះ ដែលបាននិយាយក្នុងអង្គហេតុនោះ ។ លោកបាននិយាយថា នៅក្នុងគំនិតរបស់លោកប្រហែលថាមាន៤0ទៅ៥0នាក់ជាអ្នកទោសនៅក្នុងជំរំនោះ ឬក៏មន្ទីរនោះ ។

**ស៖** តើលោកបានកត់សម្គាល់ទេ ថាតើអ្នកទាំងនោះ គេចេញមកពីប្រភេទប្រជាជនកម្ពុជាណាជាក់លាក់ទេ? ថាតើគេជាជនល្មើសសឹក? ជាអ្នកក្រុង? ជាអ្នកជនបទ? តើលោកបានសង្កេតឃើញថាតើឃើញថាវាមានភាពកែប្រែនៃចំនួនអ្នកទោសថ្មីចាស់ផ្លាស់ប្តូរជាញឹកញាប់យ៉ាងដូចម្តេចដែរ?

**សាក្សី TC-1៖**

**ឆ៖** ខ្ញុំគិតថា ប្រហែលជាមានអ្នកទោស៥0នាក់នៅពេលមួយដែលខ្ញុំទៅដល់ ហើយខ្ញុំនៅទីនោះប្រហែលជាបីខែ ហើយខ្ញុំបានឃើញថា នៅពេលនោះឯង-- ហើយខ្ញុំនឹងឈានទៅចង់យល់ចំណុចមួយជាមូលដ្ឋានថា មនុស្សទាំងអស់នោះ គឺសុទ្ធតែជាកសិករដែលថា អ្នកខ្លះមកពីតំបន់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ហើយការដែលបញ្ជូនមកថ្មីៗនោះ ដែលគេប្រើថាអ្នកបញ្ជូនមកថ្មី អ្នកចូលថ្មី

គឺអ្នកទោសដែលមកម្តងមួយៗ ហើយដែលគេបញ្ជូនមក ម្នាក់មានអ្នកយាមមកជាមួយ ហើយជួនកាលមានកូនស្រីមកជាមួយផង ហើយជួនកាល គេមកម្តងមួយ ឬក៏បី ឬក៏ពីរ ។ ពេលខ្លះគេមកពីតំបន់តែមួយទេម្តងៗ ។ ហើយខ្ញុំគិតថា គេមកពីតំបន់នៅព្រំប្រទល់រវាងតំបន់ខ្មែរក្រហមកាន់កាប់ ហើយនិងជាមូលដ្ឋានរបស់ខ្មែរក្រហម ហើយនឹងម្ខាងទៀតជាតំបន់ដែលស្ថិតនៅជិតនៅក្នុងតំបន់ដែលគ្រប់គ្រងដោយរដ្ឋាភិបាលក្នុងសម័យនោះ ។

ហើយខ្ញុំពិនិត្យឃើញថាម-១៣នេះ មានលក្ខណៈពិសេសមួយនៅក្នុងប្រភេទ គឺជាមណ្ឌលប្រឆាំងនឹងការស៊ើបការខាងកិច្ចការប៉ូលិស ហើយថាមានមនុស្សដែលគេរកឃើញកន្លែងនេះ គឺថាមិនចាត់ទុកថាជាកន្លែងហ្នឹងទេ គឺថាខ្ញុំចង់ដឹងថា តើគេចង់ធ្វើអ្វី កន្លែងខ្លះក្នុងតំបន់នោះ ក្នុងភូមិភាគនោះ ។ ពេលនោះ គឺថាអ្នកខ្លះគ្រាន់តែដឹកទំនិញលក់សោះ អីសោះ ថាស្របច្បាប់ ឬយ៉ាងណានោះ? ហើយក្រោយមកត្រូវបានគេចាប់ខ្លួន ហើយគេចោទថាទៅស៊ើបការនៅកន្លែងនោះទៅវិញ ។

ហើយការមកដល់នូវអ្នកទោសជាកងទ័ពនោះប្រហែលជា១៥ ឬក៏៣០ ខ្ញុំមិនចាំច្បាស់ទេ ហើយកន្លែងនោះ គឺៗថាវាមានការចលាចលមិនធម្មតា គឺថាដោយសារមន្ទីរនោះមិនមានឧបករណ៍គ្រប់គ្រាន់មិនមានកន្លែងដាក់ទុកគ្រប់គ្រាន់នូវការបញ្ជូនអ្នកទោសថ្មីៗមកអ៊ីចឹងហ្នឹង។ ហើយគេបានបញ្ជូនចេញថ្ងៃបន្ទាប់នោះ គេទុកតែមួយយប់ ប៉ុន្តែ ម-១៣ មិនមែនជាកន្លែងសម្រាប់អ្នកទទួលអ្នកទោសថ្មីច្រើនទេ គឺថាដោយខ្ញុំពិនិត្យនៅពេលនោះៗ ។

[១៤:៣៩:៤៩]

**ស៖** លោកបានប្រាប់យើងថា អំពីស្ថានភាព ថាតើស្ថានភាពរបស់លោកហ្នឹង ជាពិសេសសូមឲ្យបញ្ជាក់លម្អិតអំពីស្ថានភាពរបស់លោកផ្ទាល់ ហើយនិងអ្នកជាប់គុកជាមួយលោកហ្នឹង ដែលថាលោករៀបរាប់ពីការមានការជាប់ខ្នោះ ហើយដាក់កជើង ។ តើលោកអាចប្រាប់យើងបានទេ? ថាតើលក្ខខណ្ឌអនាម័យដូចម្តេចដែរ? នៅក្នុងការរស់នៅរបស់អ្នកទាំងនោះ តើគេអាចងូតទឹកបានទេ? ថាតើអ្នក ទោសទាំងនោះមានអ្វីហូបគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** អ្នកទាំងអស់លើកលែងតែអ្នកទោសមួយចំនួនតូចតែប៉ុណ្ណោះ បានជាប់ខ្នោះជើងម្ខាងដាក់ទៅនឹងរនុក ឈើរនុកមួយដែលជាប់ទៅនឹងកងខ្នោះ ហើយដែលមានរបៀបជាគេចាក់សោភ្ជាប់នៅលើកម្រាលនៅក្នុងរោងមួយប្រហែលជា៣០សង់ទីម៉ែត្រ ខ្ពស់ជាងនៅលើខាងលើដីហ្នឹង ប្រហែលជាម្ភៃ ឬក៏ដប់ប្រាំ ឬក៏ម្ភៃនាក់ ដែលជាប់ក្នុងខ្នោះវែងជាមួយគ្នាហ្នឹង ឬក៏ច្រើនជាងហ្នឹងបន្តិចបន្តួច ។

មានរោងបី រោងមួយនោះគឺនៅឆ្ងាយបន្តិចអំពីអ្នកទោសដែលជាអ្នកទោសឈឺនោះ ។ ហើយជាពិសេស គឺថាវាមានផ្ទះពីរដែលមានអ្នកទោសពេញនៅហ្នឹងទាំងអស់ គឺថាពេញណែនតែម្តង ។

ទាក់ទងទៅនឹង លក្ខខណ្ឌអនាម័យវិញ មិនមានលទ្ធភាពអ្វីទាល់តែសោះ ដើម្បីឲ្យពួកគេ ឬក៏អ្នកទោសណាម្នាក់អាចទៅងូតទឹកបាននោះ នៅខាងក្រៅនោះគឺមិនអាចទេ ។ គឺថាលទ្ធភាពនេះ តែបើវាមានភ្លៀងដែលវាកើតចំពោះដែលខ្ញុំជាប់នៅកន្លែងនោះ គឺយើងប្រើបំពង់ឫស្សីដែលយើងប្រើសម្រាប់បត់ជើងតូចនោះ ជាបំពង់ឫស្សីធំ គឺដែលយើងអាចឃើញនៅក្នុងព្រៃកម្ពុជា គេអាចប្រើគឺជាបំពង់ធំមួយដែលយើងអាចប្រើយើងអាចប្រមូលយកទឹកភ្លោតអ៊ីចឹង ដូចបំពង់ទឹកភ្លោតអ៊ីចឹង យើងប្រើបំពង់ឫស្សីវែងមួយជាបំពង់ឫស្សីព្រៃហ្នឹង ដែលគេដាក់ភ្ជួរនៅកន្លែងមួយនៅចុងម្ខាងនៃរបារជញ្ជាំងនោះ ហើយដែលអ្នកទោសអាច ប្រើបត់ជើងតូចបានដោយមិនបាច់រំខានទៅដល់អ្នកដទៃទៀតនោះ ។ ដើម្បីបត់ជើងធំហ្នឹង ឬក៏អ្នកទោសត្រូវនិយាយ ឬក៏ត្រូវប្រាប់ទៅអ្នកនោះអាចនឹងជួបនូវការរន្ធត់ ពេលដែលគេស្នើសុំចេញទៅបត់ជើង គឺថាគេឲ្យដោះចេញដើម្បីទៅបត់ជើងនោះ គឺវាមាន-- ហើយគឺថាជាបំពង់ហ្នឹងគឺថាវាមានកន្លែង ដែលសុទ្ធតែមានភក់ ដែលថាអ្នកទោសត្រូវដើរបណ្តើរចេញ-- ដែលថា ដែលអាចហ្នឹងថា អាចដើរជាន់ទៅលើ ហើយក៏ប្រើបង្គន់មួយដែលគេដាក់ឈើពីរសង្ខាង ហើយអង្គុយបត់ជើងលើឈើនោះ ។ ហើយការភ័យខ្លាច ដែលថារអិលធ្លាក់ចូលទៅក្នុងរណ្តៅបង្គន់នោះ គឺវាការរន្ធត់ណាស់ ។ គឺថា អ្នកទោសនោះ វាបានកើតឡើងថា អ្នកទោសខ្លះទៅបត់ជើង ហើយរអិលជើងពីឈើធ្លាក់ចូលទៅរណ្តៅនោះ ។ គឺថានេះហើយ គឺជាលក្ខខណ្ឌអនាម័យដែលខ្ញុំសូមបញ្ជាក់ ។

[១៤:៥៥:១៩]

**ស៖** ចុះអំពីរបបអាហារវិញ តើបានអ្វីហូប?

**ឆ៖** ចំពោះម្ហូបអាហារ គឺគេចែកពីរដងក្នុងមួយថ្ងៃ ។ ម្ហូបនោះ គឺគេធ្វើពី-- វាមានជាអង្ករ បាយដែលត្រូវបានគេបុកពីព្រឹកដោយអ្នកទោសមួយចំនួនដែលគេដោះឲ្យមិនជាប់ខ្នោះនោះ គេត្រូវបុកអង្ករបុកស្រូវបានជាអង្ករ ហើយគេធ្វើការនៅវាលស្រែនៅក្នុងភូមិជិតៗនោះឯង ។ ហើយអង្ករ ស្រូវអង្ករហ្នឹងមានរសជាតិឆ្ងាញ់ណាស់ ។ គឺថាខ្ញុំឃ្លានណាស់ គឺថាមានអង្ករមួយចំនួន ហើយស្រូវក៏ច្រើនដែរ ព្រោះវាមិនមានកម្រិតទេ គឺច្រើន ។ គឺថាបាយមួយចានពេញហើយយើងហូបតែបាយឲ្យបានច្រើនតាមដែលយើងឃ្លាន ។ ចំពោះរបបអាហារអ្នកទោសផ្សេងៗ ដូចដែលលោកចៅក្រម ឡាវែន៍ បានបញ្ជាក់នោះ គឺថា នៅក្នុងនេះគឺថាខ្ញុំមិនសិទ្ធិជាងគេតាមពិតនៅពេលនោះ ។ ដែលខ្ញុំចាំមិនច្បាស់ទេ នៅក្នុង

ខណៈពេលមួយដែល ឌុច ចាត់ទុកថា ខ្ញុំមិនមែនជាអ្នកមានទោសអំពីការចោទប្រកាន់ប្រឆាំងខ្ញុំទេ ។ ហើយដើម្បីឲ្យខ្ញុំមានសុខភាពល្អ ខ្ញុំមានលទ្ធភាពដើម្បីចែករំលែកនូវស្ងោរ ឬក៏ស៊ុប សម្ល ជាមួយហ្នឹងអ្នកយាម ។ ប៉ុន្តែ របៀបនោះធ្វើនៅខាងក្រៅ ប៉ុន្តែអ្នកទោសផ្សេងៗទៀត ខុសពីករណីខ្ញុំគឺថា អ្នកទោសគឺថារបបគេនឹងគឺដូចៗគ្នា ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា សម្លសម្រាប់អ្នកយាមវិញ គឺជាអាហារមួយដែលធម្មតាស្ងោរ គឺជាសម្លធម្មតា ។

សៈ លោកចៅក្រមចង់ឲ្យយើងឈប់សម្រាក ឬក៏យើងត្រូវបន្តទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជម្រះប្រកាសសម្រាក២០នាទី រហូតដល់ម៉ោង៣:០៥នាទី អញ្ជើញចូលវិញ ។ ហើយមន្ត្រីតុលាការសូមអញ្ជើញសាក្សីទៅកាន់បន្ទប់រងចាំ និងសូមអញ្ជើញគាត់ត្រឡប់មកវិញតាមម៉ោងកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង១៤:៤៧នាទី ដល់ម៉ោង១៥:០៩នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ!

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការនាំ អញ្ជើញជនសាក្សីមកចូលបន្ទប់សវនាការ ។

ជាកិច្ចបន្តសូមប្រគល់វេទិកានេះជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តតាំងសំណួរដល់សាក្សីរូបនេះបន្តទៀត សូមអញ្ជើញ ។

**សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

សៈ មុនយើងសម្រាកយើងបាននិយាយអំពីចំនួនអ្នកជាប់ឃុំគឺថា អ្នកទាំងនោះភាគច្រើនសុទ្ធតែកសិករ ហើយលោកក៏បាននិយាយអំពីអ្នកទោសកុមារ ឬក៏ពីកុមារ ។ តើលោកអាចបញ្ជាក់ដោយលម្អិតអំពីកុមារដែលក៏ជាអ្នកជាប់ទោសដែរនៅក្នុង ម-១៣ នោះ?

**សាក្សី TC-1៖**

**ឆ៖** តាមដែលខ្ញុំចាំ ជាពិសេសគឺថាមានកុមារីតូចម្នាក់ ប៉ុន្តែខ្ញុំមិនគិតថាខ្ញុំចាំក្មេងផ្សេងទៀតនៅទីនោះទេ ។ ខ្ញុំក៏បានចាំផងដែរថា ហើយខ្ញុំគិតថាវត្តមាននៃកុមារីនេះ គឺជាការមួយដែលខ្ញុំមិនអាចស្ទ្រាំបានទេក្នុងពេលនោះ ។ គឺថាកុមារីនោះក៏មកជាមួយឪពុករបស់នាង ។ ខ្ញុំបានចាំច្បាស់អំពីពេលដែលពួកគេនោះមកដល់ក្នុងមន្ទីរ ពីព្រោះខ្ញុំត្រូវបានឃុំនៅក្នុងជិតកន្លែងច្រកទ្វារចូលដែលខ្ញុំអាចឃើញគេយកមនុស្សចូល យកមនុស្សចេញបាន។ ឪពុករបស់កុមារីតូចនេះ ត្រូវបាននាំមកជួប ឌុច ហើយ ឌុច បានមើលទៅក្នុងឯកសារមួយ។ បន្ទាប់ពីនោះមក ហើយគាត់បញ្ជូនបុរសនោះទៅឆ្ងាយហើយអ្នកយាមបាននាំឪពុកនិងកូនស្រីត្រឡប់ទៅកន្លែងឃុំខ្លួន នៅក្នុងជំរំនោះហើយក៏មាន វាមានចំណុចជាក់លាក់ដែលថាខ្មែរក្រហមមិនដែលឆ្លើយទៅនឹងការរិះគន់របស់អ្នកទោសនោះទេ ។ បុរសនេះ គឺថាបានគេចងស្លាបសេកគាត់ ចង់ដៃស្លាបសេកគាត់ ។

នៅពេល ឌុច បានឲ្យឯកសារមួយ គាត់យកឯកសារមួយពីអ្នកយាមមក ហើយអ្នកទោសនោះគោរព ឌុច ហើយ ឌុច ក៏បានសម្តែងអាការៈទទួលអ្នកទោសនោះ ហើយកុមារីក៏នៅកន្លែងនោះដែរ ។ ហើយក៏និយាយទៅកាន់កុមារីនោះតែពីរ-បីម៉ាត់ ខ្ញុំនៅឆ្ងាយ ខ្ញុំមិនអាចស្តាប់ច្បាស់បានទេកាលនោះ ។ ខ្ញុំអាចឃើញដែរថា នៅពីមុខអ្នកយាមនោះគឺមានផ្ទះមួយរោងមួយ ។ ហើយនៅខាងមុខរោងនោះគឺវាមានយ៉ដែល ឌុច ដាក់តុធ្វើការរបស់គាត់នៅកន្លែងនោះ ជាតុរបស់ ឌុច ។ ហើយខ្ញុំឃើញថា ឪពុកបាននិយាយពីរ-បីម៉ាត់ទៅកូនថា គាត់នឹងមកវិញ ។ តើលោកចៅ ក្រមចង់បន្តរឿងរ៉ាវនៃកុមារីតូចនេះ?

[១៥:១៤:០៨]

**ស៖** ខ្ញុំមិនគិតថាសំខាន់ ឬមិនសំខាន់ ខ្ញុំគ្រាន់តែចង់ដឹងថាតើមានកុមារផ្សេងៗទៀតដែរឬអត់? ខ្ញុំចង់ បញ្ជាក់ថា តើកុមារនេះនៅរស់ឬក៏ស្លាប់?

**ឆ៖** កុមារនោះនៅពីរ-បីថ្ងៃ ហើយនាងនោះបានយំ ហើយនាងមិនព្រមញុំាំអ្វីទេ ។ ហើយបន្ទាប់ពីរយៈពេលខ្លីមួយមកគឺថា អ្នកយាមក្មេងម្នាក់បានថែទាំកុមារីនោះ ។ ហើយមិនបានចូលរួមជាសកម្មទេ ចូលរួមនៅក្នុងការប្រជុំទិតៀន ស្វ័យទិតៀននៅរៀងរាល់ល្ងាចដែលគេអង្គុយជុំគ្នានៅកន្លែងមួយក្នុងចំណោមនៅចន្លោះរោងដែលគេឃុំខ្ញុំនៅកន្លែងហ្នឹង ហើយនិងរោងមួយផ្សេងទៀត ។ ដូច្នេះ ខ្ញុំជាសាក្សីសំខាន់បានឃើញរឿងហ្នឹង ហេតុការណ៍ហ្នឹងគឺជា ម្នាក់ៗត្រូវធ្វើការសារភាពពីកំហុសរបស់ខ្លួន ហើយសុំឲ្យមានការកែតម្រូវកំហុសប្រចាំថ្ងៃរបស់គេ ហើយជួយកែតម្រូវកំហុសរបស់មិត្តរួមការងាររបស់គេ ។ អ៊ីចឹងហើយគឺជាពេលខ្លះគេជជែកត្រូវតទល់គ្នាហើយ កុមារីនោះបានចូលរួមក្នុងការប្រជុំទិតៀន ស្វ័យ

ទិតៀនពេលល្ងាចនោះឯង ។ គាត់បានចូលរួមនៅក្នុងការប្រជុំរបស់ការងារអ្នកយាមដែរ ដែលខ្ញុំអាចមើលឃើញ ។

**ស៖** ទាក់ទងទៅនឹងវគ្គទិតៀន ស្វ័យទិតៀននេះ តើលោកអាចប្រាប់បានទេគឺថា អ្នកយាមមួយៗក៏បាន ដឹងថាកំហុសម្នាក់ៗទេ តើមានន័យថានេះជាការជំរុញឲ្យមានការរាយការណ៍នោះទេ?

**ឆ៖** បាទ, គឺថាគេតម្រូវឲ្យមានការងារខិតខំមានលទ្ធផលល្អ ជាឧទាហរណ៍គឺថា អ្នកបដិវត្តន៍វ័យក្មេងគឺមិនស្ទាក់ស្ទើរនឹងធ្វើអ្វីនោះទេ ដែលក្នុងការចោទប្រកាន់ ឬក៏ឆ្លើយរាយការណ៍ ឬក៏មានការសង្ស័យនៅក្នុងក្រុមជាមួយគ្នា ដើម្បីបង្ហាញថាខ្លួនជាអ្នកបដិវត្តន៍ល្អ ។

**ស៖** នេះជាអ្វីដែលលោកបានស្តាប់ដោយត្រចៀកផ្ទាល់ ឬក៏អ្វីដែលលោកបានឃើញដោយផ្ទាល់ភ្នែក ឬក៏អ្វីដែលលោកបានដឹងពេលក្រោយ?

[១៥:១៦:៥៧]

**ឆ៖** ខ្ញុំអាចបានឃើញដោយខ្លួនឯងនូវឧទាហរណ៍ ឬក៏ហេតុការណ៍ហ្នឹងដែលកើតឡើងនោះនៅពេលដែលខ្មែរក្រហមចាប់ផ្តើមបង្ហាញខ្លួននៅតំបន់សៀមរាប ។ បន្តិចពីមុនហ្នឹង ហើយក្រោយមកគេមិននៅយូរទេ នៅក្នុងខែឧសភា ឆ្នាំ១៩៧០ ដែលខ្ញុំចាំច្បាស់ ។ ហើយម្តងហើយម្តងទៀតគេ យើងឃើញ ច្បាស់ថា នៅក្នុងកិច្ចប្រជុំគេឆ្លើយ ឬក៏រាយការណ៍ថា មានសមាជិកផ្សេងគឺថាមិនមែនជាជនបដិវត្តន៍ល្អ ឬក៏ថាវាមានមូលដ្ឋានមួយចំនួនដែលគេ គឺថាអាកប្បកិរិយាមិនល្អ ឬក៏គេនៅក្នុងគ្រួសារក៏ដោយមិនមែននៅក្នុងចំណោមខ្មែរក្រហមទេ ។

នោះគឺជាលក្ខណៈគ្រប់គ្រាន់ដើម្បីឲ្យគេមកហៅឲ្យទៅជួបកម្មាភិបាលខ្មែរក្រហម ឬក៏មេដឹកនាំខ្មែរក្រហមដែលគេមានក្រដាសមួយសន្លឹក គឺគេបង្កើតប្រព័ន្ធរាយការណ៍ ឆ្លើយដាក់អ្នកណាៗ ។ ពេលនោះគឺថានៅក្នុងមន្ទីរ ឬក៏នៅក្នុងជំរំនោះគឺថាមានមនុស្សមួយចំនួន ខ្ញុំមិនដឹងច្បាស់ មិនស្គាល់ច្បាស់ថាតើគេនោះប្រាប់អ្នកផ្សេងអំពីអ្វី? ប៉ុន្តែ អ្វីដែលខ្ញុំចូលចិត្តគាត់នោះ គាត់ជាអ្នកទោសដែលបានស្លាប់នៅក្នុងមន្ទីរនោះ ហើយគាត់គឺជាអ្នកដែលជាប់នៅក្នុងជំរំនៅក្នុងមន្ទីរនោះ មួយឆ្នាំកន្លះហើយមិនបានធ្វើអ្វីហើយមិនមែនជាអ្វីដែលខ្ញុំ ដែលជាគុណប្រយោជន៍សម្រាប់គាត់នោះទេ ពីព្រោះថាមិនដឹងថាពីមុនគាត់ធ្វើអ្វីនោះទេ។ ដូច្នេះ មិនថាករណីនោះទេ វាមានការងារអ្វីដែលប្រឆាំង ទៅនឹងគាត់គឺថា គាត់នឹងបានមកនិយាយជាមួយខ្ញុំជាញឹកញាប់ ។

អ្វីដែលគាត់ប្រាប់ខ្ញុំនោះគឺធ្វើឲ្យខ្ញុំ យល់ថាជារបៀបមួយ ហើយខ្ញុំមិនដឹងថា ឌុច បានដឹង ឬមិនដឹងទេពីហេតុការណ៍នោះ។ ប្រហែលជារបៀបមួយដើម្បីព្យាយាមធ្វើឲ្យខ្ញុំមានអារម្មណ៍ស្ងប់ ថាគាត់នោះគឺនៅកាន់ជើងខាងខ្ញុំ ដើម្បីធ្វើឲ្យប្រាកដ ថាកុំឲ្យខ្ញុំរត់គេចខ្លួន ប៉ុន្តែអ្នកនោះបានប្រាប់រឿងរ៉ាវជាច្រើនដល់ខ្ញុំដែលគាត់បានឆ្លងកាត់នៅក្នុងតំបន់ខ្មែរក្រហម។ ខ្ញុំសូមបញ្ជាក់ថា អំពីការធ្វើការរាយការណ៍នេះគឺថាជាទម្រង់មួយនៃការកុហកដែរ ។ ប៉ុន្តែ សារសំខាន់ជាខ្លឹមសារនៃអ្វីដែលថាការរីកសាយនៃការឃោសនាបដិវត្តន៍ហ្នឹងគឺវានៅក្នុងរបបរាយការណ៍នោះឯង ។

**ស៖** ទាក់ទងទៅនឹងប្រភេទផ្សេងៗគ្នានៃអ្នកជាប់ឃុំ ថាតើមានការអ្នកខ្លះជាប់ច្រវាក់ ឬជាប់ខ្នោះ តើមានអ្នកខ្លះដែលមិនត្រូវបានជាប់ខ្នោះដែរឬទេ? តើមានរបបដាក់ខ្នោះពេលយប់ឬក៏ពេលថ្ងៃខុសគ្នា ដែរឬទេ? តើអ្នកទោសដែលមិនជាប់ខ្នោះនោះ តើមានច្រើនដែរឬទេ?

[១៥:២០:៥០]

**ឆ៖** ទេ គឺមិនមានច្រើនទេ គឺថាអ្នកខ្លះ គឺថាគេធ្វើការងារដាំស្ល ។ ខ្ញុំមិនអាចជម្រាបលោកបានច្រើន ថាតើពួកគេជាប់ខ្នោះពេលយប់ ហើយមិនដាក់ខ្នោះពេលថ្ងៃនោះបានច្រើនប៉ុន្មានទេ? គឺថាអ្នកទោសម្នាក់នោះ ពិតបានរត់គេចខ្លួនប្រហែលជាអ្នកនោះមិនត្រូវបានគេដាក់ខ្នោះទេ នៅក្នុងករណី គឺថាវានាំផលអាក្រក់មួយដល់អ្នកយាម ។ បើគេរត់រួចនោះ បើសិនជាអ្នកណារត់ចេញ ហើយពេលអ្នកខ្លះតាមទៅដែលចាប់បានហើយសម្លាប់គឺថាប្រហែលជាមិនពិតទេ ។ ប៉ុន្តែ នៅពេលដែលជាអ្នកទទួលខុសត្រូវនៅកន្លែងនោះគឺថា គឺអ្នកយាមម្នាក់នោះឯងជាអ្នកយកម្ហូបអាហារមកឲ្យខ្ញុំ ។ គាត់នោះគឺជាមនុស្សដែលស្ងប់ស្ងាត់មិនមែនជាមនុស្សនិយាយច្រើនទេ ។ ហើយយើងទាំងអស់គ្នា នៅពេលដែលម្នាក់នោះរត់បាត់ទៅនោះ យើងទាំងអស់គ្នាហ្នឹង យើងក៏ចង់ធ្វើដូច្នោះដែរ ។ អ្នកមួយចំនួនដែលអាចដើរបាននូវទីនោះ ពាសពេញកន្លែងនោះបាន គឺថាអ្នកដែលជាប់យូរ ហើយអ្នកដែលបានទទួលសិទ្ធិ មិនត្រូវបានដាក់ខ្នោះ ពីព្រោះគេបានធ្វើការងារ គេបានគោរពទៅតាមលក្ខខណ្ឌនៃការឃុំខ្លួន ឬក៏ដែលបង្គាប់ហើយគេមិនបះបោរ ហើយគេមិនតវ៉ា ។

**ស៖** អ៊ីចឹងហើយលោកបានយោងទៅអ្នកយាមម្នាក់ ហើយនិងអាកប្បកិរិយារបស់អ្នកយាមរបៀបជាកាយវិការក្មេង គឺថាអ្នកយាមនោះក្មេងពេក ។ តើលោកអាចបញ្ជាក់បានទេ ថាតើអ្នកយាមទាំងអស់សុទ្ធតែកុមារ តើមានជាមនុស្សចាស់ទេ? តើវាមានឋានានុក្រមអ្វី មានឋានៈខ្ពស់ទាបទេ?

**ឆ៖** ខ្ញុំមិនច្បាស់ថាតើវាមានឋានៈអ្វីទេនៅក្នុងចំណោមអ្នកនោះ ។ គេមានមេរបស់គេដូចជាអនុប្រធានរបស់ ឌុច ហ្នឹងគឺជាមនុស្សចាស់ ។ ប៉ុន្តែ នៅក្នុងឋានៈកម្មាភិបាលខ្មែរក្រហមនោះខ្ញុំមិនដឹងច្រើនប៉ុន្មានទេពីរឿងហ្នឹង ។ ខ្ញុំដឹងរឿងខ្លះអំពីមនុស្សក្មេងម្នាក់ដែលគាត់មកជាច្រើនលើកច្រើនសាមក កន្លែងហ្នឹង ។ គាត់ទទួលខុសត្រូវក្នុងការប្រជុំទិតៀន ស្វ័យទិតៀនដែលគេប្រជុំក្នុងចំណោមអ្នកយាមក្មេងៗដែលគេបំពាក់បំប៉នគោលជំហរនយោបាយគេនោះ ។ ប៉ុន្តែ ក្នុងចំណោមនោះ គឺមានការប្រកាសការឆ្លើយតទល់ដាក់គ្នាទៅវិញទៅមក ហើយក៏មានឮសូរសំឡេងរបៀបនេះដែរ នៅក្នុងភូមិដែលក្នុងឱកាសមួយចំពោះការរៀបចំពិធីជប់លៀងអាហារពេលល្ងាចមួយ ខ្ញុំទទួលបានការអនុញ្ញាតឲ្យទៅជាមួយអ្នកយាមក្មេងម្នាក់ហ្នឹង ដើម្បីទៅភូមិតូចមួយនៅចុងព្រៃ ទៅផ្ទះរបស់ម្ដាយអ្នកយាមក្មេងនោះ ដែលយើងត្រូវទៅសម្លាប់មាន់ ហើយយកមាន់១៣ យកមកធ្វើម្ហូបសម្រាប់ជប់លៀងលាដែលខ្ញុំបានចេញពីកន្លែងហ្នឹង ។ គឺថាកុមារក្មេងដែលមកពីភូមិជិតហ្នឹងឯងគឺថា គេទទួលបាននូវរបបអាហារល្អជាងគេ ប៉ុន្តែបើសិនជាមើលអាកប្បកិរិយារបស់គេវិញ គេទទួលបាននូវវិធានការនៃការការពារតាំងពីរបបអាហារ ហើយនិងថាគេជាជនដែលជឿជាក់នៅក្នុងបដិវត្តន៍ ហើយគេអនុញ្ញាតឲ្យកុមារហ្នឹងធ្វើការជាមួយបដិវត្តន៍ ។ អ៊ីចឹងហើយគឺ គេទទួលបានការពារ ហើយអ្នកយាមហ្នឹងឯង គឺថា ជាកាយវិការរបស់កុមារ ដែលថាជួនកាលគេលេងច្រើន ជួនកាលគេឃោរឃៅគ្មានការគិតគូរអ្វីនោះទេ ។ អ៊ីចឹងហើយ ខ្ញុំបានឃើញជាញឹកញាប់គឺ សុទ្ធតែអ្នកយាមដដែលៗហ្នឹង គឺក្នុងរយៈពេលបីខែ ។ ប៉ុន្តែ កាយវិការរបស់គេនោះមិនមាន-- ប៉ុន្តែអ្នកយាមម្នាក់ដែលថា ល្អចំពោះអ្នកឯងថ្ងៃច័ន្ទ ប៉ុន្តែថ្ងៃអង្គារមិនល្អនេះ ។

**ឆ៖** ប៉ុន្តែទាក់ទងទៅនឹងបញ្ហា ការសួរចម្លើយយើងបានយោងទៅរកវិធីត្រជាក់ តើពាក្យនេះ ជាពាក្យដែលលោកធ្លាប់បានឮទេ នៅពេលដែលលោកជាប់នៅម-១៣?

**ឆ៖** អត់ទេ លោកចៅក្រម ។ ខ្ញុំប្រើពាក្យនេះ ឃ្លានេះ ជាពាក្យអក្សរកាត់ ។ នៅក្នុងស-២១ ខ្ញុំបានដឹងយ៉ាងច្បាស់អំពីអ្វីដែលខ្ញុំបានអាននោះ គេហៅវិធីត្រជាក់ ឬក៏វិធីក្ដៅហ្នឹង ។ តាមដែលខ្ញុំពិនិត្យឃើញនោះ ខ្ញុំមិនចង់យោងទៅរកវិធីសាស្ត្រអ្វី វិធីជាក់លាក់ទេ ខ្ញុំគ្រាន់និយាយថា ខ្ញុំមិនរងការវាយដំការធ្វើទារុណកម្មអ្វីនោះទេ ដើម្បីឲ្យគេទទួលយកពីសេចក្ដីសារភាពពីខ្ញុំហ្នឹងគឺ ខ្ញុំមិនបានរងការវាយដំ ឬក៏ទារុណកម្មទេ ។ នេះជាការបញ្ជាក់របស់ខ្ញុំ ។

**ស៖** តើលោកបាននិយាយថា គេបានសុំឲ្យលោកសរសេរពីសេចក្តីថ្លែងការណ៍ពី ភាពគ្មានទោស ហ្នឹង ជាពាក្យរបស់លោកផ្ទាល់ទេ តើគេបានសុំឲ្យលោកសរសេរឯកសារហ្នឹង នៅក្នុងប្រើពាក្យដោយខ្លួនឯងទេ ឬក៏គេសុំឲ្យលោកធ្វើសេចក្តីសារភាព?

**ឆ៖** បាទ, ប៉ុន្តែវាមើលទៅដូចជាសេចក្តីសារភាព តាមអ្វីដែលខ្ញុំចាំច្បាស់ ប្រហែលជាខ្ញុំបង្កើតពាក្យហ្នឹងដោយខ្លួនឯងទេពេលនោះ ។ ប៉ុន្តែ តាមដែលខ្ញុំយល់ គឺអនុវត្តចំពោះសេចក្តីថ្លែងការណ៍បញ្ជាក់ពីការគ្មានទោស វាមានអត្ថបទ ដើម្បីបញ្ជាក់ថា ខ្ញុំមិនមានពិរុទ្ធភាពចំពោះបទដែលគេចោទប្រកាន់ខ្ញុំ ។ នេះជាធម្មតា នេះជាផ្នែកទីពីរនៃប្រវត្តិរូបការងារសង្ខេបមួយ ដែលបញ្ជាក់សេចក្តីលម្អិតដែលទាក់ទងទៅនឹងមានការសិក្សាជីវិតរបស់ខ្ញុំ ឪពុកម្តាយ ប្រពន្ធ នៅកម្ពុជា ។ បន្ទាប់មក ខ្ញុំត្រូវធ្វើសម្បថមួយអំពីភាពគ្មានទោសរបស់ខ្ញុំ អំពីមូលដ្ឋាន អំពីភាពម៉ឺងម៉ាត់ ដែលខ្ញុំត្រូវសរសេរ ហើយខ្ញុំសូមស្បថថា ចំពោះមុខ កូនរបស់ខ្ញុំ ខ្ញុំមិនធ្វើអ្វី ខុសពីអ្វីដែលខ្ញុំឆ្លើយ ។ ហើយខ្ញុំធ្វើបែបនោះ គឺខ្ញុំបញ្ជាក់ថា ខ្ញុំធ្វើសេចក្តីព្រាងបញ្ជាក់ថា ពីភាពគ្មានទោស ។

[១៥:២៨:៥៩]

**ស៖** លោកក៏បានយោងទៅរកអ្វីដែលលោកបានឃើញនៅក្នុងរោង នៅម្ខាងទៀត នៅត្រើយម្ខាងនៃស្ទឹងតូចមួយនោះ អូរតូចមួយ តើមូលដ្ឋានដែលលោកឃើញនេះ លោកបាន យើងបាននិយាយបញ្ជាក់ថា តើលោកជាអ្នកបានឃើញផ្ទាល់នូវហេតុការណ៍អំពើហិង្សាហ្នឹងទេ ឬក៏លោកបានឃើញសម្រែក ឬការទ្រហោយំអ្វីទេ? ដែលថាអ្វីដែលលោកបានឃើញនោះ ដែលអនុញ្ញាតឲ្យលោកជឿជាក់ថា វាអាចជាសកម្មភាពអំពើហិង្សាដែលបានកើតឡើង?

**ឆ៖** ទេ, ខ្ញុំមិនបានឮការយំទ្រហោ ហើយខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែកនូវទម្រង់នៃអំពើហិង្សាណាមួយដែរ ។ នៅក្នុងការឃុំខ្លួនរយៈពេលទាំងអស់ ខ្ញុំរបស់ខ្ញុំនៅម-១៣នោះ ប៉ុន្តែខ្ញុំបានគិតថា ខ្ញុំចងចាំ គេបានអនុញ្ញាតឲ្យខ្ញុំទៅនិយាយទៅកាន់អ្នកពីរនាក់ដែលជួយខ្ញុំពីរនាក់នោះ ជាជំនួយការរបស់ខ្ញុំ នៅពេលមួយដែល ឌុច បានទទួលយល់ព្រមថា ពួកគេទាំងពីរនាក់នោះ គឺថាសុំឲ្យដោះខ្នោះ ។ អ៊ីចឹងហើយ យើងមានឱកាសអង្គុយជាមួយគ្នា ហើយជជែកជាមួយគ្នា ។ ដូចដែលខ្ញុំបានបញ្ជាក់ហើយ លោកចៅក្រម ទោះបីជាគេមិនដែលនិយាយអ៊ីចឹង ដោយច្បាស់ក្តី ពួកគេជឿក្នុងចិត្តថា គ្មាននរណាម្នាក់នឹងត្រូវបានគេដោះលែងឲ្យរួចខ្លួននោះទេ ។ គេនិយាយថា នៅទីនេះ អ្នកទោសទាំងអស់ត្រូវបានវាយដំ ឬក៏វាយ គេវាយ គេប្រើរំពាត់វាយអ្នកទោសនៅលើទ្រូង នៅលើឆ្អឹងជំនី ហើយអ្នកទោសទាំងអស់

គឺថាមានពាក់អាវ ដែលមានឡេវខ្មៅ អាវនោះគឺក្លាយទៅជាប្រឡាក់គគ្រិច ហើយក៏វាដាច់ដាចរហែក ។ អាស្រ័យទៅ ហើយយើងមិនអាចមើលឃើញ ថាតើស្នាមវាយដំទៅលើខ្លួនរបស់គេបានទេ ។ បើសិនជាការចាំរបស់ខ្ញុំមិនច្បាស់ទេនោះ នៅពេលដែលខ្ញុំបញ្ជាក់ចំណុចនេះ គឺថាអ្នកទាំងអស់នោះបានប្រាប់ខ្ញុំ ជំនួយការពីរនាក់បានប្រាប់ខ្ញុំ ។

[១៥:៣១:៣៦]

**ស៖** លោកបាននិយាយអំពី គេធ្វើសេចក្តីថ្លែងការណ៍ ដោយជនជាប់ចោទនៅពេលល្ងាច យើងមិនបានពិនិត្យឃើញយល់ច្បាស់ អំពីចំណុចនោះនៅឡើយទេ តើលោកអាចប្រាប់យើងបន្តិចថែមទៀត អំពីការសន្ទនា ដែលលោកបាននិយាយជាមួយ ឌុច កាលនោះទាក់ទងទៅនឹងទំនាក់ទំនងរវាងខ្មែរក្រហម ហើយនិងកុម្មុយនីស្តវៀតកុងនោះ?

**ឆ៖** រឿងមួយដែលខ្ញុំចាំ ដែលថាខ្ញុំនិយាយជជែកជាមួយ ឌុច នោះ គឺជារឿងឃោបល់ដែលនិយាយអំពីករណីមួយ ដែលគាត់ថា យើងធ្វើការជាមួយ សហការគ្នាជាមួយវៀតកុង កុម្មុយនីស្តវៀតណាម ហើយពួកគេទាំងពីរហ្នឹងឈ្នះសមរភូមិដូចគ្នា ។ ហើយដោយនិយាយបែបនោះ គឺថាខ្ញុំសម្តែងនូវការមិនទុកចិត្តទាក់ទងនឹងសេចក្តីសម្រេចចិត្ត ដែលថាវៀតណាមគេចូលមកកម្ពុជា ដែលថា ដែលបានបញ្ជាក់ឈ្មោះ សីហនុ នៅក្នុងសេចក្តីប្រកាសរបស់គេ ។ ហើយខ្ញុំមិនដែលឃើញគេមកដល់ភូមិមកដល់ស្រះស្រង់ទេ គឺថាការឲ្យបារីទៅអ្នកទោសនោះ គឺថាដោយយើងហៅបារីថាជា សីហនុៗ ។ អ៊ីចឹងហើយគឺជាពាក្យមួយលាក់សម្ងាត់មួយរបស់គេ ។ អ៊ីចឹង បើខ្ញុំនិយាយពីបញ្ហានេះ ខ្ញុំយោងទៅរកបក្សមួយ ដែលនៅពេលនោះបានចាប់ផ្តើមដកខ្លួនចេញឆ្ងាយពី អំពីសហប្រតិបត្តិការ ឬកិច្ចសហការអំពីបងធំរបស់ប្រទេសជិតខាងនោះ ។

ខ្ញុំក៏បានចាំដែរ នៅក្នុងការសន្ទនាទាំងនោះ ខ្ញុំបាននិយាយថា នៅពេលវៀតណាមខាងជើង កងពលដែលគេបានមកដល់តំបន់សៀមរាបនោះ ជាតំបន់ដែលខ្ញុំរស់នៅ គឺថា១៣គីឡូម៉ែត្រ នៅខាងជើងសៀមរាប គឺថាត្រូវបានបញ្ជប់ វាស្ថិតនៅក្នុងបន្ទាត់មួយដែលថា កងទ័ពវៀតណាមចូលមកក្នុងតំបន់សៀមរាបហើយនៅខាងជើងនោះ ។ ហើយគេក៏បានប៉ុនប៉ង ហើយខ្ញុំ ក៏បានព្យាយាមចេញទៅអង្គរវត្ត ដើម្បីទៅធ្វើការ ការអភិរក្សរបស់ខ្ញុំជាការងារប្រចាំថ្ងៃ ។ ហើយខ្ញុំបានពិនិត្យឃើញថា គេបានបិទផ្លូវ គេបានដាក់កុងត្រូលដោយអន្លើៗ ។ ហើយពួកទាហានវៀតណាមខាងជើងក៏បានបោះទីតាំងនៅទីនោះ ឈរជើងនៅទីនោះ ។ ដូច្នោះហើយ គេបានឃាត់ខ្ញុំ ហើយគេមានមន្ត្រីយោធាម្នាក់ ក្រោយមកគាត់បាន

សួរខ្ញុំ គាត់អាយុប្រហែលជា៥០ឆ្នាំ ។ គេមិនអនុញ្ញាតឲ្យខ្ញុំឈរទេ ឲ្យខ្ញុំអង្គុយ ហើយគាត់ប្រាប់ឲ្យខ្ញុំនិយាយឈ្មោះខ្ញុំ ឲ្យសរសេរ ឲ្យប្រកបឈ្មោះនៅលើដីខ្សាច់ សួរខ្ញុំថា ខ្ញុំមកពីណា? ខ្ញុំធ្វើអីនៅកន្លែងនេះ? ខ្ញុំមានសំណាងណាស់ ដោយគិតថាទាហានរបស់គាត់ចាប់ខ្ញុំបើសិនជាខ្ញុំនៅតែបន្តដំណើរទៅទៀតនោះ ។ ប្រហែលជាគេត្រូវបានចាប់ខ្លួន ដោយទ័ពវៀតណាម ដែលថាម្នាក់បានរបួស ដែលថា ចំត្រូវគ្រាប់ចំពោះនោះ ។

ហើយ ខ្ញុំពិតជាបានដើរនៅក្បែរឡានមួយដែលមានគ្រោះថ្នាក់ចរាចរនៅតាមផ្លូវ គឺថាមានកុមារម្នាក់ ដែលទទួលបាន បានរងរបួសត្រូវចំណាំងគ្រាប់មួយនៅនឹងខ្លួន ហើយគឺកុមារក្មេងប្រុសនោះ គឺថាត្រូវរបួស ហើយមានទាហានម្នាក់ក៏ត្រូវ មានគ្រាប់ត្រូវចំពោះ ហើយខ្ញុំបានយកអ្នកទាំងនោះដាក់ក្នុងឡាន ដើម្បីយកទៅពេទ្យសៀមរាប តាមផ្លូវដែលខ្ញុំទៅធ្វើការ ហើយមន្ត្រីវៀតណាមនោះ គឺថាការប្រយុទ្ធប្រហែលជា៥០ម៉ែត្រខាងមុខហ្នឹងអ្នកឯង មិនអាចទៅបានទៀតទេ បើសិនជាខ្ញុំទៅ គេនឹងបាញ់ខ្ញុំចោល ។

**ស៖** ប្រហែលជាលោកឆ្លើយទៅឆ្ងាយពេក អំពីសំណួរដែលខ្ញុំសួរ សំណួរខ្ញុំ បើខ្ញុំសួរចង់ឲ្យច្បាស់នោះគឺ តើលោកអាចប្រាប់យើងឲ្យបានច្បាស់ ថាតើ ឌុច តើទំនាក់ទំនងរវាងលោក និងគាត់នៅពេលនោះរវាង ជាពិសេសទំនាក់ទំនងរវាងខ្មែរក្រហម និងវៀតណាមខាងជើង តើលោកបានដឹងព័ត៌មានអ្វីខ្លះ អំពីផែនការ អំពីអ្វីៗ ដែលថាជា--

**ឆ៖** សូមអភ័យទោស លោកចៅក្រម ដែលខ្ញុំថា ទៅឆ្ងាយពីអ្វីខ្ញុំចងចាំ ។ គេផ្តល់ឲ្យខ្ញុំនូវ លិខិតធ្វើដំណើរ គឺកងទ័ពវៀតណាមហ្នឹងឯង ដែលបានចេញឲ្យខ្ញុំត្រឡប់ទៅភូមិវិញ ហើយខ្ញុំមិនដែលធ្វើដំណើរទៅណាមកណា ដោយមិនមានលិខិតធ្វើដំណើរនោះទេ ។ អ៊ីចឹង ហើយខ្ញុំត្រូវតែមានលិខិតហ្នឹងលិខិតហ្នឹងសរសេរជាភាសាវៀតណាម ហៅថា *លេសេ ប៉ាសេ* គឺលិខិតធ្វើដំណើរ "គឺសមមិត្តប៊ីហ្សូអ្នកឯងអាចត្រឡប់ទៅផ្ទះវិញ" គឺថាពាក្យនេះ គឺជាពាក្យរៀបរាប់ គឺថាមានប្រយោជន៍ណាស់ ក្នុងការប្រើក្នុងកាលៈទេសៈមួយចំនួន ។

នៅពេលមក ខ្ញុំត្រឡប់មកភ្នំពេញ ទទួលបន្ទុកនៅសាលាបារាំងមួយនៅភ្នំពេញ ខ្ញុំនឹងត្រូវធ្វើដំណើរនៅតាមជនបទ ខ្ញុំត្រូវតែប្រើលិខិតធ្វើដំណើរនេះ ពីព្រោះគឺថាមានកងទ័ពបែបនោះ យើងអាចជួប ជាកងទ័ពវៀតណាម មិនមែនខ្មែរក្រហមទេនៅពេលនោះ គឺថាមានខ្មែរក្រហមតិចណាស់ ។ នៅពេលដែលខ្ញុំ ដែលគេចាប់ខ្លួនខ្ញុំ នៅក្នុងចំណុចមួយនោះ ខ្ញុំគិតថា ប្រហែលគឺជា មានប្រយោជន៍ណាស់

ដើម្បីឲ្យខ្ញុំមានលិខិតធ្វើដំណើររបស់វៀតណាមនេះ ដែលធ្វើឲ្យខ្ញុំក្លាយទៅជាអ្នកសង្ស័យខ្លាំង ប៉ុន្តែការពិតវាទៅជាអ៊ីចឹង ។ ប៉ុន្តែ ឌុច មិនបាននិយាយអ្វីច្រើនអំពីបញ្ហានេះទេ ពីទំនាក់ទំនង ខ្ញុំមិនចាំច្បាស់ទេ ។ ខ្ញុំពិតជាបានគិតថា គាត់កម្រនឹងបាននិយាយអំពីវត្តមានរបស់វៀតណាមខាងជើង គឺថាមិនបាននិយាយអំពីការគំរាមកំហែងទេ ។

**ស៖** អ៊ីចឹង គឺថាលោក គេដោះលែងលោកឲ្យចេញពីមន្ទីរហ្នឹង ហើយលោកបានសរសេរសៀវភៅមួយដែលហៅថា ច្រកទ្វារធំ *ឌឹហ្គេត* នោះ?

**ឆ៖** ខ្ញុំបានសរសេរសៀវភៅនេះ ក្នុងឆ្នាំ២000 លោកចៅក្រម ។

[១៥:៣៩:៤០]

**ស៖** នៅក្នុងទំព័រ២៦ នៃសៀវភៅនេះ លោកបានសរសេរដូចតទៅនេះ៖

ខ្ញុំបានឋិតនៅក្នុងកាលៈទេសៈដ៏អភ័ព្វមួយ នៅពេលដែលសាក្សីម្នាក់នៅខែតុលា ឆ្នាំ២000 គឺថាមានធ្វើការនៅឧដុង្គប្រហែលជា៣0គីឡូម៉ែត្រពីភ្នំពេញហ្នឹង ។ គេបានចាប់ខ្លួនខ្ញុំ ហើយគេដាក់ច្រវាក់ ហើយយកទៅដាក់នៅក្នុងមន្ទីរឃុំឃាំងខ្មែរក្រហមអស់រយៈពេល៣ខែ ។ ខ្ញុំបានឃើញគឺថា នៅភ្លាមនោះបន្ទាប់ពីការដោះលែងរបស់ខ្ញុំ គឺថា ស្ថានទូតបារាំងបានស្នើសុំឲ្យបកប្រែកូនសៀវភៅមួយស្តីអំពីកម្មវិធីនយោបាយរបស់រណៈសិរ្សរួបរួមជាតិកម្ពុជា ។ ហើយខ្ញុំបានយកមកជាមួយខ្ញុំពីព្រៃមកខ្លឹមសារនោះ គឺថានិយាយអំពីអំពើរន្ធត់ និងគឺថា នៅពេលនោះគឺបាននិយាយអំពីការជម្លៀសទីក្រុង ហើយនឹងការបង្កើតនូវៗសម្ងូហភាពគ្រប់គ្រងលើរដ្ឋមួយ គឺផ្អែកទៅលើប្រជាពលរដ្ឋនៅជុំវិញនោះ ។ ប៉ុន្តែការព្រមានបែបនេះ គឺថាៗបានឮដល់ប៉ារីស ប៉ុន្តែគេមិនស្តាប់ដឹងឮ ហើយបារាំងមិនស្តាប់ខ្ញុំទេ ប៉ុន្តែគេនៅតែគាំទ្រខ្មែរក្រហម ។

ដូច្នេះ ខ្ញុំចង់ដឹងបន្ថែមទៀត គឺថាលោកបានបញ្ជាក់នៅក្នុងឯកសារសៀវភៅរបស់លោកហ្នឹងថាតើឯកសារនេះឆ្លើយតបទៅអ្វីដែលលោកសរសេរក្នុងសៀវភៅ ឬក៏លោកចាំពីគំនិតអ្វីផ្សេង?

**ឆ៖** គឺថានៅក្នុងពិធីបាយល្ងាចមួយ ដែលរៀបចំដោយការជប់លៀងលាចេញមក គឺថា នៅតំបន់ មេតំបន់មួយនៅអមលាំង គេបានធ្វើពិធីហ្នឹង ហើយគឺជាកម្មាភិបាលថ្នាក់ខ្ពស់នៅក្នុងតំបន់ហ្នឹងកន្លែងហ្នឹង ។ ជាអ្នកដែលនិយាយច្រើនជាងគេបំផុត ដែលគាត់និយាយមកខ្ញុំ ហើយគាត់សើច ក៏សើចដែរ ។ ហើយៗបានធ្វើមតិយោបល់រឿងនយោបាយទាក់ទងទៅនឹងការជោគជ័យក្នុងអនាគតរបស់គេរបស់ខ្មែរក្រហម ។ ប៉ុន្តែមួយរយៈក្រោយមក ខ្ពីក្រោយមកគាត់និយាយមកខ្ញុំថា ដែលគាត់ចង់ពីព្រោះ

ថា ខ្មែរក្រហមវត្តមានកាន់តែជិតហើយ មកដល់ភ្នំពេញ ដែលថាកងកម្លាំងបដិវត្តន៍នោះ គឺថាគេមិនអាចចូលមកដល់ទូតបារាំង ។ គេបានស្នើសុំឱ្យខ្ញុំជួយយក យល់ព្រមជាមួយគេក្នុងការយកឯកសារមួយយកទៅឱ្យស្ថានទូតបារាំង ។ ហើយខ្ញុំក៏បានទទួលយល់ព្រម ហើយខ្ញុំយកឯកសារហ្នឹង ខ្ញុំដាក់ចូលទៅក្នុងសំណុំឯកសារមួយ ។ ខ្ញុំដាក់នៅក្នុងទ្រូងនៅក្នុងអាវ នេះជាឯកសារហ្នឹង ។ មិនធូនប៉ុន្មានទេ ខ្ញុំដាក់ក្នុងទ្រូង ក្នុងអាវខ្ញុំមក ។

[១៥:៤៣:២១]

ហើយការដែលគេដោះលែងខ្ញុំនោះ ក៏មានន័យថា គឺជាការត្រឡប់មកវិញដល់ភ្នំពេញនេះនៅក្នុងបរិបទមួយជាអ្នកសាធារណរដ្ឋនោះ គឺថាអាចជាមានលទ្ធភាពមួយច្បាស់ថា ខ្ញុំនឹងលើកជាបញ្ហាមួយចំនួន ពីព្រោះរហូតមកដល់ពេលនោះ គឺថាអ្នកទោសដែលត្រូវបានគេដោះលែងនោះ គឺអ្នកទោសថាជាវៀតណាម ពួកវៀតណាម ។ គឺអ្នកទាំងនោះហើយ ដែលខ្មែរ-- អ្នកទោសដែលជាប់កន្លែងនោះ គឺថាឯកសារនេះមានបញ្ជាក់អំពីកូនសៀវភៅពីរដែលបានបោះពុម្ពជាភាសាខ្មែរ ។ ខ្ញុំមិនចាំចំណងជើងច្បាស់អំពីសៀវភៅនោះទេ ហើយខ្ញុំក៏មិនចាំពីខ្លឹមសារនៃកូនសៀវភៅទាំងនោះទេ ។ ក៏ប៉ុន្តែ ខ្ញុំបានបកប្រែអត្ថបទនេះ ដោយហេតុថា ពីព្រោះខ្ញុំមានការប្រុងប្រយ័ត្នណាស់ក្នុងការបកប្រែនោះ ។ ខ្ញុំខ្លាចក្រែងថាអាចនឹងការមានការឆែកឆេរផ្ទះរបស់ខ្ញុំ គេចាប់ ហើយប្រសិនបើគេឃើញឯកសារនេះ នោះមានន័យថាខ្ញុំនឹងត្រូវចេញពីស្រុកខ្មែរ ។ អ៊ីចឹងហើយខ្ញុំមិនចង់ឱ្យគេដឹង ខ្ញុំចង់នៅស្រុកខ្មែរជាមួយក្រុមគ្រួសារហើយបន្តការងាររបស់ខ្ញុំហ្នឹង គឺចាត់ជាការព្រួយបារម្ភរបស់ ។ អ៊ីចឹងហើយខ្ញុំបកប្រែឯកសារនេះគឺឱ្យបានលឿនៗ ហើយពិបាកណាស់ដើម្បីធ្វើដូច្នោះនោះ ។

[១៥:៤៥:១៧]

ខ្ញុំបានផ្តល់ឯកសារនេះទៅឱ្យស្ថានទូតបារាំង ហើយនឹងឱ្យទៅ ហើយខ្ញុំឱ្យរូបថតមួយចំនួនប្រហែលជារូបថត២០សន្លឹកទៅជាមួយឯកសារហ្នឹងផង ។ នោះហើយគឺជាៗរូបថតខ្មៅសទេ ដែលបង្ហាញពីរូបភាពទ័ពខ្មែរក្រហម ប្រហែលជាអាវុធរបស់គេផងដែរនៅក្នុងរូបថតហ្នឹង ។ ហើយក៏បានបង្ហាញរូបភាពមួយចំនួនអំពីរបបខ្មែរក្រហម ដែលបានបង្ក្រាបដោយរបបនោះមានរូបថត ហ៊ូ យន់ និង ហ៊ូ នឹម ដែលទំនងថា ជាអ្នកនៅរស់ទេនៅពេលដែលរូបថតហ្នឹងមានហើយនោះ ។

ខ្ញុំចាំអត្ថបទហ្នឹងបានច្រើនទេ ពីព្រោះនៅពេលដែលខ្ញុំចាប់ផ្តើមសរសេរ នៅពេលដែលខ្ញុំចាប់អារម្មណ៍ថា ចង់សរសេរសៀវភៅនេះ ខ្ញុំបាននឹកឃើញថា ខ្ញុំមានការលំបាកក្នុងការចងចាំពីសេចក្តីលម្អិត

នៅក្នុងអ្វីដែលនៅក្នុងអត្ថបទនោះ ។ ដែលផ្អែកទៅលើអារម្មណ៍ដែលខ្ញុំចងចាំ ជាពិសេសខ្ញុំសរសេរសៀវភៅនេះ គឺថាជារបាយការណ៍ដោយផ្អែកលើ វាមិនមែនជាអ្វី ជាអារម្មណ៍ ការចងចាំដូចជាសាក្សី ។ ខ្ញុំសរសេរសៀវភៅនោះ ផ្អែកទៅលើកអារម្មណ៍របស់ខ្ញុំ ។ ហើយខ្ញុំសរសេរអត្ថបទនេះ គឺពាក់ព័ន្ធនៅក្នុងរឿងនយោបាយ ថាតើខ្ញុំត្រូវដាក់បញ្ចូលក្នុងសៀវភៅ នៅក្នុងបណ្ណសាររបស់បារាំងនៅក្នុងក្រសួងការបរទេសនោះ ។ ខ្ញុំអាចនឹងទទួលបាននូវអត្ថបទហ្នឹងមួយច្បាប់ មិនមែនជាអត្ថបទដែលខ្ញុំបានបកប្រែទេ ប៉ុន្តែអំពីសេចក្តីសង្ខេបរបស់មន្ត្រី *ស្សាស្សេដឺហ្សេន* អ្នកទទួលកិច្ចការបរទេសនោះទទួលបន្ទុកការងារនោះ ។ ហើយគាត់បានសរសេរ គឺសេចក្តីសង្ខេបរបស់ការបកប្រែរបស់ខ្ញុំហ្នឹងដែលអាចរកឃើញនៅក្នុងបណ្ណសាររបស់ក្រសួងការបរទេសបារាំង ជាអត្ថបទមួយដែលមិនគួរឲ្យចាប់អារម្មណ៍អីទេ ។ ក៏ប៉ុន្តែក្នុងករណីនោះ លោកចៅក្រមអាចនឹងឃើញចំណងជើងបានដែរ ។ នេះហើយជាមូលហេតុ ដែលខ្ញុំអាចៗនិយាយបញ្ជាក់ច្បាស់បាន នៅពេលដែលខ្ញុំទាក់ទងភ្ជាប់មកនៅនឹងចំណងជើងសៀវភៅខ្ញុំ ។

**សៈ** ខ្ញុំសូមឲ្យលោកបញ្ជាក់ថា ការបញ្ជាក់គឺយើងបានធ្វើហើយ ដោយសហចៅក្រមស៊ើបអង្កេតផ្ទៀងផ្ទាត់ទាក់ទងទៅនឹងឯកសារទាំងនេះ ហើយយើងបានធ្វើសំណើទៅក្រសួងការបរទេសបារាំង ។ ហើយឯកសារពីរដែលហៅថា ជាឯកសារនយោបាយនោះ គេបានរកឃើញឯកសារពីរដែលដាក់បញ្ចូលទៅក្នុងឯកសារ E២៧១៣ ហើយ E២០ ។ ខ្ញុំជឿថា វាអាចហ្នឹង ខ្ញុំគិតថា ងាយស្រួលដើម្បីយើងឯកភាពគ្នាថា ឯកសារនេះមិនផ្ទុះបញ្ចាំងអំពីសេចក្តីពន្យល់ដែលលោកបានដាក់នៅក្នុងសៀវភៅរបស់លោក ។ ខ្ញុំមិនពិនិត្យឃើញថា មិនមានការបញ្ជាក់អំពីការជម្លៀសប្រជាជនចេញពីក្រុង ឬក៏អនុវត្តនូវគោលការណ៍សម្ហូហភាពរដ្ឋ ហើយមិនឃើញមានសរសេរពាក្យហ្នឹង នៅក្នុងឯកសារនេះទេ ។

[១៥:៤៩:២៥]

**ឆៈ** ពិតហើយ នៅមិនទាន់ដាក់ជូនបញ្ចូលទៅក្នុងឯកសារសង្ខេប ។

**សៈ** អ៊ីចឹងហើយ លោកគិតថា លោកអាចនឹងនឹកឃើញឡើងវិញពីការចងចាំ ហើយនិងដាក់បញ្ចូលនូវព័តមានហ្នឹង ឬក៏នេះជាអ្វីដែលថា ជាអ្វីដែលមានរួចទៅហើយនៅក្នុងឆ្នាំ១៩៧១ ។

**ឆៈ** អ្វីៗគឺអាចមានលោកចៅក្រម ប៉ុន្តែខ្ញុំជឿថា ខ្ញុំចាំ ជាពិសេសថាមានពាក្យ-- ខ្ញុំពិបាកក្នុងការបកប្រែពាក្យនោះ គឺថាពាក្យដែលខ្ញុំបកប្រែនោះគឺ *វិសាម* ក្នុងភាសាបារាំង គឺថាជាពាក្យថ្មីដែលខ្ញុំពិបាកនឹងយល់បាន ដែលបកប្រែទៅជាភាសាបារាំងនោះ ដែលមិនមែនតែជាពាក្យមានន័យច្បាស់នោះ

ទេ ។ ខ្ញុំមិនជឿថា ខ្ញុំជាអ្នកសរសេរអត្ថបទហ្នឹង ដែលថាខុសពីខ្លឹមសារដើមនោះឬម្តេច? អ្វីដែលខ្ញុំចាំបានតាមន័យទូលាយវិញ មិនច្បាស់លាស់ទេ ប៉ុន្តែប្រហែលជាអាចថា ពាក្យដែលខ្ញុំប្រើនៅក្នុងសៀវភៅនោះ គឺជាពាក្យដែលបានប្រើក្នុងពេលក្រោយៗមកទៀត ។ នៅក្នុងខែមេសា ព្រមទាំងនៅក្នុងពាក្យដែលគេប្រើផ្សេងៗទៀត ដូចជាសមូហភាព ។ នោះគឺជាពាក្យជាក់លាក់មួយចំនួនដែលខ្ញុំបានប្រើ ។ ទាក់ទងទៅហ្នឹងអត្ថបទដែលខ្ញុំចាំ តែជាន័យទូទៅទេ មិនចាំលម្អិត ។

[១៥:៥១:២៦]

**ស៖** សំណួរចុងក្រោយមួយ លោកបានបញ្ជាក់ថា របៀបដែលលោកចោទសួរអំពីថាតើអារម្មណ៍របស់លោកចំពោះ ឌុច នេះយ៉ាងដូចម្តេច? ក្នុងសៀវភៅរបស់លោកនេះ និយាយអំពី *ខឺហ្គេត (The Gate)* ទំព័រ៤២៨ ដែលនិយាយដូចខាងក្រោមនេះ៖

បើយើងជាផ្នែកមួយនៃប្រវត្តិសាស្ត្រពេលនោះ គឺថាវាស្ថិតនៅក្នុងការចងចាំរបស់យើងទោះបីជាយើងក្លាយទៅជាឧបករណ៍នៃការអបមង្គលរបស់ក៏ដោយ ក៏ធ្វើឲ្យយើងមានអារម្មណ៍ជំពាក់មួយនៅក្នុងចំណោមយើងទាំងអស់គ្នានេះ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់បន្ថែមនៅពេលដែលសរសេរប្រយោគនេះ តើលោកនិយាយជាមួយ ឌុច ឬក៏លោកនិយាយជាមួយ ឌួង? ដែលថា ជាមនុស្សម្នាក់ ជាអ្នកចាប់អ្នកឯងក្នុងឆ្នាំ១៩៧១ហ្នឹង ។ ទោះជាណាក្តី តើលោកអាចយកប្រយោគហ្នឹង មកប្រើចំពោះ ឌុច ផងដែរឬទេ?

**ឆ៖** បាទពាក្យថា *ខឺហ្គេត* ឬក៏ច្រកទ្វារធំនេះ បានសរសេរ៣០ឆ្នាំក្រោយពីហេតុការណ៍ហ្នឹង ។ តាមរយៈការចងចាំអំពីការភ័យខ្លាច អំពីអារម្មណ៍របស់ខ្ញុំ អំពីមនោសញ្ចេតនាដែលខ្ញុំទទួលបាន ដែលខ្ញុំមិនអាចបំភ្លេចបានទេក្នុងរយៈពេល៣០ឆ្នាំកន្លងមកហើយក្តី ។ ហើយវាទាក់ទងទៅហ្នឹងអ្វីដែល ឌុច នៅម-១៣ នោះគឺជាអ្វីដែលខ្ញុំបានឃើញ ដោយភ្នែកផ្ទាល់ ដោយអារម្មណ៍ផ្ទាល់ ។ ហើយខ្ញុំទទួលហេតុការណ៍ហ្នឹង ដោយមូលដ្ឋាននៃ-- ដែលថា អារម្មណ៍ហ្នឹងហើយវាស្ថិតនៅអន្ទោលតាមប្រាណរបស់ខ្ញុំជានិច្ចនោះ ។ ហ្នឹងគឺថា ជាវិធីមួយដែលប្រើពាក្យពេចន៍ត្រង់ៗ ដែលផ្អែកទៅលើការចងចាំទៅផ្លូវអារម្មណ៍ដែលខ្ញុំទទួលបាន ។ ប៉ុន្តែ វាមិនមែនដកចេញនូវអ្វីទាំងអម្បាលម៉ាន ដែលនៅអាម្មរណ៍ដែលថាៗតាមលំដាប់លំដោយនៃអារម្មណ៍របស់ខ្ញុំ ដែលឆ្លងហេតុការណ៍ហ្នឹង ។ ហើយក៏មិនមែនមានន័យថាវាមិនមានការពិត ដែលកើតនៅក្នុងជំរំនោះដែរ គឺសុទ្ធតែជាការពិត ។

[១៥:៥៤:៤២]

អ្វីដែល ឌុច បាននិយាយ អ្វីដែលអ្នកយាមនិយាយ អ្វីដែលខ្ញុំនិយាយ ដែលទាក់ទងនៅក្នុងសៀវភៅនេះ ខ្ញុំមិនភ្ជាប់ទៅនឹងពាក្យជាក់លាក់ដែលប្រើទេ ខ្ញុំបានភ្ជាប់ពាក្យពេចន៍ខ្លឹមសារហ្នឹង ទៅលើនឹងខ្លឹមសារអ្វីដែលប្រើពាក្យ ខ្លឹមសារនៃការជជែករបស់យើងនាពេលនោះ ។

ឥឡូវនេះលោកបានយោងទៅរក លោកចៅក្រមបានយោងទៅចំណុចជាក់លាក់មួយ ចំណុចនេះគឺជាគំនិតនៃការ *អាហ្វិចសិន* គឺទំនាក់ទំនងមនោសញ្ចេតនា ទោះបីជាទាក់ទងថាជាអារម្មណ៍ហ្នឹង យើងយល់ថាជាអារម្មណ៍អាក្រក់ហ្នឹងក៏ដោយ គឺយើងជិតជាប់ក្នុងអារម្មណ៍ ។

ខ្ញុំសូមបញ្ជាក់ថា អ្វីដែលខ្ញុំប្រឈមជាមួយនឹង ឌុច នោះគឺខ្ញុំដូចជាទុកជោគវាសនារបស់ខ្ញុំ ក្នុងកណ្ដាប់នៃជនម្នាក់ ប៉ុន្តែហើយគឺជាហេតុការណ៍ដ៏សោកនាដកម្មមួយដែរ ដែលខ្ញុំធ្លាប់ឆ្លងកាត់ ដែលថាខ្ញុំជាប់ជំពាក់ ខ្ញុំត្រូវតែកែខ្លួនឯងវិញ ។ ខ្ញុំត្រូវតែតទល់នឹងអ្វីដែលខ្ញុំប្រឈមមុខទាក់ទងទៅនឹងការពិតដែលជាក់ច្បាស់ ដែលចេញពីមនុស្សម្នាក់ ឬក៏បុគ្គលម្នាក់ ដែលជាអ្នកទទួលជោគជ័យ ដែលជាអ្នកមានកម្លាំងអំណាចនៃការសម្លាប់រង្គាលមួយ ។ គឺជាការសម្លាប់រង្គាលដែលបង្កើតឡើងក្នុងរូបភាពជារដ្ឋមួយ ជាស្ថាប័នមួយ ។

បើខ្ញុំមិនបានធ្វើដូច្នោះតទល់ទេ ខ្ញុំមិនអាចនឹងរស់បានដល់ថ្ងៃនេះទេ គឺជាសេចក្ដីរន្ធត់ដែលស្ថិតនៅក្នុងអារម្មណ៍របស់ខ្ញុំ ហើយអ្វីដែលខ្ញុំបានចង់ចាំគឺថា គឺជាការចង់ចាំរបស់បុគ្គលដែលបានប្ដូរផ្ដាច់ជីវិត ប្ដេជ្ញាចិត្ត និងលះបង់ជីវិតរបស់គាត់នៅក្នុងគោលបំណងមួយ ដែលផ្អែកទៅលើគំនិតដែលថា បទឧក្រិដ្ឋមិនមែនថា ជារឿងស្របច្បាប់ទេ ប៉ុន្តែត្រូវតែបន្ត ត្រូវតែទទួលថាការធ្វើឧក្រិដ្ឋហ្នឹងត្រូវតែធ្វើ ។ អ៊ីចឹងហើយ ហើយអ្វីដែលខ្ញុំកើតមក កំណើតរបស់ខ្ញុំគឺ អាចជំរុញឲ្យខ្ញុំជួបនឹងស្ថានភាពហ្នឹង អ៊ីចឹងហើយខ្ញុំមិនអាចនឹងដកខ្លួនចេញពីស្ថានភាពហ្នឹងបាន ។ ហើយខ្ញុំមិនអាចថា ឌុច គឺជាអ្នកប្រព្រឹត្តបទល្មើសនោះ គឺថាធ្វើខ្លួន ឬក៏បញ្ជាឲ្យគេធ្វើនោះតាមអ្វីដែលខ្ញុំយល់ ។ ខ្ញុំមិនអាចកាត់បន្ថយនៅក្នុងគោលដៅ ប៉ុន្តែខ្ញុំចង់កាត់បន្ថយនូវកម្រិតមរណៈ ឬក៏កម្រិតឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងកណ្ដាប់ដៃរបស់គាត់ ។ នោះហើយ គឺជាការលំបាកដែលខ្ញុំប្រឈមមុខនៅពេលនោះ ខ្ញុំទទួលអារម្មណ៍ថា បទឧក្រិដ្ឋនេះគឺជា បទឧក្រិដ្ឋរបស់មនុស្សម្នាក់ ។ ហើយដើម្បីឲ្យយល់បានច្បាស់ គឺជាអំពើដ៏រន្ធត់មួយ មិនមែនអាចបំប្លែង ឌុច ឲ្យទៅជាមនុស្សបែបបិសាចមួយទេ ប៉ុន្តែគេយល់ថាគាត់គឺជាមនុស្សម្នាក់ដែលថាគាត់ទទួលបាននៅការអប់រំមួយដែលថាដូច-- ។ ហើយ យើងមិនអាចចាត់ទុកថាវាជាឧបសគ្គ ។ អ៊ីចឹង

ហើយ ការយល់អំពីភាពមិនច្បាស់នៅក្នុងភាពអមនុស្សធម៌របស់គាត់នោះ គឺដែលបណ្តាលឲ្យមានការសោកនាដកម្មផ្ទាល់ខ្លួនរបស់ខ្ញុំដល់ពេលថ្ងៃនេះ ។

[១៥:៥៩:៥៣]

**ស៖** លោកប្រធាន តើលោកអនុញ្ញាតឲ្យខ្ញុំ សួរសំណួរពីរបីទៀត ទៅជនជាប់ចោទបានឬទេនៅពេលនេះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក, អ៊ីចឹងសំណួរចុះ ។ ហើយជនជាប់ចោទអង្គុយនៅទីនោះហើយ ហើយចាំឆ្លើយនឹងសំណួររបស់លោកចៅក្រម ។

**សួរដោយចៅក្រម ហ្សង់ម៉ាកឡាវែន៍៖**

**ស៖** សំណួរទីមួយរបស់ខ្ញុំ គឺដូចតទៅនេះ លោកនឹកឃើញថា លោកចាំថា នៅពេលដែលខ្ញុំសួរសំណួរលោកអំពីលក្ខខណ្ឌអនាម័យ ចំពោះអ្នកជាប់ឃុំនៅពេលនោះ លោកបានបញ្ជាក់យ៉ាងច្បាស់ថា អ្នកជាប់ឃុំឃាំងនោះ គឺអាចទៅមុជទឹកនៅក្នុងអូរនោះបាន ស្ទឹងនោះបាន ។ ប៉ុន្តែលោកបានស្តាប់សាក្សីនិយាយហើយ គាត់និយាយថា គាត់គឺជាមនុស្សតែម្នាក់គត់ដែលបានទទួលសិទ្ធិទៅងូតទឹកនោះ ។

តើលោកអាចបញ្ជាក់យ៉ាងដូចម្តេចចំពោះចំណុចមួយនេះ?

**ជនជាប់ចោទ៖**

**ឆ៖** លោកចៅក្រមជាទីគោរព! យើងខ្ញុំទាំងពីរនាក់ អត់មានអ្នកណាក្បត់សច្ចធម៌ទេ សច្ចធម៌គឺវាអ៊ីចឹង ។ កាលដែល ប៊ីហ្សូ ទៅនៅជាមួយនឹងខ្ញុំ យើងខ្ញុំនៅក្បែរកូនអូរមួយទេ ជម្រៅបីតឹក ។

ដូច្នេះ គាត់និយាយហ្នឹងពិតហើយ កន្លែងហ្នឹងជនរងគ្រោះដែលទៅជាប់ទោសនៅទីនោះអត់មានបានទៅមុជទឹកទេ ។ កន្លែងដែលយើងខ្ញុំ ខ្ញុំបានរាយការណ៍ផ្ទាល់ជូនលោកចៅក្រមម្សិលមិញ ម្សិលថ្ងៃគឺកន្លែងមួយផ្សេងទៀត ថ្មីទៀត ដែលយើងខ្ញុំទៅនៅជាប់មាត់ស្ទឹង ។

**ស៖** ដូច្នេះ ប្រសិនបើជាខ្ញុំយល់ច្បាស់ អ្វីដែលលោកនិយាយពេលនេះ គឺថានៅពេលដែលលោកឃុំខ្លួន ហ្វ្រង់ស្វ័រ ប៊ីហ្សូ គឺថាអ្នកទោសផ្សេងទៀត គឺមិនបាន មិនបានមានលទ្ធភាពថាទៅមុជនៅអូរ ឬក៏ស្ទឹងនោះទេ ។ ជាពិសេសទៅទៀត លោកនឹងបានស្តាប់សាក្សី ទើបតែបាននិយាយអំពីដែលថា វាមានលក្ខខណ្ឌអនាម័យ ដែលថាខ្យល់អុកស៊ីសែន ដែលថាយើងអាចដកដង្ហើមបាននៅក្នុងម-១៣ ។ វាមានវត្តមាននៃការស្លាប់មនុស្សហ្នឹងច្រើន អ្វីដែលយោង ដែលបានយោងទៅលោក អ្វីលោកនិយាយ

ទៅគាត់អំពីការធ្វើទារុណកម្មដែលគេបានប្រើនោះ ។ ខ្ញុំសូមសួរថាតើ តើមានអារម្មណ៍ តើលោកគិតដូចម្ដេច អ្វីដែលលោកសាក្សីបាននិយាយពីប្រធានបទនេះ ពីបញ្ហានេះ?

[១៦:០៤:២៧]

**ឆ៖** ខ្ញុំបានជម្រាបលោកចៅក្រមហើយ ដំបូងគឺខ្ញុំធ្វើទារុណកម្មទៅលើគិញម្នាក់ឈ្មោះ កៅ ប៊ុន ហៀង ឬ កៅ ឈុនហៀង នោះ ។ ដូច្នេះ ប្រហែលជារឿងហ្នឹងឯងដែលខ្ញុំយកទៅនិយាយជម្រាបលោក ប៊ីហ្សូ ។ ចំណែករឿងផ្ទះខ្ទមមួយដែលគាត់ឃើញ ហើយមានខ្សែ មានកងអីហ្នឹង ខ្ញុំមិនជឿថាគាត់ភរទេ តែមិនមែនជារបស់ខ្ញុំទេ ។

សូមបញ្ជាក់ថា មុនកកើតមន្ទីរ-១៣ មានមន្ទីរគនរបាលរួមទៅហើយ ដែល តាម៉ុក ដេញចោលដឹកនាំដោយពួកហាណូយ ។ ដូច្នេះ អាចសំណល់ពីពួកនោះមកក៏មិនដឹង ហើយយើងខ្ញុំទៅជាន់កន្លែងគេចាស់ក៏មិនដឹង ។ ទារុណកម្ម-- យើងខ្ញុំទទួលមានហូរហែរយ៉ាងតិចណាស់ក៏ពីរដែរ ដែលតាមខ្ញុំចាំ ។

ហ្នឹង ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** ថាតើការិយាល័យ ឬក៏មន្ទីរសន្តិសុខ របស់អ្នកដែលមកពីហាណូយ នោះ នៅកន្លែងណា?

**ឆ៖** ចៅក្រមទេ-- សំណួរវាមិនដែលចំត្រង់ហ្នឹង គឺមន្ទីរនគរបាលដូចគ្នានឹងម-១៣ដែរ ។ តែ តាម៉ុក គាត់ដេញចោល គាត់រំលាយចោលមុនកកើតម-១៣ ។ ខ្ញុំបានទទួលភារកិច្ចជាប្រធានមន្ទីរ-១៣ ខ្ញុំចេញតែដេញសួរ បងហុក ដែរ រឿងអីបានជាតាម៉ុក រំលាយនគរបាលពួកហាណូយ? ដើម្បីជៀសវាងកុំឲ្យខ្លួនខ្ញុំវាធ្លាក់ទៅក្នុងគ្រោះថ្នាក់ ឬតាម៉ុក ដេញចេញ ប៉ុន្តែ បងហុក មិនឆ្លើយប្រាប់ខ្ញុំទេ ។

**ស៖** ខ្ញុំសូមអានសេចក្ដីដកស្រង់ចេញពីសៀវភៅលោក ប៊ីហ្សូ នៅក្នុងទំព័រ១៨៤ ។

នេះគឺជាការសន្ទនារវាងលោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ បាននិយាយថា ខ្ញុំបានស្ដាប់ឮអំពី ឮថាគេចងអ្នកទោស វាយអ្នកទោសនៅក្នុងជំរំនោះ ហើយលោកបានឆ្លើយថា មនុស្សភាគច្រើនដែលបានមកដល់កន្លែងនេះហើយ គឺថាពន្យល់បន្ទាប់ពីសម្ងាត់-- គឺថាសុទ្ធតែជាអ្នកគិញ ជាអ្នកស៊ើបការណ៍ គឺជាការទទួលខុសត្រូវរបស់ខ្ញុំការស៊ើបសួរ ថាតើគេយកព័ត៌មានអ្វី? គេអ្នកណាជាអ្នកចាយលុយឲ្យពួកគេមក? គឺថាជនក្បត់តែម្នាក់ហ្នឹង គឺថាអាចនឹងរារាំងដល់បដិវត្តន៍ ។ ថាតើគេនឹងទំលាត លាតត្រដាងពីអ្វីដែលគេដឹង ទៅដល់អ្នកផ្សេង?

សំណួរពីហ្វ្រង់ស្វ័រ ប៊ីហ្សូ៖ អ្នកណាជាអ្នកវាយដំ អ្នកទោសនោះ? ចម្លើយរបស់លោក លោកឆ្លើយថា អើ! ខ្ញុំខ្ញុំមិនចូលចិត្តអំពីក្បត់របស់គេ គឺគ្រាន់តែបំបាក់ស្មារតីរបស់គេ ហើយដាក់គេឲ្យនៅ

ដាច់ពីគេ ហើយគឺថាឱ្យនៅដាច់ដោយឡែក ។ ហើយយើងមិនអាចស្រមៃមើល ថាតើគេកុហក ការកុហកនោះ ធ្វើឱ្យខ្ញុំខឹងសម្បាណាស់ ។ ពេលដែលខ្ញុំសួរគេនោះ ហើយខ្ញុំមិននិយាយច្រើនទេ ហើយ បើគាត់ថា ការបដិសេធទៅនឹងថ្នាក់លើរបស់ខ្ញុំគឺជាការបំពាន ។ ដូច្នោះ ហើយខ្ញុំត្រូវតែវាយពួកគេ រហូតទាល់តែគេ ទាល់តែខ្ញុំបានទទួលអ្វីដែលខ្ញុំចង់បាននោះ ។

ឥឡូវនេះ តើសេចក្តីអធិប្បាយនៅក្នុងសៀវភៅនេះ តើឯកសារនេះចង្អុលបង្ហាញ ឬក៏ធ្វើឱ្យលោកនឹកឃើញពីហេតុការណ៍នោះទេ? ថាតើលោកបានបញ្ជាក់ពីការពិតនោះទេ?

[១៦:១០:៥០]

**ឆ៖** ខ្ញុំនៅតែជឿថា រឿងដែលខ្ញុំជម្រាបជូនលោក ប៊ីហ្សូ ជារឿងតែមួយគត់ ដែលខ្ញុំសួរចម្លើយគិញម្នាក់ឈ្មោះ កៅ ប៊ុនហៀង នោះ ។ នៅពេលហ្នឹង ដូចខ្ញុំបានរាយការណ៍ជម្រាបលោកចៅក្រមរួចហើយ ឬក៏ព្រះរាជអាជ្ញាក៏មិនដឹង ថាខ្ញុំកំពុងតែគ្រុនចាញ់វិលមុខ ។ កំពុងតែពេលសួរចម្លើយហ្នឹង កំពុងតែសួរចម្លើយស្ងួតៗហ្នឹង មានពួកហាណូយពីរនាក់ កម្មាភិបាលហាណូយពីរនាក់ គេសេរី ដើរមកវ៉ៃ ។ គេដើរមកវ៉ៃផ្ទួសផោះៗ អាហ្នឹងឆ្លើយថាគិញ ។ ដល់ឃើញអ៊ីចឹង ខ្ញុំខឹងដែរ ខ្ញុំដើរទៅរកវ៉ៃ ពេលហ្នឹងៗ ខ្ញុំដើរចេញជំទើតចុងទៅ ទាញរំពាត់ទៅ អានោះវាលើកដៃសំពះ ។ ខ្ញុំ--លើកដៃសំពះ ខ្ញុំសំដៅទៅរកវ៉ៃវា វាលើកដៃសំពះខ្ញុំ ដូចវ៉ៃវាលែងកើត ។ ដូច្នេះវាហត់ វាអស់កម្លាំងពេលហ្នឹង ចង់ងាប់ហើយ យកឱ្យគេទៅទុក ។ ដូច្នេះវាហត់ វាអស់កម្លាំង វាវិលមុខ គឺនៅពេលហ្នឹងឯង មានតែម្តងហ្នឹងឯង ដែលសុខភាពខ្ញុំមិនអំណោយ ។ សុខភាពខ្ញុំវាមិនអំណោយ ទទួលជួបបញ្ហាខាងផ្លូវចិត្តអ៊ីចឹងមកទៀត ខ្ញុំមិនសប្បាយចិត្តខ្ញុំស្ទុះទៅរកវ៉ៃមែន ហត់មែនចង់ដាច់ដង្ហើមខ្លួនឯងមែន ។

[១៦:១៣:៥៥]

**ស៖** សូមអត់ទោស! សូមទោសដែលនិយាយកាត់លោក ប៉ុន្តែអ្វីដែលលោកបានប្រាប់យើងនោះ ថាតើយើងយោងទៅរកសម្តីរបស់ ប៊ីហ្សូ ថាមិនមែនអ្វីស្របទៅ និយាយទៅគាត់ទេ ។ តើពិតដែរ ឬមិនពិត? វាស្របគ្នា ឬមិនស្របគ្នា?

**ឆ៖** ខ្ញុំមិនបានមើលអត្ថបទនេះរបស់លោក ប៊ីហ្សូ ច្បាស់លាស់ទេ ។ ក៏ប៉ុន្តែរឿងដែលខ្ញុំបានចាំ ហើយខ្ញុំធ្វើ គឺដូចដែលខ្ញុំរាយការណ៍ជូនលោកចៅក្រមអ៊ីចឹង ។ នៅពេលចំពោះមុខនេះ ខ្ញុំអត់ហ៊ានបញ្ជាក់ជូនលោកចៅក្រម ហើយបដិសេធចម្លើយលោក ប៊ីហ្សូ ទេ ។ រឿងវាសាមសិបឆ្នាំហើយ ទុកពេលវេលាឱ្យយើងខ្ញុំទាំងពីរនាក់ពិចារណា ។

**សៈ** ខ្ញុំចង់សួរអំពីចំណុចល្អិត តើលោកបានមើលសៀវភៅដែលរបស់លោក ប៊ីហ្ស៊ូ ទេ? យើងបានផ្តល់មួយ *កូពី* ហើយតើលោកបានអានទេ?

**ឆៈ** ខ្ញុំមិនមានសៀវភៅនេះទេ ។

**សៈ** នៅទំព័រ១៦៩ និយាយអំពីការបាត់បង់ជីវិត ។ លោកចង់ចាំលេខទំព័រទេ ប៉ុន្តែលោកមិនចាំអ្វីដែលសរសេរក្នុងហ្នឹង អំពើទារុណកម្មនៅក្នុងសៀវភៅហ្នឹងទេឬ?

**ឆៈ** ខ្ញុំគិតថារឿងទារុណកម្ម រឿងអីៗនេះ ជាឧក្រិដ្ឋកម្មដែលវាមានទៅលើជនរងគ្រោះមែនពិត ។ ហើយខ្ញុំដឹងថាលោក ប៊ីហ្ស៊ូ ទៅនៅជាមួយនឹងខ្ញុំ ខ្ញុំអត់ដែលបានវ៉ៃ ខ្ញុំអត់ដែលបានគំហកអីទេ ខ្ញុំអត់ដែលបានអី ។ ដូច្នេះ ខ្ញុំឃើញទុក្ខសោករបស់គាត់ដែលធំ គឺរឿង ឡាយ ហើយនិង សុន ហ្នឹងឯង ។

**សៈ** សំណួរមួយចុងក្រោយ គេបាននិយាយច្រើនអំពីគោលចំណងរបស់លោក ថាចង់ដឹងការពិត ។ ហើយក៏បាននិយាយច្រើនដែរអំពីការស្អប់ការនិយាយកុហក ។ ខ្ញុំចង់សួរសំណួរទៅលោក ដើម្បីឲ្យលោកបញ្ជាក់ ថាតើអ្វីនៅក្នុងឯកសារ D-67 នៅក្នុងសំណុំរឿង ដែលយោងទៅរកការសម្ភាសន៍ស្តួរចម្លើយលោក ដែលចៅក្រមសួរសំណួរដូចខាងក្រោមនេះ នៅក្នុងស្តួរចម្លើយនោះ ។ នេះខ្ញុំដកស្រង់លេខ ERN001776425 នេះនៅក្នុងអត្ថបទបារាំង 7654 គឺ D-67 គឺជាលេខយោងមួយនៅឯកសារនោះ ។ សំណួរដែលសួរនោះ គឺថាដូចខាងក្រោមនេះ៖

ដែលនាំឲ្យយើងសួរលោក គឺអំពីតម្លៃដែលលោកបានពិនិត្យឃើញនៅក្នុងខ្លឹមសារ នៃចម្លើយសារភាព តើលោកជឿថាចម្លើយសារភាពហ្នឹងឆ្លុះបញ្ចាំងពីការពិតឬទេ? តើលោកបានដឹងអំពីការកែប្រែក្នុងរយៈកាលកន្លងមកច្រើនឆ្នាំនោះទេ? នៅពេលនោះលោកបានពន្យល់មួយចំនួននៅស-២១ អំពីចំណុចផ្សេងៗ ប៉ុន្តែលោកនិយាយថា ចំណុចមួយខ្ញុំដកស្រង់ “តាមពិតតាំងពីដំបូងដើមនៅម-១៣ ខ្ញុំដឹងថាចម្លើយសារភាពនោះ គឺមិនឆ្លុះបញ្ចាំងពីការពិតនោះទេ ។ ខ្ញុំ គេបានបង្ខំខ្ញុំឲ្យធ្វើការនៅបម្រើនៅអង្គការឧក្រិដ្ឋកម្មពេញមួយជីវិតខ្ញុំ អ៊ីចឹងហើយខ្ញុំត្រូវតែទទួលភារកិច្ចហ្នឹងនៅក្នុងហេតុការណ៍ហ្នឹង”តើលោកបានយល់ច្បាស់ទេ? តើលោកមានមតិយោបល់ទេអំពីពាក្យ ដែលលោកបាននិយាយនោះ?

[១៦:១៩:៤០]

**ឆ៖** ខ្ញុំឮលោកចៅក្រមអានច្បាស់ ហើយខ្ញុំយល់ច្បាស់ ហើយខ្ញុំនៅតែរក្សាថានេះជាសេចក្តីទៅតាមគោលជំហរខ្ញុំ ដែលវិភាគទៅលើសេចក្តីសារភាព ដែលយើងខ្ញុំទទួលបានដោយទារុណកម្ម ។ យើងខ្ញុំនៅតែទទួលស្គាល់ថា នេះជាឧក្រិដ្ឋកម្មដែលអត់ប្រកែក ។

**ស៖** សំណួរខ្ញុំ គឺវាមានលក្ខណៈជាក់លាក់ លោកបាននិយាយថា គឺនិយាយដោយយ៉ាងច្បាស់ពីដំបូង ពីមុនដំបូងនៃប្រតិបត្តិការនៃម-១៣ ខ្ញុំដឹងថាចម្លើយសារភាពទាំងអស់នោះ គឺមិនឆ្លុះបញ្ចាំងពីការពិតទេ ។ តើអាចបញ្ជាក់ទេ លោកបានដឹង ដែលថាចម្លើយសារភាពទាំងអស់នោះ គឺមែនជាការពិតទេ តាំងពីដំបូងនៃម-១៣ នោះដែរ?

**ឆ៖** ខ្ញុំនៅតែទទួលស្គាល់ថា សេចក្តីសារភាព ។

**ស៖** សូមលោកបញ្ជាក់ឡើងវិញ ប្រយោគចុងក្រោយៗ របស់លោកគឺថាអាច-- គឺថាអាចនឹងបកប្រែខ្វះ ឬក៏លោកមិនបានបញ្ចប់?

[១៦:២១:៣៣]

**ឆ៖** ខ្ញុំនៅតែទទួលស្គាល់ថា សេចក្តីសារភាពដែលយើងខ្ញុំទទួលបានមិនស្របនឹងការពិតទាំងស្រុងទេ យ៉ាងច្រើនណាស់បានម្ភៃភាគរយ យ៉ាងច្រើនណាស់បានត្រឹមម្ភៃភាគរយហ្នឹង ។ បើអំពីចំនួនមនុស្ស ដែលគេឆ្លើយដាក់វិញ កាន់តែតិចទៀតហើយ យ៉ាងច្រើនដប់ភាគរយ ។

**ស៖** តើមានការពិតមួយ ដែលថាជាការពិតនយោបាយ ឬក៏ការពិតត្រូវតែស្របជាមួយនឹង ដូចជាការពិតខាងវណ្ណៈអធន វាត្រូវតែមានភាពខុសគ្នាអំពីការពិតនៃបរិបទនីមួយៗនោះ?

**ឆ៖** សូមៗ គិតបន្តិចសិន សំណួរនេះជ្រៅណាស់ ខ្ញុំពិបាកឆ្លើយ ។ យកល្អសូមលោកចៅក្រមមេត្តាសួរសំណួរ ដែលមានន័យអ៊ីចឹង ក៏ប៉ុន្តែមាននេះចែកជាពីរ-បីសំណួរ ។

**ស៖** លោកបាននិយាយថា ប្រហែលម្ភៃភាគរយនៃខ្លឹមសារក្នុងចម្លើយសារភាពទេ ដែលឆ្លុះបញ្ចាំងពីការពិតនោះ ។ មានតែម្ភៃភាគរយទេ អ៊ីចឹងសំណួរខ្ញុំដូចខាងក្រោម៖

ចុះផ្នែកផ្សេងដែលនៅសល់ តើលោកអាចនិយាយថាចម្លើយសារភាពហ្នឹងគឺស្របជាមួយនឹងការពិតដែលមិនមែនជាសត្យានុម័ត ប៉ុន្តែជាការពិតប្រភេទមួយដែលកំណត់ឡើង ដោយមាគ៌ារបស់បក្សដោយមនោគមវិជ្ជាវណ្ណៈអធន? តើការពិតហ្នឹងវាឆ្លុះបញ្ចាំងនោះទេ?

**ឆ៖** អា២០ភាគរយដែលខ្ញុំតែងតែនិយាយថាសេចក្តីសារភាព វាមិនដែលពិត ពិតយ៉ាងច្រើនបាន ២០ភាគរយនេះ យ៉ាងនេះ ។ រឿងរ៉ាវអីដែលធ្វើ ដល់យើងចាប់ច្រើនមក មនុស្សខ្លះអាសកម្មភាពបដិវត្តន៍សោះ ទៅថាសកម្មភាពបង្កប់ ។

ដូច្នេះ ខ្ញុំសូមនិយាយនៅពេលហ្នឹងចម្លើយ កុយ ធួន បន្តិចចុះ។ ខ្ញុំអត់បានអានទេ ប៉ុន្តែខាងលើគេអ្នកអាន គេថាវាដូច វាត្រឹមត្រូវហើយ ។ ក៏ប៉ុន្តែ ចំពោះខ្ញុំវិញ ខ្ញុំនៅតែចោទបញ្ហា ថាតើអានេះជាសកម្មភាពក្បត់ ឬក៏ជាសកម្មភាពបដិវត្តន៍ដែល កុយ ធួន គាត់មិនបង្វែរពាក្យថា ខ្ញុំធ្វើនេះតាមបញ្ហាអ្នកនេះ តាមបញ្ហា *សេអ៊ីអា* អីចុះ ។ ដូច្នេះ ដែលខ្ញុំគិតថាមិនពិតនេះ មកពី លាប ហ្នឹង នៅក្នុង--

[១៦:២៦:៣២]

**ស៖** អីចឹងជាសំណួរចុងក្រោយមួយរបស់ខ្ញុំ លោកបានឮអ្វី អំពីអំពើនៃអំពើ ដែលថាការរាយការណ៍ ឬក៏ឆ្លើយដាក់ តើលោកមិនស្តាប់សំណួរច្បាស់? ខ្ញុំបានស្តាប់ចម្លើយហើយខ្ញុំ ប៉ុន្តែខ្ញុំមិនឮពាក្យ *ដឺឡាសស្យុង* ជាភាសាបារាំង ជាការឆ្លើយទម្លាក់កំហុសទៅលើអ្នកណាម្នាក់ទៀតនោះ ។ ថាតើនេះគឺជាកាយវិការមួយ ឬក៏ជាគោលការណ៍ដែលមនុស្សគ្រប់គ្នាត្រូវយកមកប្រើដើម្បីឲ្យខ្លួនក្លាយទៅជាអ្នកបដិវត្តន៍ល្អ ។ លោកបាននិយាយពីខាងដើមហើយថា គឺជាការល្អដើម្បីនឹងរាយការណ៍ទម្លាក់កំហុសពីឪពុកម្តាយរបស់ខ្លួន ដើម្បីក្លាយជាអ្នកបដិវត្តន៍ល្អ?

**ឆ៖** នេះវាជាបញ្ហាទ្រឹស្តីទេ ។ ខ្ញុំឮនិយាយយូរហើយ ខ្ញុំឮគេនិយាយយូរហើយ កាលដែលខ្ញុំនៅជាប់គុកធំ ពីកម្មាភិបាល គេរៀនពីកម្មាភិបាលវៀតណាម ។ ចាប់ឪពុកមក ថ្វាយបង្គំឪពុក ថាខ្ញុំសូមថ្វាយបង្គំឪពុក តែខ្ញុំសូមបាញ់ចោលខ្លាំង ។ ឯចំណែកក្នុងការអនុវត្តវិញ ខ្ញុំបានរាយការណ៍ជូនលោកថៅក្រុម ខ្ញុំមិនចូលចិត្តអ៊ំា ខ្ញុំមិនចូលចិត្តឲ្យកូនចៅគេរាយការណ៍ពីម៉ែឪគេទេ ខ្ញុំជ្រើសរើសកូនកសិករដែលល្អមក ដើម្បីពឹងពាក់ យោងគ្នាទៅវិញទៅមកទៅថ្ងៃមុខ ។

ដូច្នេះគោលជំហរ ដូច្នេះខ្ញុំអត់ដែលប៉ានចង់ឲ្យអ្នកណាអ្នកអនុវត្តឯង គោលការណ៍រាយការណ៍ចោទប្រកាន់អំពីឪពុកម្តាយខ្លួនឯងទេ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលត្រូវឈប់សម្រាកនៅពេលល្ងាចហើយ អង្គជំនុំជម្រះសាលាដំបូង ប្រកាសផ្អាកសវនាការ ការពិភាក្សាដេញដោលនៅថ្ងៃនេះត្រឹមនេះ ។ ហើយសវនាការនឹងបន្តនៅពេលព្រឹកថ្ងៃស្អែកទីប្រាំបួន ខែមេសា ចាប់ពីម៉ោងប្រាំបួនតទៅ ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទ កាំង ហ្កេកអ៊ាវ ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកកាន់ទីនេះ ឲ្យបានមកមុនម៉ោងប្រាំបួនព្រឹកនៅថ្ងៃស្អែក ។ លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដោយហេតុអង្គសវនាការត្រូវការស្តាប់ចម្លើយលោកនៅជាបន្តនៅថ្ងៃស្អែក ចាប់ពីម៉ោងប្រាំបួនទៅ ។ ដូច្នេះ អង្គជំនុំជម្រះ សូមអញ្ជើញលោកមកកាន់បន្ទប់សវនាការនេះចាប់ពីម៉ោងប្រាំបួន នៅថ្ងៃទៀត ។ ហើយមន្ត្រីតុលាការសហការជាមួយនឹង *វីហ្សូ* ដើម្បីជួយសម្រួលដល់សាក្សីរូបនេះ ឲ្យត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅវិញ និងសម្រួលឲ្យគាត់ត្រឡប់មកកាន់សាលសវនាការវិញឲ្យបានទាន់ពេលមុនពេលម៉ោងប្រាំបួនព្រឹកនៅថ្ងៃស្អែក ។

ហើយសូមជម្រាបដល់អ្នកចូលរួមនៅក្នុងនីតិវិធីសវនាការនិងសាធារណជនដូចគ្នា គឺសូមអញ្ជើញចូលមកសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

*[សវនាការផ្អាកនៅម៉ោង ១៦:៣១នាទី]*